# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រ
## អភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
## ២០១៩-២០២៣

រៀបចំដោយ
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
ឆ្នាំ ២០១៨

# អារម្ភកថា

អាទិភាពគោលនយោបាយចម្បងរបស់រាជរដ្ឋាភិបាលគឺការរក្សាសន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខជាតិដែលជាបុរេលក្ខខណ្ឌដ៏ចាំបាច់ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ លើកកម្ពស់ជីវភាពរស់នៅនិងសេចក្តីថ្លៃថ្នូរបស់ប្រជាជន ។ ប្រជាជនកម្ពុជាបាននិងកំពុងទទួល ផ្លែផ្កាពីសេចក្តីសុខសន្តិភាព ស្ថិរភាពនយោបាយ និងកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា បានបញ្ចប់បេសកកម្មជាប្រវត្តិសាស្ត្ររបស់ខ្លួន ប្រកបដោយភាពជោគជ័យ និងសម្រេចបានសមិទ្ធផលធំៗជាច្រើន ជាក់ស្តែង កំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាជាង ៧% ក្នុង ១ឆ្នាំ។ ទំហំសេដ្ឋកិច្ចជាតិ (ផសស តាមថ្លៃបច្ចុប្បន្ន) បានកើនឡើងពី ៦១.៣២៦.៩២៨លានរៀល ឬសមមូលនឹងប្រមាណជាង ១៥.២៣៧លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០១៣ ដល់ ៩៩.៣៣២.២១៩លានរៀល ឬសមមូលនឹងប្រមាណជាង ២៤.៦០៥លានដុល្លារអាម៉េរិក នៅឆ្នាំ២០១៨។ អត្រាប្តូរប្រាក់ស្ថិតនៅក្នុងរង្វង់ ៤.០៥០រៀល ក្នុង ១ ដុល្លារ ក្នុងខណៈដែលអត្រាអតិផរណាជាមធ្យមស្ថិតក្នុងរង្វង់ ៣%។ ទុនបម្រុងអន្តរជាតិកើនឡើងពី ៣.៦៤៣ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០១៣ ដល់ ១០.០៥០លានដុល្លារអាម៉េរិក នៅឆ្នាំ២០១៨។ ទុនវិនិយោគដែលត្រូវបានអនុម័តចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧ មានទំហំសរុប ២៣,៣ប៊ីលានដុល្លារអាម៉េរិក។ ទំហំពាណិជ្ជកម្មអន្តរជាតិបានកើនឡើងពី ១៦.២៧៩លានដុល្លារអាម៉េរិក នៅឆ្នាំ២០១៣ ដល់ ២៥.០៧០ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០១៧ និងអាចឡើងដល់ប្រមាណ ២៨.០៣៦លានដុល្លារអាម៉េរិក នៅឆ្នាំ ២០១៨ ដោយក្នុងនោះ ការនាំចេញបានកើនឡើងពី ៦.៥៣០លានដុល្លារអាម៉េរិកនៅឆ្នាំ២០១៣ ដល់ ១០.៨៤៩លានដុល្លារអាម៉េរិក នៅឆ្នាំ២០១៧ និងអាចឡើងដល់ប្រមាណ ១២.១២៣លានដុល្លារអាម៉េរិក នៅក្នុងឆ្នាំ២០១៨ ខណៈដែលការនាំចូលបានកើនឡើងពី ៩.៧៤៩លានដុល្លារអាម៉េរិក នៅឆ្នាំ២០១៣ ដល់ ១៤.២២១លានដុល្លារអាម៉េរិកនៅក្នុងឆ្នាំ២០១៧ និងអាចឡើងដល់ប្រមាណ ១៥.៩១៣លានដុល្លារអាម៉េរិក នៅឆ្នាំ២០១៨។ អត្រានៃភាពក្រីក្រដែលត្រូវបានវាស់វែងឃើញថាប្រមាណ ៥៣,៥% ក្នុងឆ្នាំ ២០០៤ បានធ្លាក់ចុះមកនៅ ១៣,៥% នៅឆ្នាំ២០១៤ និងបន្តធ្លាក់ចុះក្រោម ១០% នៅឆ្នាំ២០១៨។

សេចក្តីប្រាថ្នា និងការខិតខំរបស់រាជរដ្ឋាភិបាល គឺប្រែក្លាយឋានៈរបស់កម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទៅប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ រាជរដ្ឋាភិបាលបានកំណត់នូវចក្ខុវិស័យរយៈពេលវែងសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមគឺ ការកសាងប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាប័ន្ន ប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុដែលជាឧបករណ៍បម្រើដល់ការកាត់បន្ថយនិងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព ហើយរួមចំណែកដល់ការអភិវឌ្ឍ និងគាំពារធនធានមនុស្សកាន់តែទូលំទូលាយ និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ផ្អែកលើចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដែលមានលក្ខណៈទូលំទូលាយ ដោយផ្តោតលើសសរស្តម្ភពីរគឺ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។

ដើម្បីរួមចំណែកសម្រេចឱ្យបាននូវបំណងប្រាថ្នា និងចក្ខុវិស័យខាងលើ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំនូវផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ សម្រាប់អភិវឌ្ឍន៍ វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ គោលបំណងនៃការរៀបចំឯកសារនេះ គឺដើម្បីកំណត់អំពីយុទ្ធសាស្ត្ររបស់ក្រសួង ធានាឱ្យបាននូវសុខុមាលភាពសង្គមប្រកបដោយសុខដុម កាត់បន្ថយនូវភាពរងគ្រោះនិងងាយរងគ្រោះរបស់ប្រជាជន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនគ្រប់ស្រទាប់ សំដៅលើកកម្ពស់កម្រិតជីវភាពប្រជាជន ជាពិសេស ប្រជាជនក្រីក្រ ងាយរងគ្រោះ ជនពិការ កុមារកំព្រា អនីតិជន ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន អតីតយុទ្ធជន អតីតមន្ត្រីរាជការស៊ីវិល និងមនុស្សចាស់ជរា។ល។

ខ្ញុំជឿជាក់ថា ផែនការយុទ្ធសាស្ត្រនេះ នឹងក្លាយទៅជាផែនទីបង្ហាញផ្លូវសម្រាប់គ្រប់ប្រតិបត្តិករ និងអង្គភាពអនុវត្តដែលបាន កំពុង ឬ នឹងបំពេញបេសកកម្មក្នុងវិស័យសុខុមាលភាពសង្គម សំដៅសម្រេចឱ្យបាននូវមហិច្ឆិតារួមគ្នាមួយដូចមានចែងខាងលើ។ ខ្ញុំក៏សូមអំពាវនាវដល់អ្នកពាក់ព័ន្ធ អង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុក និងបរទេស ដៃគូអភិវឌ្ឍន៍ បន្តសហការ រួមចំណែកក្នុងការអនុវត្តផែនការនេះឱ្យទទួលបាននូវប្រសិទ្ធភាព ប្រសិទ្ធផល និងប្រកបដោយស្មារតីទទួលខុសត្រូវ។

ថ្ងៃ សុក្រ ១៤កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១៨

រដ្ឋមន្ត្រី

វង សូត

# តារាងមាតិកា


**អារម្ភកថា** ..... i

**តារាងមាតិកា** ..... iii

**បញ្ជីអក្សរបំព្រួញ** ..... vi

**បញ្ជីតារាង** ..... vii

**បញ្ជីរូបភាព** ..... viii

**ខ្លឹមសារសង្ខេប** ..... ix

**ជំពូកទី១**

**សេចក្តីផ្តើម**

**១.១.សាវតា និងបរិបទ** ..... ១

**១.២.ទំនាក់ទំនងរវាង ផ.យ.អ.ច. ជាមួយ ផ.យ.អ.ជ.** ..... ៣

**១.៣.ដំណើរការនៃការរៀបចំ ផ.យ.អ.ច.** ..... ៣

**១.៤.ទម្រង់របស់ ផ.យ.អ.ច.** ..... ៤

**ជំពូកទី២**

**លទ្ធផលសម្រេចបាន និងបញ្ហាប្រឈម**

ការងារអាទិភាពទី១៖ លើកកម្ពស់សុខុមាលភាពសង្គមនិងកិច្ចការគ្រួសារ ..... ៦

ការងារអាទិភាពទី២៖ លើកកម្ពស់សុខុមាលភាពកុមារនិងយុវនីតិសម្បទា ..... ៨

ការងារអាទិភាពទី៣៖ លើកកម្ពស់សុខុមាលភាពសម្រាប់ជនពិការ ..... ១២

ការងារអាទិភាពទី៤៖ លើកកម្ពស់សុខុមាលភាពមនុស្សចាស់ ..... ១៥

ការងារអាទិភាពទី៥៖ លើកកម្ពស់វិស័យអតីតមន្ត្រីរាជការស៊ីវិល ..... ១៨

ការងារអាទិភាពទី៦៖ លើកកម្ពស់វិស័យអតីតយុទ្ធជន ..... ២០

ការងារអាទិភាពទី៧៖ បង្កើតរបបសន្តិសុខសង្គមសម្រាប់ប្រជាជនទូទៅ ..... ២២

ការងារអាទិភាពទី៨៖ ពង្រឹងសមត្ថភាពស្ថាប័ននិងពង្រឹងភាពជាដៃគូ ..... ២២

**ជំពូកទី៣**

**ទិសដៅយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន**
**និងយុវនីតិសម្បទា**

**៣.១. ចក្ខុវិស័យ** ..... ២៥

**៣.២. បេសកកម្ម** ..... ២៥

**៣.៣. គោលបំណងយុទ្ធសាស្ត្រ** ..... ២៥

៣.៣.១.គោលបំណងគោលនយោបាយ ..... ២៥

៣.៣.២. គោលបំណងកម្មវិធី ........ ២៦

កម្មវិធីទី១៖ ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ........ ២៦

កម្មវិធីទី២៖ ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ........ ២៦

កម្មវិធីទី៣៖ ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍភាពជាដៃគូ........ ២៦

**៣.៤. កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ........ ២៧**

កម្មវិធីទី១៖ ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ........ ២៨

អនុកម្មវិធីទី១.១៖ ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ ........ ២៨

អនុកម្មវិធីទី១.២៖ ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា........ ៣០

អនុកម្មវិធីទី១.៣៖ ការអភិវឌ្ឍសុខុមាលភាពជនពិការ ........ ៣៣

អនុកម្មវិធីទី១.៤៖ ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់........ ៣៥

អនុកម្មវិធីទី១.៥៖ ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន ........ ៣៦

អនុកម្មវិធីទី១.៦៖ ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គមរាជធានី ខេត្ត ........ ៣៧

កម្មវិធីទី២៖ ការបង្កើនប្រសិទ្ធិភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ........ ៣៧

អនុកម្មវិធីទី២.១៖ ការអភិវឌ្ឍសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលប្រកបដោយប្រសិទ្ធភាព ៣៧

អនុកម្មវិធីទី២.២៖ ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធនិងគ្រួសារ ........ ៣៨

អនុកម្មវិធីទី២.៣៖ ការបន្តនិរន្តរភាពសេវាស្តារលទ្ធភាពពលកម្មជូនជនពិការ ........ ៣៩

កម្មវិធីទី៣៖ ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍភាពជាដៃគូ........ ៤១

អនុកម្មវិធីទី៣.១៖ ការពង្រឹងសមត្ថភាពស្ថាប័ននិងភាពជាដៃគូ ........ ៤១

អនុកម្មវិធីទី៣.២៖ ការអភិវឌ្ឍធនធានមនុស្ស........ ៤២

អនុកម្មវិធីទី៣.៣៖ ការពង្រឹងសមត្ថភាពមន្ទីរ និងអភិវឌ្ឍភាពជាដៃគូរាជធានី ខេត្ត ........ ៤៣


## ជំពូកទី៤
## ការរៀបចំស្ថាប័នសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ


**៤.១.ថ្នាក់ជាតិ ........ ៤៤**

**៤.២.ថ្នាក់រាជធានី ខេត្ត ........ ៤៦**

**៤.៣.តាគីពាក់ព័ន្ធ ........ ៤៦**

## ជំពូកទី៥
## យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទានសម្រាប់ផែនការយុទ្ធសាស្ត្រ

**៥.១. ថវិកាជាតិ** ........ ៤៧
**៥.២.ធនធានដៃគូអភិវឌ្ឍន៍** ........ ៤៧
**៥.៣. តម្រូវការថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ** ........ ៤៧

## ជំពូកទី៦
## ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

**៦.១.ត្រួតពិនិត្យតាមដាន** ........ ៤៩
**៦.២.ការវាយតម្លៃ** ........ ៤៩

## ជំពូកទី៧
## សេចក្តីសន្និដ្ឋាន

**សេចក្តីសន្និដ្ឋាន** ........ ៥០
**ឧបសម្ព័ន្ធ** ........ ៥១
**១.ម៉ាទ្រីចស្តីពីតម្រូវការចំណាយលើកម្មវិធី និងអនុកម្មវិធី** ........ ៥១
**២.ម៉ាទ្រីចស្តីពីតម្រូវឥណទានតាមប្រភេទចំណាយតាមកម្មវិធី និងអនុកម្មវិធី** ........ ៥៣
**៣.ម៉ាទ្រីចស្តីពីការតាមដានត្រួតពិនិត្យការអនុវត្ត** ........ ៥៤

# បញ្ជីអក្សរបំព្រួញ

| | |
|---|---|
| ក្រសួង ស.អ.យ. | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ក.ជ.ក. | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ក.ស.ជ. | ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| ប.ជ.ស. | បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល |
| ប.ជ.អ. | បេឡាជាតិអតីតយុទ្ធជន |
| ម.ជ.ព. | មូលនិធិជនពិការ |
| ផ.យ.អ.ជ. | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ផ.យ.អ.វ. | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ |
| គ.ជ.ប. | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត |

# បញ្ជីតារាង


តារាងទី១៖ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រ ........ ៤

តារាងទី២៖លទ្ធផលសម្រេចបានការងារអាទិភាពទី១ ........ ៧

តារាងទី៣៖លទ្ធផលសម្រេចបានការងារអាទិភាពទី២ ........ ១១

តារាងទី៤៖លទ្ធផលសម្រេចបានការងារអាទិភាពទី៣ ........ ១៤

តារាងទី៥៖លទ្ធផលសម្រេចបានការងារអាទិភាពទី៤ ........ ១៦

តារាងទី៦៖លទ្ធផលសម្រេចបានការងារអាទិភាពទី៥ ........ ១៩

តារាងទី៧៖លទ្ធផលសម្រេចបានការងារអាទិភាពទី៦ ........ ២១

តារាងទី៨៖លទ្ធផលសម្រេចបានការងារអាទិភាពទី៨ ........ ២៣

តារាងទី៩៖ចំណុចដៅនៃសូចនាករអនុកម្មវិធីទី១.១ ........ ២៩

តារាងទី១០៖ចំណុចដៅនៃសូចនាករអនុកម្មវិធីទី១.២ ........ ៣៣

តារាងទី១១៖ចំណុចដៅនៃសូចនាករអនុកម្មវិធីទី១.៣ ........ ៣៤

តារាងទី១២៖ចំណុចដៅនៃសូចនាករអនុកម្មវិធីទី១.៤ ........ ៣៦

តារាងទី១៣៖ចំណុចដៅនៃសូចនាករអនុកម្មវិធីទី២.១ ........ ៣៨

តារាងទី១៤៖ចំណុចដៅនៃសូចនាករអនុកម្មវិធីទី២.២ ........ ៣៩

តារាងទី១៥៖ចំណុចដៅនៃសូចនាករអនុកម្មវិធីទី២.៣ ........ ៤០

តារាងទី១៦៖ចំណុចដៅនៃសូចនាករអនុកម្មវិធី៣.២ ........ ៤៣

តារាងទី១៧៖តម្រូវការថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ២០១៩-២០២៣ ........ ៤៨

# បញ្ជីរូបភាព


រូបទី១៖ ភាគរយប៉ាន់ស្មាននិងព្យាករណ៍ នៃប្រជាជនវ័យចាស់ធៀបនឹងប្រជាជនសរុប ................ ១៧

រូបទី២៖ ថវិកាដ្ឋដែលបានវិភាជន៍រយៈពេល៥ឆ្នាំ ២០១៤-២០១៨ ........................................... ២៤

រូបទី៣៖ គំនូសបំព្រួញផែនការយុទ្ធសាស្ត្រ ........................................................................ ២៧

# ខ្លឹមសារសង្ខេប

ការរៀបចំឯកសារនេះ គឺដើម្បីកំណត់អំពីយុទ្ធសាស្ត្ររបស់ក្រសួង ធានាឱ្យបាននូវសុខុមាលភាពសង្គមប្រកបដោយសុខដុម កាត់បន្ថយនូវភាពងាយរងគ្រោះនិងងាយរងគ្រោះរបស់ប្រជាជន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនគ្រប់ស្រទាប់ សំដៅលើកកម្ពស់កម្រិតជីវភាពប្រជាជន ជាពិសេស ប្រជាជនក្រីក្រ ងាយរងគ្រោះ ជនពិការ កុមារកំព្រា អនីតិជន ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន អតីតយុទ្ធជន អតីតមន្ត្រីរាជការស៊ីវិល និងមនុស្សចាស់ជរា ។ល។ ឯកសារនេះ គឺបន្ស៊ី ប្រមូលផ្តុំ ពង្រឹងកម្មវិធីដែលមានស្រាប់ និងការប្រែក្លាយសកម្មភាពពីការផ្តល់សេវាដែលមានចរិតជាការផ្តល់ជំនួយដោយអន្តរាគមន៍ ទៅជាកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជាបណ្តើរៗ ឆ្លើយតបទៅតាមបំណងប្រាថ្នា និងតម្រូវការជាក់ស្តែងរបស់ប្រជាជន។

ផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ គឺជាផែនទីបង្ហាញផ្លូវដែលផ្តោតលើកម្មវិធីសំខាន់ៗចំនួនបី គឺ១.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ២.ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គមនិងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ និង៣.ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍភាពជាដៃគូ។ ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គមមានអនុកម្មវិធីចំនួនប្រាំមួយ រួមមាន ១.ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ ២.ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា ៣.ការអភិវឌ្ឍសុខុមាលភាពជនពិការ ៤.ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់ ៥.ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន និង៦.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គមរាជធានី ខេត្ត។ ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គមនិងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ មានអនុកម្មវិធីចំនួនបីគឺ ១.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ២.ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ៣.ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ។ ដោយឡែក ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍភាពជាដៃគូមានបីអនុកម្មវិធីគឺ ១.ការពង្រឹងសមត្ថភាពស្ថាប័ននិងភាពជាដៃគូ ២.ការអភិវឌ្ឍធនធានមនុស្ស និង៣.ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូរាជធានី ខេត្ត។

ផែនការយុទ្ធសាស្ត្រនេះ ត្រូវការថវិកាវិភាជន៍ពីរដ្ឋប្រមាណ ៦.៤៩៣.៤៧០លានរៀល និងការចូលរួមចំណែកពីដៃគូអភិវឌ្ឍន៍ប្រមាណ ១៨០លានដុល្លារអាមេរិក សម្រាប់អនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ដើម្បីសម្រេចបាននូវចំណុចដៅនៃសូចនាករដែលបានលើកនៅក្នុងផែនការយុទ្ធសាស្ត្រនេះ។

ឯកសារនេះមានភាពទន់ភ្លន់ និងអាចកែសម្រួលបាន អាស្រ័យលើស្ថានភាពវិវត្តន៍នៃសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយ ដើម្បីឆ្លើយតបទៅបញ្ហានានាដែលកើតមានឡើងក្នុងអំឡុងពេលអនុវត្តជាក់ស្តែងសំដៅបន្ស៊ីនឹងស្ថានភាពប្រែប្រួលនោះ ព្រមទាំងបង្កើនប្រសិទ្ធភាពការងារឱ្យកាន់តែប្រសើរឡើង។

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១. សាវតា និងបរិបទ

ក្នុងរយៈពេល២ទសវត្សរ៍កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបានទទួលជោគជ័យយ៉ាងត្រចះត្រចង់ក្នុងការស្តារ និងអភិវឌ្ឍប្រទេសជាតិឡើងវិញ។ បន្ទាប់ពីរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយឈ្នះឈ្នះ សន្តិភាពពេញលេញត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៨ អង្គការចាត់តាំងរបស់ខ្មែរក្រហមត្រូវបានបញ្ចប់ ។ សន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខជាតិដែលជាបុរេលក្ខខណ្ឌដ៏ចាំបាច់ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ ការលើកកម្ពស់ជីវភាពរស់នៅ និងសេចក្តីថ្លៃថ្នូរបស់ប្រជាជន។ ប្រជាជនកម្ពុជាបាននឹងកំពុងទទួលផ្លែផ្កាពីសេចក្តីសុខសន្តិភាព ស្ថិរភាពនយោបាយ និងកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក្នុងអត្រាមធ្យមប្រមាណ ៧,៧% នាអំឡុងពេលពីរទសវត្សរ៍កន្លងមកនេះ។ អត្រាភាពក្រីក្រត្រូវបានកាត់បន្ថយពី៥៣,២%នៅឆ្នាំ២០០៤ មកត្រឹម ១៣,៥% នៅឆ្នាំ២០១៤ និងបន្តធ្លាក់ចុះក្រោម១០% នៅឆ្នាំ២០១៨ ចំណូលមនុស្សម្នាក់បានកើនពី ៥៩០ដុល្លារអាម៉េរិកនៅឆ្នាំ២០០៧ ដល់រង្វង់ ១.៥៦០ដុល្លារអាម៉េរិកនៅឆ្នាំ២០១៨។ កន្លងមក រាជរដ្ឋាភិបាលបានខិតខំដាក់ឱ្យដំណើរការ និងទ្រទ្រង់គោលនយោបាយសង្គមកិច្ចជាច្រើន។ តាមរយៈនេះ ប្រជាជនកម្ពុជា ជាពិសេស ប្រជាជនក្រីក្រ និងងាយរងគ្រោះទទួលបាននូវការគាំពារគ្រប់រូបភាពក្នុងក្របខ័ណ្ឌនៃការងារគាំពារសង្គម។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានអាយុកាលដ៏យូរលង់ គឺបានចាប់កំណើតតាំងពីក្នុងសម័យសង្គមរាស្ត្រនិយម តែត្រូវបានផ្លាស់ប្តូរឈ្មោះជាបន្តបន្ទាប់ទៅតាមសម័យកាលដែលផ្លាស់ប្តូរនីមួយៗ លើកលែងតែក្នុងសម័យរបបប្រល័យពូជសាសន៍ ដែលស្ថាប័នរដ្ឋទាំងអស់ស្ទើរតែលុបបំបាត់ទាំងស្រុង។ ឯកសារដែលពាក់ព័ន្ធនឹងការវិវត្តរីកចម្រើននៃវិស័យសង្គមកិច្ចស្ទើរតែត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង រហូតដល់ឆ្នាំ១៩៩៥ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ និងដាក់ចេញនូវកម្មវិធីជាតិលើកទី១ ដែលមានឈ្មោះថា កម្មវិធីជាតិសម្រាប់ស្តារ និងអភិវឌ្ឍន៍កម្ពុជាសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចឆ្នាំ១៩៩៦-២០០០ និងឆ្នាំ២០០១ រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ចេញនូវផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច ៥ឆ្នាំលើកទី២ ២០០១-២០០៥ ដោយផ្តោតលើកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ដែលកាលនោះ ក្រសួងសង្គមកិច្ច មានឈ្មោះថា ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ដឹកនាំដោយរដ្ឋលេខាធិការ ដែលមានបេសកកម្ម គឺជានាវ៉ាប់រងចំពោះសុខុមាលភាពសង្គមនៃក្រុមជនរងគ្រោះ និងងាយរងគ្រោះបំផុតក្នុងសង្គមកម្ពុជា និងការអភិវឌ្ឍគោលនយោបាយមុខរបរ ដោយការបង្កើតសុវត្ថិភាពការងារ និងសម្របសម្រួលទំនាក់ទំនងឧស្សាហកម្ម ឱ្យស្របទៅតាមច្បាប់ស្តីពីការងារ។ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ត្រូវបានប្តូរឈ្មោះទៅជាក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដែលបានប្រកាសដាក់ចេញនូវទស្សនៈវិស័យសម្រាប់រយៈពេល ៥ឆ្នាំ ១៩៩៨-២០០៣ របស់ខ្លួន មានគោលដៅចម្បងចំនួន ៤ គឺ ១.ចូលរួមចំណែកក្នុងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការងារសុខុមាលភាពសង្គម ដោយផ្តល់សេវាកម្មទ្រទ្រង់សង្គមដ៏សមស្របដល់ក្រុមជនដែលងាយរងគ្រោះ និងការងារត្រួតពិនិត្យការអនុវត្តដ៏មានប្រសិទ្ធភាព ២.ធ្វើផែនការសកម្មភាព

ដើម្បីអភិវឌ្ឍន៍ធនធានមនុស្សដែលមានសមត្ថភាព មុខជំនាញបច្ចេកទេសសមស្របទៅតាមសេចក្តីត្រូវការនៃផ្នែកឧស្សាហកម្ម ការរីកចម្រើននៃបច្ចេកវិទ្យា និងកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ៣.រួមចំណែកក្នុងនយោបាយរបស់រាជរដ្ឋាភិបាល ដោយអនុលោមតាមអនុសញ្ញាអន្តរជាតិទាំងឡាយ ក្នុងកិច្ចការពារផលប្រយោជន៍របស់កម្មករនិយោជិត ដោយធ្វើបរិយាកាសទំនាក់ទំនងល្អរវាងកម្មករ និយោជិត និងបណ្តាអង្គការវិជ្ជាជីវៈរបស់ពួកគេជាមួយនិយោជក និងសមាគមវិជ្ជាជីវៈរបស់និយោជក តាមច្បាប់ ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិជាធរមាន តាមរយៈ គណៈកម្មការត្រីភាគី រដ្ឋ និយោជក និយោជិត និង៤.រួមចំណែកក្នុងនយោបាយមុខរបររបស់រាជរដ្ឋាភិបាល ដោយកិច្ចសហការជាប្រចាំ ធ្វើឱ្យមានប្រសិទ្ធភាពកើនឡើងនៃសង្វាក់ផលិតកម្ម និងគុណភាពរបស់កម្លាំងពលកម្មដែលអាចឱ្យសេដ្ឋកិច្ចរបស់កម្ពុជាឈានទៅប្រកួតប្រជែងជាមួយសេដ្ឋកិច្ចនៃបណ្តាប្រទេសក្នុងតំបន់ និងលើកកម្ពស់កម្រិតស្ថានភាពសង្គមកិច្ចរបស់ក្រុមមុខសញ្ញា ឱ្យសមស្របតាមការរីកចម្រើននៃស្ថានភាពប្រទេសជាតិ។

ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំលើកទី៣សម្រាប់ឆ្នាំ២០០៦-២០១០ របស់រាជរដ្ឋាភិបាល ត្រូវបានរៀបចំឡើង ដោយបានបញ្ចូលនូវឯកសារគោលនយោបាយជាតិនានា ដើម្បីសម្រេចឱ្យបាននូវគោលដៅអាទិភាព ចំណុចដៅ និងសកម្មភាពសម្រាប់រយៈពេលប្រាំឆ្នាំបន្ទាប់។ ផែនការនេះ ត្រូវបានប្តូរឈ្មោះទៅជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០០៦-២០១០ និងជាផែនការជាតិតែមួយគត់ ដែលគ្របដណ្តប់គ្រប់វិស័យសម្រាប់អនុវត្តរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល និងយុទ្ធសាស្ត្រចតុកោណដែលជាយុទ្ធសាស្ត្របន្តពីយុទ្ធសាស្ត្រត្រីកោណ។

បន្ទាប់ពីការបោះឆ្នោតសកលឆ្នាំ២០០៨ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសពីកម្មវិធី គោលនយោបាយសង្គម សេដ្ឋកិច្ចសម្រាប់នីតិកាលទី៤នៃរដ្ឋសភាឆ្នាំ២០០៨-២០១៣។ ជាមួយនឹងកម្មវិធីនយោបាយនេះ ផែនការជាតិថ្មីមួយត្រូវបានរៀបចំជំនួស ផ.យ.អ.ជ. ២០០៦-២០១០ ដើម្បីបន្សុំដំណើរការនៃការរៀបចំផែនការជាមួយអាណត្តិកាលរបស់រាជរដ្ឋាភិបាល។ ផែនការថ្មីនេះឈ្មោះថា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ដែលជាឧបករណ៍អនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។

ចាប់ពីឆ្នាំ២០០៣ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវបានប្តូរឈ្មោះទៅជាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ក្នុងរយៈពេលនោះ ក្រសួង ស.អ.យ. បានរៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីការងារ និងផែនការយុទ្ធសាស្ត្រចំនួន ៣ដង រួមមាន៖ ***ទី១.កម្មវិធីការងារ ២០០៤-២០០៨*** ដោយផ្តោតលើការងារអាទិភាពចំនួន ៦ចំណុច រួមមាន៖ ពង្រីកសេវាសង្គមកិច្ច និងកម្មវិធីសង្គ្រោះបន្ទាន់ ការងារសុខុមាលភាពកុមារនិងយុវនីតិសម្បទា ការងារពិការភាពនិងស្តារលទ្ធភាពពលកម្ម ការងារសោធនមន្ត្រីរាជការស៊ីវិល ការងារអតីតយុទ្ធជន និងអភិបាលកិច្ចល្អ ***ទី២.កម្មវិធីការងាររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់ឆ្នាំ២០០៨-២០១៣*** ដោយប្រមូលផ្តុំអនុវត្តលើការងារអាទិភាព ៦ចំណុចធំហានថ្មី ដូចជា៖ ពង្រឹង ពង្រីកសេវាសុខុមាលភាពសង្គមសម្រាប់ជនក្រីក្រងាយរងគ្រោះ ពង្រឹង ពង្រីកសេវាសុខុមាលភាពកុមារនិងយុវនីតិសម្បទា ពង្រឹង ពង្រីកសេវាសុខុមាលភាពជនពិការ និងស្តារលទ្ធភាពពលកម្ម ពង្រឹង ពង្រីករបបសន្តិសុខសង្គម សុខុមាលភាពមនុស្ស

ចាស់ មន្ត្រីរាជការស៊ីវិល និងប្រជាជនទូទៅ ពង្រឹង ពង្រីករបបសន្តិសុខសង្គម និងសុខុមាលភាពនៃអតីតយុទ្ធជន និង***ទី៣.ផែនការយុទ្ធសាស្ត្រឆ្នាំ២០១៤-២០១៨*** ដោយផ្តោតលើយុទ្ធសាស្ត្រ៣យ៉ាង និងកម្មវិធីអាទិភាព ៨ចំណុចជំហានទី៣ គឺ (ក).យុទ្ធសាស្ត្រ៣យ៉ាង រួមមាន (១). បង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម (២). ពង្រឹងពង្រីកប្រព័ន្ធសន្តិសុខសង្គម និង(៣).ពង្រឹងសមត្ថភាពស្ថាប័ន និងកៀរគរប្រភពធនធានទាំងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ និង(ខ).កម្មវិធីអាទិភាព ៨ចំណុច គឺ (១).អភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ (២).អភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា (៣).អភិវឌ្ឍសុខុមាលភាពជនពិការ (៤).អភិវឌ្ឍសុខុមាលភាពមនុស្សចាស់ (៥). អភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (៦).អភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន (៧).សិក្សាស្រាវជ្រាវបង្កើតប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់ប្រជាជនកម្ពុជា និង(៨).អភិវឌ្ឍសមត្ថភាពស្ថាប័ន និងពង្រឹងភាពជាដៃគូ។

បើពិនិត្យមើលពីក្របខ័ណ្ឌពេលវេលារវាងកម្មវិធីការងារ ផែនការយុទ្ធសាស្ត្ររបស់ក្រសួង ស.អ.យ. ហាក់មិនមានសង្គតិភាពទាំងស្រុង ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា នូវបណ្តាឆ្នាំមុនៗ រហូតដល់ពេលរាជរដ្ឋាភិបាលបានធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនៅឆ្នាំ ២០០៨ ដែលបង្កើតបាននូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិថ្មីមានឈ្មោះថា ផ.យ.អ.ជ. បច្ចុប្បន្នកម្ម ២០០៩-២០១៣ ទើបផែនការយុទ្ធសាស្ត្ររបស់ក្រសួងអាចបន្សុំ និងមានសង្គតិភាពជាមួយ ផ.យ.អ.ជ. របស់រាជរដ្ឋាភិបាល។

## ១.២.ទំនាក់ទំនងរវាង ផ.យ.អ.ស. ជាមួយ ផ.យ.អ.ជ.

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ២០១៩-២០២៣ មានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីប្រចាំឆ្នាំរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៥-២០៣០។ ផែនការយុទ្ធសាស្ត្រនេះជាផែនទីតម្រង់ផ្លូវឱ្យក្រសួង និងអ្នកពាក់ព័ន្ធរៀបចំផែនការសកម្មភាព ដើម្បីធ្វើឱ្យសម្រេចបាននូវចំណុចដៅនៃសូចនាករដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ២០១៩-២០២៣ របស់ក្រសួង។

## ១.៣.ដំណើរការនៃការរៀបចំ ផ.យ.អ.ស.

ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួង ស.អ.យ. បានចេញប្រកាសលេខ ១០១០ស.អ.យ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រឆ្នាំ២០១៩-២០២៣ របស់ក្រសួង។ ប្រកាសនេះកំណត់អំពីភារកិច្ចរបស់ក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រ និងក្រុមការងារបច្ចេកទេសត្រូវរៀបចំផែនការយុទ្ធសាស្ត្រនេះ នៅចន្លោះខែតុលា ឆ្នាំ២០១៧ ដល់ខែតុលា ឆ្នាំ២០១៨ទៅតាមដំណាក់កាលនីមួយៗដូចខាងក្រោម៖

តារាងទី១.ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រ

| ដំណាក់កាល | បរិយាយ | ពេលវេលា |
|---|---|---|
| ១ | ការវិភាគវិស័យ | ៣សប្តាហ៍ |
| ២ | ការរៀបចំគោលនយោបាយរបស់វិស័យ | ៣សប្តាហ៍ |
| ៣ | ការជ្រើសរើសគោលបំណងនិងអាទិភាពរបស់វិស័យ | ២សប្តាហ៍ |
| ៤ | ការរៀបចំកម្មវិធី និងអនុកម្មវិធី | ២សប្តាហ៍ |
| ៥ | ការរៀបចំការប៉ាន់ស្មានចំណាយនិងក្របខ័ណ្ឌហិរញ្ញប្បទាន | ២សប្តាហ៍ |
| ៦ | ការរៀបចំប្រព័ន្ធតាមដាន | ២សប្តាហ៍ |
| ៧ | ការរៀបចំសេចក្តីព្រាង | ២សប្តាហ៍ |
| ៨ | ការកែសម្រួលសេចក្តីព្រាង | ៤សប្តាហ៍ |
| ៩ | ការអនុម័ត និងការផ្សព្វផ្សាយ | ៤សប្តាហ៍ |

## ១.៤. ទម្រង់របស់ ផ.យ.អ.វ.

ឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបានរៀបចំឡើងដោយផ្អែកតាមការណែនាំរបស់ក្រសួងផែនការ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ដែលបានបែងចែកជា៧ជំពូកដូចខាងក្រោម៖

ជំពូកទី១ បង្ហាញជូនពីសាវតា អាទិភាពសម្រាប់ការអភិវឌ្ឍក្នុងវិស័យ ទំនាក់ទំនងរវាង ផ.យ.អ.វ. ជាមួយ ផ.យ.អ.ជ. បេសកកម្មនិងគោលបំណងយុទ្ធសាស្ត្ររបស់វិស័យ ដំណើរការនៃការរៀបចំ ផ.យ.អ.វ. និងទម្រង់របស់ ផ.យ.អ.វ.។

ជំពូកទី២ ការវិភាគស្ថានភាព បង្ហាញជូនអំពីសមិទ្ធផល និងបញ្ហាប្រឈមនានា។

ជំពូកទី៣ ទិសដៅយុទ្ធសាស្ត្ររបស់វិស័យ បង្ហាញជូនអំពីចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួង គោលបំណងយុទ្ធសាស្ត្រ អាទិភាពរបស់វិស័យបែងចែកតាមកម្មវិធី និងអនុកម្មវិធី សង្គតិភាពរវាង ផ.យ.អ.វ. ជាមួយ ផ.យ.អ.ជ. និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និងអាទិភាពអន្តរវិស័យ។

ជំពូកទី៤ ការរៀបចំស្ថាប័ន បង្ហាញជូនអំពី ការរៀបចំសម្របសម្រួលការអនុវត្ត ផ.យ.អ.វ. ក្នុងក្រសួង និងអន្តរក្រសួង ការរៀបចំប្រកបដោយចីរភាព។

ជំពូកទី៥ យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទានសម្រាប់ ផ.យ.អ.វ. បង្ហាញជូនអំពីផែនការថវិកា រួមបញ្ចូលទាំងការប៉ាន់ស្មានហិរញ្ញប្បទានលើថវិកាជាតិ និងថវិកាពីដៃគូអភិវឌ្ឍន៍ ធនធានដែលត្រូវការ និងយុទ្ធសាស្ត្រកៀរគរបន្ថែម ការប៉ាន់ស្មានចំណាយប្រចាំឆ្នាំ ទំនាក់ទំនងផែនការហិរញ្ញវត្ថុរបស់វិស័យជាមួយចំណាយប៉ាន់ស្មានរបស់ ផ.យ.អ.ជ. និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ចំណាយរបស់ ផ.យ.អ.វ. នីមួយៗ ដោយផ្អែកលើការចំណាយប៉ាន់ស្មានច្បាស់លាស់។

ជំពូកទី៦ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ បង្ហាញជូនអំពីកាលបរិច្ឆេទនៃកិច្ចប្រជុំផ្ទៃក្នុងក្រសួង ដើម្បីវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តផែនការ កាលបរិច្ឆេទនៃការវាយតម្លៃប្រចាំឆ្នាំ កាលបរិច្ឆេទនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ និងកាលបរិច្ឆេទនៃការវាយតម្លៃបញ្ចប់អាណត្តិ។

ជំពូកទី៧ សេចក្តីសន្និដ្ឋាន បង្ហាញជូនអំពីការសន្និដ្ឋានរួមរបស់ផែនការយុទ្ធសាស្ត្រនេះ។

# ជំពូកទី២
# លទ្ធផលសម្រេចបាន និងបញ្ហាប្រឈម

## ការងារអាទិភាពទី១៖ លើកកម្ពស់សុខុមាលភាពសង្គមនិងកិច្ចការគ្រួសារ

- បានបង្កើត និងអនុវត្តកម្មវិធីសង្គ្រោះបន្ទាន់ដោយមានកិច្ចសហការជាមួយកាកបាទក្រហមកម្ពុជា និងអង្គការនានាសម្រាប់ជួយប្រជាជនក្រីក្រ ទុរគតជន ប្រជាជនរងគ្រោះដោយគ្រោះធម្មជាតិ រងគ្រោះដោយគ្រោះមហន្តរាយផ្សេងៗ ដែលក្នុងរយៈពេល៥ឆ្នាំ ជនរងគ្រោះប្រមាណ៣៧៣.៩៥២គ្រួសារ ត្រូវបានជួយសង្គ្រោះ សម្រាលស្ថានភាពលំបាក ដោយបង្គលក្ខណសម្បត្តិសម្រាប់ការស្តារជីវភាពឡើងវិញ។ បានផ្សព្វផ្សាយ អប់រំ បញ្ជ្រាបការយល់ដឹងស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់អាជ្ញាធរមូលដ្ឋាននិងប្រជាជនចំនួន៥២៦.៥៧៥នាក់
- បានសង្គ្រោះ អប់រំផ្លូវចិត្ត ពិគ្រោះយោបល់ ថែទាំសុខភាពជូនជនអនាថាសរុបចំនួន៧.៦៣៣នាក់ ក្រៅពីទទួលបានសេវាខាងលើ ជនអនាថាចំនួន៧.១៤៥នាក់ បានទទួលសេវាស្តារនីតិសម្បទា បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍។ បានសាងសង់អគារមជ្ឈមណ្ឌលព្យាបាល និងថែទាំជនវិបល្លាសស្មារតី ដែលនឹងដាក់ឱ្យដំណើរការក្នុងឆ្នាំ២០១៩ខាងមុខ
- បានផ្តល់សេវាថែទាំ និងគាំទ្រនៅសហគមន៍ដល់ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗបានចំនួន១៩.៧៧៩នាក់ ក្នុងនោះ មានការអប់រំផ្សព្វផ្សាយ វគ្គបំណិនជីវិត អប់រំសុខភាព សេវាប្រឹក្សាយោបល់ និងការបង្កើតមុខរបរខ្នាតតូចដល់គ្រួសារ និងកុមារដែលរងផលប៉ះពាល់ដោយសារជំងឺអេដស៍
- បានបង្កើត និងអនុវត្តកម្មវិធី ស្តីពីការអភិវឌ្ឍគ្រួសារ បំផុសលើកទឹកចិត្តការកសាងគ្រួសារល្អ ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ តាមរយៈការរៀបចំទិវាជាតិ និងអន្តរជាតិ ស្តីពីគ្រួសារ ១៥ឧសភា ជារៀងរាល់ឆ្នាំ។ បានបញ្ជ្រាបការងារយេនឌ័រទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើកកម្ពស់តួនាទីស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត តាមរយៈការផ្សព្វផ្សាយទស្សនទានយេនឌ័រ និងអនុសញ្ញា ស៊ី-ដ (CEDAW) ដល់មន្ត្រីបង្គោលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការផ្សព្វផ្សាយការយល់ដឹងស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារដល់សហគមន៍
- បានរៀបចំ និងដាក់ឱ្យអនុវត្តនូវបទដ្ឋានអប្បបរមា សម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល និងឧបករណ៍ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយនិងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មជួញដូរមនុស្ស និងសង្គ្រោះជនរងគ្រោះ។ តាមរយៈគោលនយោបាយនិងបទដ្ឋាននេះ ជនរងគ្រោះដោយអំពើជួញដូរមនុស្សប្រមាណ២.៩០០នាក់ ស្រី២.១១៣នាក់ ត្រូវបានសង្គ្រោះ អប់រំប្រឹក្សាយោបល់ បញ្ជូនទៅស្តារនីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមមណ្ឌលរបស់អង្គការ និងជនរងគ្រោះចំនួន៧៤៣នាក់ ត្រូវធ្វើសមាហរណកម្មទៅសហគមន៍ និងតាមដានបន្តចំនួន១៣១នាក់។ ទន្ទឹមនោះ បានកសាងមណ្ឌលសំចតប៉ោយប៉ែតសម្រាប់ទទួលទុកដាក់ជនរងគ្រោះដែលទទួលបានពីអាជ្ញាធរ និងភាគីថៃ

- បានធ្វើមាតុភូមិនិវត្តន៍ស្ត្រីជនជាតិវៀតណាមរងគ្រោះដោយអំពើជួញដូរមនុស្ស៣៧នាក់ និងទទួល ១.៤៦០៨នាក់ ស្រី៥៨៤នាក់ ក្នុងនោះ ពីប្រទេសវៀតណាម ៥៨៥នាក់ ថៃ ២១៤នាក់ ម៉ាឡេស៊ី ២០៨ នាក់ សិង្ហបុរី ០១នាក់ ឥណ្ឌូនេស៊ី ២៥៤នាក់ សូម៉ាលី ៣៩នាក់ ចិន ១៥៤នាក់ អារ៉ាប់ប៊ីសាអូឌីត ០៣នាក់ និងជប៉ុន ០៦នាក់។

តារាងទី២.លទ្ធផលសម្រេចបានការងារអាទិភាពទី១

| ល.រ | សូចនាករ | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | 2014 | 2015 | 2016 | 2017 | 2018 | |
| 1 | ជនរងគ្រោះនិងងាយរងគ្រោះត្រូវបានទទួលជំនួយសង្គ្រោះបន្ទាន់ (គ្រួសារ) | 32,212 | 178,538 | 43,580 | 62,476 | 57,146 | 373,952 |
| 2 | ជនអនាថាបានទទួលសេវាដោះស្រាយបញ្ហាទប់ស្កាត់និងការពារ (នាក់) | 544 | 2,437 | 884 | 1,727 | 2,041 | 7,633 |
| 3 | ជនអនាថាដែលធ្វើសមាហរណកម្មទៅគ្រួសារ និង សហគមន៍វិញ (នាក់) | 56 | 2,437 | 884 | 1,244 | 2,524 | 7,145 |
| 4 | ជនផ្ទុកមេរោគអេដស៍/ជំងឺអេដស៍និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺកាចសាហាវផ្សេងៗនៅតាមសហគមន៍ទទួលបានសេវាប្រឹក្សា ថែទាំ គាំទ្រ (នាក់) | 2,264 | 6,748 | 3,724 | 2,758 | 4,285 | 19,779 |
| 5 | ជនរងគ្រោះដោយអំពើជួញដូរមនុស្សធ្វើសមាហរណកម្មទៅគ្រួសារ និងសហគមវិញ (នាក់) | 146 | 47 | 58 | 147 | 345 | 743 |
| 6 | ជនរងគ្រោះដោយអំពើជួញដូរមនុស្សទទួលបានសេវាពិគ្រោះយោបល់ និងស្តារនីតិសម្បទា (នាក់) | 279 | 598 | 455 | 720 | 848 | 2,900 |

**បញ្ហាប្រឈម៖**

- វិសាលភាពគ្របដណ្តប់នៃកម្មវិធីជាតិជំនួយសង្គម នៅមិនទាន់ទូលំទូលាយនិងគ្របដណ្តប់ពេញលេញ ដែលធ្វើឱ្យក្រុមប្រជាជនមួយចំនួន មិនទាន់ទទួលបានការគាំពារ
- ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណ និងអត្រានុកូលដ្ឋានប្រជាជនទូទៅ ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប្រជាជនក្រីក្រនិងងាយរងគ្រោះ និងប្រព័ន្ធចុះបញ្ជីរបស់ស្ថាប័នប្រតិបត្តិករនៅមិនទាន់បានតភ្ជាប់គ្នា ដែលនាំឱ្យមានការត្រួតគ្នាលើការកំណត់អត្តសញ្ញាណ និងការចុះបញ្ជី និងការផ្តល់អត្ថប្រយោជន៍ត្រួតគ្នាផងដែរ
- ការយល់ដឹងអំពីប្រព័ន្ធគាំពារសង្គម ដូចជាអត្ថប្រយោជន៍ និងកាតព្វកិច្ចក្នុងការចូលរួមរបស់ប្រជាជននៅក្នុងរបប ឬកម្មវិធីនីមួយៗនៅមានកម្រិត[1]។ ការពង្រឹងសមត្ថភាពមន្ត្រីក៏ជាតម្រូវការចាំបាច់ដែលត្រូវបង្កើនឱ្យស្របតាមស្ថានភាព និងតម្រូវការជាក់ស្តែង

1 ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ទំព័រ xiv

- ខណៈដែលគុណភាពនៃសេវាសុខាភិបាលត្រូវបានពង្រឹង ការលើកកម្ពស់អាហារូបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះនិងកុមារនៅមិនទាន់មានវឌ្ឍនភាពខ្លាំងក្លានៅឡើយ។ លទ្ធផលនៃការអង្កេតសុខភាព និងប្រជាសាស្ត្រឆ្នាំ២០១៤បង្ហាញថា កុមារក្រោមអាយុ៥ឆ្នាំប្រមាណ៣២% មានបញ្ហាកម្ពស់ (ក្រិន) ១០% មានភាពស្គមស្គាំង និង ២៤% មានទម្ងន់មិនគ្រប់។ ស្ត្រីមានផ្ទៃពោះ និងកុមារក្រោមអាយុ ៥ឆ្នាំ មកពីគ្រួសារក្រីក្រងាយនឹងជួបប្រទះបញ្ហាកង្វះអាហារូបត្ថម្ភ ដោយសារកង្វះធនធានហិរញ្ញវត្ថុ និងព័ត៌មាន ដែលចាំបាច់ដើម្បីទទួលសេវាថែទាំសុខភាព និងរបបអាហារូបត្ថម្ភព្រមទាំង ទឹកស្អាត និងអនាម័យផងដែរ[2]
- ឆ្នាំ២០១៤ អត្រានៃភាពក្រីក្រមាន ១៣,៥% ស្មើប្រមាណ២លាននាក់ ជាក់ស្តែង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានសហការជាមួយសប្បុរសជន កាកបាទក្រហមកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ជួយសង្គ្រោះ និងផ្តល់ជំនួយសង្គ្រោះបន្ទាន់ប្រមាណ ៣៨១.៦០៦នាក់ ស្មើ១៧,៨៩% នៃគ្រួសារក្រីក្រសរុបតែប៉ុណ្ណោះ។ ចំពោះមុខ ក្រសួងត្រូវខិតខំបន្ត និងយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីជួយដល់ជនរងគ្រោះនិងងាយរងគ្រោះ តាមកម្មវិធីកិច្ចគាំពារសង្គម
- ការពង្រឹងកម្មវិធីអភិវឌ្ឍន៍គ្រួសារនៅមានកម្រិត ដោយខ្វះការចូលរួមរបស់គ្រប់ភាគីពាក់ព័ន្ធ
- របបឧបត្ថម្ភសម្រាប់ជនរងគ្រោះស្នាក់នៅបណ្តោះអាសន្នក្នុងមណ្ឌលរយៈពេលតិចជាង៣០ថ្ងៃ គឺជួបការលំបាកក្នុងការអនុវត្តតាមស្មារតីនៃអនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ដែលបានកែសម្រួលមាត្រា៧នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ និងអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ ពីព្រោះពេលវេលាខ្លីពេក មិនគ្រប់គ្រាន់ក្នុងការចេញប្រកាសទទួលស្គាល់ជនរងគ្រោះដែលស្នាក់នៅក្នុងមណ្ឌល
- ស្ថានភាពរងគ្រោះរបស់ប្រជាជនមានលក្ខណៈមិនដូចគ្នា ដែលធ្វើឱ្យមានការលំបាកក្នុងការធ្វើអន្តរាគមន៍សង្គ្រោះទៅតាមស្ថានភាពជាក់ស្តែង
- ការផ្តល់សេវាគាំទ្រដល់ជនអនាថាជួបការលំបាក ដោយសមត្ថកិច្ចក្នុងការប្រមូលជនអនាថាជាសមត្ថកិច្ចរបស់គណៈបញ្ជាការឯកភាពរាជធានី ខេត្ត មិនមែនជាសមត្ថកិច្ចរបស់ក្រសួង និងមន្ទីរ ស.អ.យ.។ លើសពីនេះ ជនអនាថាទាំងបីប្រភេទ ( ១.ជនអនាថាដែលរស់នៅក្នុងខេត្ត ២.ជនអនាថាដែលមានមេខ្យល់ដឹកនាំ និង ៣.ជនអនាថាដែលចំណាកស្រុកពីតំបន់ផ្សេង ) តែងតែបំលាស់ទីមិនទៀងទាត់ពីតំបន់មួយទៅតំបន់មួយ ដែលទាមទារឱ្យមានយុទ្ធសាស្ត្រនិងវិធានការដោះស្រាយផ្សេងៗគ្នា។ ទន្ទឹមនេះ ក្រសួងពុំទាន់មានប្រព័ន្ធទិន្នន័យសម្រាប់គ្រប់គ្រងព័ត៌មាន ស្តីពីចំនួននិងអត្តសញ្ញាណជនអនាថានៅឡើយ។

## ការងារអាទិភាពទី២៖ លើកកម្ពស់សុខុមាលភាពកុមារនិងយុវនីតិសម្បទា

- ក្រសួងបានរៀបចំទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារនិងទិវាកុមារកម្ពុជាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

[2] ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ទំព័រ ១៥

- បានពង្រឹងពង្រីកយន្តការតាមដាន និងអនុវត្តសិទ្ធិកុមារ តាមក្រសួង ស្ថាប័ន និងរាជធានី ខេត្ត និងបានចេញគោលការណ៍ណែនាំស្តីពីការអនុវត្តអនុសាសន៍របស់អង្គការសហប្រជាជាតិ ស្តីពីការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិកុមារ
- បានជំរុញ និងលើកកម្ពស់ការអនុវត្តសិទ្ធិកុមារតាមរយៈការពង្រឹងសមត្ថភាពមន្ត្រីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល និងផ្សព្វផ្សាយសិទ្ធិកុមារយ៉ាងទូលំទូលាយ
- បានរៀបចំរបាយការណ៍ ស្តីពីស្ថានភាពនៃការអនុវត្តសិទ្ធិកុមារជារៀងរាល់ឆ្នាំ និងរៀបចំរបាយការណ៍ឆ្លើយតបទៅនឹងកម្រងសំណួររបស់គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិពាក់ព័ន្ធនឹងរបាយការណ៍ជាតិលើកទី១និងទី២ ស្តីពីការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ និងស្តីពីការជួញដូរកុមារ ការធ្វើពេស្យាចារកុមារនិងរូបភាពអាសអាភាសកុមារ និងរបាយការណ៍ឆ្លើយតបទៅនឹងសេចក្តីសម្រេចចិត្តមហាសន្និបាត អ.ស.ប លេខ ៦៩/១៥៩ ស្តីពីការការពារកុមារពីការសម្លុតគម្រាមកំហែង ដើម្បីផ្ញើទៅតំណាងពិសេសអង្គការសហប្រជាជាតិ។ បានរៀបចំ និងផ្សព្វផ្សាយដាក់ឱ្យអនុវត្តនូវផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍកុមារ ឆ្នាំ២០១៦-២០១៨។ បានរៀបចំរបាយការណ៍ជាតិគួបលើកទី៤ ទី៥ និងទី៦ ស្តីពីការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិកុមារ
- បានអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ និងបទដ្ឋានអប្បបរមា ស្តីពីការថែទាំជំនួសចំពោះកុមារ ដោយបានសហការជាមួយអង្គការជាតិ អន្តរជាតិ ទទួលកុមារកំព្រា និងកុមាររងគ្រោះឱ្យស្នាក់នៅកន្លែងថែទាំកុមារមាន៦៣៩កន្លែង មានកុមារចំនួន២៦.១៨៧នាក់ ស្រី១២.៥២៦នាក់ និងយុវជនចំនួន៩.១៨៧នាក់ ស្រី៣.៣២៣នាក់ ក្នុងនោះមណ្ឌលថែទាំកុមារចំនួន៤០៦កន្លែងមានកុមារសរុបចំនួន១៦.៥៧៩នាក់ (មណ្ឌលរដ្ឋ២២ មានកុមារនិងយុវជន១.៦០១នាក់ ស្រី៧២៤នាក់) ផ្ទះស្នាក់នៅបណ្តោះអាសន្ន២៥កន្លែងមានកុមារ៦២៨នាក់ ផ្ទះស្នាក់នៅជាក្រុម៧១កន្លែងមានកុមារ១.៥៩២នាក់ ក្រៅពីនោះ កុមារមួយចំនួនបានកំពុងស្នាក់នៅអន្តេវាសិកដ្ឋាន ទីវត្តអារាម និងទីកន្លែងសាសនា១៣៧កន្លែងមានកុមារ៧.៣៨៨នាក់ ស្រី៣.៥៨២នាក់។ តាមរយៈការធ្វើអធិការកិច្ចរបស់មន្ត្រីបង្គោលរាជធានី ខេត្ត បានរកឃើញមណ្ឌលចំនួន២៥២ប៉ុណ្ណោះ ក្នុងចំណោម៤០៦មណ្ឌលដែលមានកុមារស្នាក់នៅសរុបចំនួន៧.៦៣៤នាក់ ស្រី ៣.៦៣៤នាក់ និងយុវជនវ័យក្មេងចំនួន១.៧៧៩នាក់ ស្រី ៩១៩នាក់។ ក្នុងចំណោម៤០៦មណ្ឌល មាន៤៣ បានប្តូរពីការថែទាំជាមណ្ឌលទៅជាផ្ទះស្នាក់នៅជាបណ្តោះអាសន្ន ផ្ទះស្នាក់នៅជាក្រុម អន្តេវាសិកដ្ឋាន និងវត្តអារាម មណ្ឌលចំនួន៧៣ បានប្តូរទៅជាសេវាកម្មមិនថែទាំ មណ្ឌលចំនួន៣៣ បានបិទ ក្នុងនោះមានមណ្ឌលរដ្ឋចំនួនមួយផងដែរ ហើយមិនមានព័ត៌មានចំនួន៥មណ្ឌល។ ក្រសួងបានធ្វើសមាហរណកម្មកុមារដែលស្នាក់នៅក្នុងមណ្ឌលចំនួន១.០១៣នាក់ ទៅកាន់គ្រួសារ និងសហគមន៍វិញដែលជាផ្នែកមួយនៃការអនុវត្តផែនការពង្រឹងការថែទាំកុមារ និងសមាហរណកម្មកុមារចំនួន៣០% ពីមណ្ឌលថែទាំ ទៅកាន់គ្រួសារនិងសហគមន៍ប្រកបដោយសុវត្ថិភាព ២០១៦-២០១៨ នៅក្នុងរាជធានី ខេត្តគោលដៅទាំង៥ព្រមជាមួយគ្នានេះ ការថយចំនួនកុមារក្នុងមណ្ឌល អាចបញ្ជាក់ថា ការថែទាំកុមារនៅតាមសហគមន៍មានការកើនឡើង ដែលជាមូលហេតុតម្រូវឱ្យមន្ត្រីបង្គោលរាជធានី ខេត្ត បន្តធ្វើអធិការកិច្ចកន្លែងថែទាំកុមាររហូតដល់ការថែទាំបែបសហគមន៍

- ដើម្បីពង្រឹងប្រសិទ្ធភាពនិងគុណភាពការគ្រប់គ្រងមណ្ឌលថែទាំកុមារ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យចំនួន០៣ គឺ អនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ និងអនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៧នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ ដោយបានដំឡើងប្រាក់ម្ហូបអាហារពី៤៥.០០០៛/ខែ ទៅ ១៥០.០០០៛/ខែ និងអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការប្រគល់មុខងារ ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ការប្រគល់មុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និងមុខងារការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះនៅក្នុងសហគមន៍ ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ។ ដោយឡែក ក្រសួងបានចេញប្រកាសលេខ ៣០៨ ស.អ.យ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦ ស្តីពីលក្ខខណ្ឌ និងទម្រង់បែបបទនៃការស្នើសុំការអនុញ្ញាតបង្កើតមណ្ឌលថែទាំកុមារ និងបានបណ្តុះបណ្តាលគុណវុឌ្ឍិអង្គការសុវត្ថិភាពកុមារដល់មន្ត្រីជំនាញ បុគ្គលិកអង្គការជាច្រើន
- បានអនុវត្តតាមច្បាប់ ស្តីពីសុំកូនអន្តរប្រទេស ក្រសួងបានបង្កើតយន្តការ និងរៀបចំលិខិតបទដ្ឋានគតិយុត្តជាច្រើន និងបានចុះកិច្ចព្រមព្រៀងស្តីពីការកំណត់ចំនួនទីភ្នាក់ងារជាមួយសុំកូនអន្តរប្រទេសជាមួយប្រទេសអ៊ីតាលី ប្រទេសអេស្ប៉ាញ និងប្រទេសម៉ាល់តា
- បានទទួលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ឱ្យស្នាក់នៅមជ្ឈមណ្ឌលព្យាបាល ស្តារនីតិសម្បទា ២៩.៧៣៩នាក់ និងធ្វើសមាហរណកម្មទៅសហគមន៍វិញ ២១.១១៤នាក់
- បានប្រកាស និងដាក់ឱ្យអនុវត្តច្បាប់ ស្តីពីយុត្តិធម៌អនីតិជន ព្រមទាំងបានផ្សព្វផ្សាយដល់មន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដើម្បីជំរុញអនុវត្តច្បាប់នេះ ក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្ររយៈពេល០៣ឆ្នាំ ប្រកាស ស្តីពីការសាងសង់មណ្ឌលយុវនីតិសម្បទា ប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះមណ្ឌលយុវនីតិសម្បទា ប្រកាសអន្តរក្រសួង ស្តីពីលក្ខខណ្ឌនិងទម្រង់បែបបទនៃការស្នើសុំបង្កើតមណ្ឌលសម្រាប់ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងគោលការណ៍ណែនាំ ស្តីពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។ ព្រមជាមួយគ្នានេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា និងការកសាងមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនកែវផុស ខេត្តព្រះសីហនុ
- បានអប់រំកុមារ យុវជន ទប់ស្កាត់បាតុភាពអសកម្មនានាក្នុងសង្គម រួមចំណែកលើកស្ទួយសីលធម៌ សុជីវធម៌ និងការពារសិទ្ធិកុមារ និងជនរងគ្រោះដែលប្រើប្រាស់គ្រឿងញៀន។ បានសហការជាមួយក្រសួងមហាផ្ទៃ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ផ្តល់សេវាអប់រំក្រៅប្រព័ន្ធ និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់អនីតិជនទំនាស់នឹងច្បាប់ និងកុមារតាមម្តាយទៅក្នុងពន្ធនាគារដែលមានអាយុលើសពី ៣ឆ្នាំ។

តារាងទី៣.លទ្ធផលសម្រេចបានការងារអាទិភាពទី២

| ល.រ | សូចនាករ | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | 2014 | 2015 | 2016 | 2017 | 2018 | |
| 1 | កុមារកំព្រា និងកុមាររងគ្រោះធ្វើសមាហរណកម្មទៅគ្រួសារ និងសហគមន៍វិញ (នាក់) | 721 | 574 | 462 | 738 | 1,140 | 3,635 |
| 2 | ចំនួនកុមារដែលទទួលបានការថែទាំនៅតាមសហគមន៍ (នាក់) | 41,194 | 42,785 | 9,608 | 9,608 | 10,748 | |
| 3 | ចំនួនកុមារកំព្រា និងកុមារងាយរងគ្រោះដែលរស់នៅក្នុងមណ្ឌលថែទាំកុមារ (នាក់) | 11,411 | 11,171 | 16,579 | 16,579 | 7,634 | |
| 4 | អនីតិជនទំនាស់នឹងច្បាប់ធ្វើសមាហរណកម្មទៅគ្រួសារ និងសហគមន៍វិញ (នាក់) | 53 | 40 | 98 | 118 | 147 | 456 |
| 5 | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនធ្វើសមាហរណកម្មទៅគ្រួសារ និងសហគមន៍វិញ (នាក់) | 1,855 | 2,009 | 2,851 | 6,722 | 7,677 | 21,114 |
| 6 | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនទទួលបានសេវាស្តារនីតិសម្បទា (នាក់) | 2,875 | 3,386 | 5,203 | 10,178 | 8,097 | 29,739 |

**បញ្ហាប្រឈម[3]៖**

- នៅកម្ពុជាមិនទាន់មានទិន្នន័យជាក់លាក់ស្តីពីកុមារកំព្រា កុមារងាយរងគ្រោះ និងកុមារពិការទេ តែផែនការយុទ្ធសាស្ត្រជាតិស្តីពីកុមារកំព្រា កុមារងាយរងគ្រោះ និងកុមារពិការ បានប៉ាន់ស្មានថា មានកុមារងាយរងគ្រោះប្រមាណ១៤% នៃចំនួនកុមារសរុប។ ផ្អែកលើទិន្នន័យរបស់ក្រសួងផែនការ ស្តីពីលទ្ធផលអត្តសញ្ញាណកម្មគ្រួសារក្រីក្រឆ្នាំ២០១៤-២០១៧ មានន័យថាកុមារទទួលបានសេវាថែទាំក្នុងមណ្ឌល និងនៅតាមសហគមន៍ចំនួន៣.២% ក្នុងចំណោមកុមារស្ថិតក្នុងគ្រួសារក្រីក្រកម្រិត១ និងកម្រិត២ មានចំនួន៨២៥,២៣៦នាក់ (គ្រួសារក្រីក្រកម្រិត១ មានកុមារ ៣២៩,៤៤២នាក់ និងគ្រួសារក្រីក្រកម្រិត២ មានកុមារ ៤៩៥,៧៩៤នាក់) ដូចនេះមានកុមាររងគ្រោះ និងងាយរងគ្រោះចំនួន៩៦.៨%ទៀត ដែលរស់នៅក្នុងគ្រួសារក្រីក្រកម្រិត១ និងកម្រិត២ កំពុងរង់ចាំទទួលសេវា។ ទន្ទឹមនឹងនេះនៅមានស្ត្រីមានផ្ទៃពោះ និងកុមារអាយុពី០-៥ឆ្នាំក្នុងគ្រួសារក្រីក្រជាច្រើនទៀតកំពុងរងចាំកម្មវិធីផ្តល់កញ្ចប់សាច់ប្រាក់ដើម្បីឆ្លើយតបនឹងបញ្ហាកង្វះអាហារូបត្ថម្ភ
- ទិន្នន័យអង្កេតចន្លោះជំរឿននៃប្រជាពលរដ្ឋនៅកម្ពុជាឆ្នាំ២០១៣ បង្ហាញថា មានកុមារពិការប្រមាណ១% នៃចំនួនកុមារទូទាំងប្រទេស។ តួលេខនេះមានកម្រិតទាប ព្រោះថាចំនួននៃកុមារពិការមិនបានប្រមូលទិន្នន័យជាក់លាក់ពីភ្នាក់ងារប្រមូលទិន្នន័យ។ ម៉្យាងវិញទៀត កុមារពិការ គឺជាក្រុមដែលងាយរងគ្រោះ ហើយលទ្ធភាពក្នុងការទទួលបានសេវាកម្មនានាពីសង្គមនៅមានកម្រិត ពួកគេខ្លះប្រឈមនឹងការរើសអើង និងករណីខ្លះ ក៏មានអំពើហិង្សាពីគ្រួសារផងដែរ

[3] ត្រទី១ដល់ទី៤ដកស្រង់ពីផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ ២០១៦-២០១៨ ទំព័រទី៨-៩

- ចំណុចផ្តើម គឺត្រូវឱ្យមានតួលេខជាក់លាក់នៃកុមារកំព្រា កុមារងាយរងគ្រោះ និងកុមារពិការសិនមុន នឹងបង្កើតកម្មវិធីអន្តរាគមន៍ឱ្យបានត្រឹមត្រូវ
- ការសិក្សាថ្មីៗនេះ ស្តីពីអំពើហិង្សាលើកុមារ ដែលរៀបចំដោយក្រសួងកិច្ចការនារី សហការជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងផែនការ បង្ហាញថា ប្រមាណ៦០% នៃកុមារអាយុក្រោម១៧ឆ្នាំ ប្រឈមនឹងអំពើហិង្សាផ្នែករាងកាយ ហិង្សាផ្លូវភេទមានប្រមាណ៦,៤% ភាគច្រើនជាកុមារី។ ចំណុចចាប់ផ្តើមគឺត្រូវមានភាពត្រឹមត្រូវ ហើយទិន្នន័យពាក់ព័ន្ធបញ្ហាកុមារប្រើប្រាស់គ្រឿងញៀនមានការពិបាក ព្រោះការសិក្សាស្រាវជ្រាវមានទំហំធំ ដូច្នេះការសិក្សាស្រាវជ្រាវតូចៗ គឺមានភាពល្អប្រសើរជាង
- កុមារដែលកើត និងទៅតាមអាណាព្យាបាលនៅប្រទេសថៃតាមរយៈចំណាកស្រុក មិនទទួលបាន សញ្ជាតិ និងសេវាគាំទ្របានពេញលេញទេ
- កុមារកំព្រាមួយចំនួនបាននិងកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារដើម្បីចិញ្ចឹមបីបាច់ ថែទាំ អប់រំ រៀនសូត្រ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប៉ុន្តែក្នុងចំណោមកុមារទាំងនោះ នៅមានកុមារមួយចំនួន នៅមិនទាន់មានការគ្រប់គ្រងករណីបានពេញលេញ។ ដោយឡែក ប្រព័ន្ធព័ត៌មានថ្នាក់ជាតិដើម្បីគ្រប់គ្រង ទិន្នន័យកុមាររងគ្រោះ និងងាយរងគ្រោះ ដែលកំពុងស្នាក់នៅក្នុងមណ្ឌល និងសហគមន៍ នៅមិនទាន់ បានបង្កើតនៅឡើយ
- ច្បាប់យុត្តិធម៌អនីតិជន និងច្បាប់សុំកូនអន្តរប្រទេស ពុំទាន់ផ្សព្វផ្សាយបានទូលំទូលាយដល់មជ្ឈដ្ឋាន មហាជន ដែលធ្វើឱ្យការអនុវត្តច្បាប់ទាំងពីរនេះ អនុវត្តមិនបានពេញលេញនិងមិនសូវមានប្រសិទ្ធភាព
- កម្មវិធីយុវនីតិសម្បទាសម្រាប់អនីតិជនទំនាស់នឹងច្បាប់មិនទាន់បានអនុវត្តពេញលេញ ការជួយដល់ អនីតិជនទំនាស់នឹងច្បាប់នៅមានកម្រិត មណ្ឌលយុវនីតិសម្បទាមិនទាន់បានកសាងសម្រាប់ទទួល អនីតិជនទំនាស់នឹងច្បាប់ ដែលទាមទារឱ្យក្រសួងត្រូវបន្តខិតខំនិងប្តេជ្ញាបន្ថែមទៀត ដើម្បីដាក់ឱ្យ ដំណើរការកម្មវិធីនានាសម្រាប់ជួយដល់អនីតិជនទំនាស់នឹងច្បាប់
- ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន បានទទួលសេវាព្យាបាលនិងស្តារនីតិសម្បទារាប់ពាន់ នាក់ក្នុងមួយឆ្នាំតាមរយៈមណ្ឌលព្យាបាល និងស្តារនីតិសម្បទា ព្រមទាំងធ្វើសមាហរណកម្មទៅគ្រួសារ និងសហគមន៍វិញ ប៉ុន្តែ កន្លងមក បន្ទាប់ពីបានធ្វើសមាហរណកម្មទៅគ្រួសារនិងសហគមន៍ ក្រសួង មិនទាន់មានកម្មវិធីសម្រាប់តាមដានឱ្យដឹងថា តើជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន ទាំងនោះបានជាសះស្បើយ ឬលាប់ត្រឡប់ទៅប្រើប្រាស់គ្រឿងញៀនសារជាថ្មី។

## ការងារអាទិភាពទី៣៖ លើកកម្ពស់សុខុមាលភាពសម្រាប់ជនពិការ

- បានអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បានអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនពិការ និងទសវត្សរ៍ជនពិការប្រចាំតំបន់ អាស៊ី និងប៉ាស៊ីហ្វិកឆ្នាំ២០១៣-២០២២ យុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឱ្យសិទ្ធិក្លាយជាការពិត" បន្ថែម លើបទដ្ឋានគតិយុត្តជាតិដែលមានស្រាប់ ដោយបានរៀបចំរបាយការណ៍ជាតិលើកដំបូង ស្តីពីការ អនុវត្តអនុសញ្ញា ស្តីពីសិទ្ធិជនពិការ

- បានប្រកាសជាផ្លូវការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព ២០១៤-២០១៨ តាមរយៈផែនការនេះ ក្រសួងបានរៀបចំរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិឆ្នាំ២០១៥ និងសេចក្តីព្រាងរបាយការណ៍បញ្ចប់អាណត្តិឆ្នាំ២០១៤-២០១៨
- បានចូលរួមកិច្ចប្រជុំក្រុមការងារក្នុងក្របខ័ណ្ឌអាស៊ានចំនួន០៦លើក ស្តីពីការកសាងផែនការមេសម្រាប់ការបញ្ជ្រាបសិទ្ធិជនពិការក្នុងសហគមន៍អាស៊ាន ឆ្នាំ២០២៥
- បានចូលរួមសន្និសីទលើកទី១១ នៃរដ្ឋភាគីអនុសញ្ញា ស្តីពីសិទ្ធិជនពិការនៅអង្គការសហប្រជាជាតិការិយាល័យកណ្តាលទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក កាលពីថ្ងៃទី១២ ដល់១៤ ខែមិថុនា ឆ្នាំ២០១៨ ក្រោមប្រធានបទ "មិនអនុញ្ញាតឱ្យនរណាម្នាក់នៅក្រៅការអនុវត្តយ៉ាងពេញលេញនៃអនុសញ្ញា ស្តីពីសិទ្ធិជនពិការ" ក្នុងនោះ កម្ពុជាទទួលបានការគាំទ្រ១៨៣សម្លេង លើ១៨៨សម្លេងចូលជាសមាជិក ECOSOC នៃអង្គការសហប្រជាជាតិ
- បានរៀបចំទិវាជនពិការកម្ពុជា និងទិវាជនពិការអន្តរជាតិ ទិវាគ ថ្លង់ និងទិវាអូទីហ្ស៊ឹមនិងដោនស៊ីនដ្រូមសម្រាប់ជនពិការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានបង្កើតក្រុមការងារសកម្មភាពជនពិការតាមក្រសួង ស្ថាប័នចំនួន១៩ និងក្រុមប្រឹក្សាសកម្មភាពជនពិការតាមរាជធានី ខេត្តចំនួន២៥ និងបានបណ្តុះបណ្តាលបញ្ជ្រាបការយល់ដឹងអំពីអនុសញ្ញាស្តីពីសិទ្ធិជនពិការ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិកឆ្នាំ២០១៣-២០២២ យុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឱ្យសិទ្ធិក្លាយជាការពិត" និងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព ដល់សមាជិកមន្ត្រីនៃអគ្គលេខាធិការដ្ឋាន ក.ស.ជ. ក្រុមការងារ ក.ស.ជ. តាមក្រសួង ស្ថាប័ន និង ក.ស.ជ. ថ្នាក់រាជធានី ខេត្ត
- បានលើកទឹកចិត្តចលនាកីឡា សិល្បៈរបស់ជនពិការ។ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ ស្តីពីការផ្តល់ប្រាក់រង្វាន់ចំពោះជ័យលាភីជនពិការក្នុងការប្រកួតប្រជែងមុខជំនាញ ការប្រកួតកីឡាស៊េរ៉ស្យ៉ាល់អូឡាំពិក និងប្រាក់ឧបត្ថម្ភគ្រូបង្វឹកនិងគ្រូបង្វឹកជំនួយ។ កីឡាករជនពិការបានចូលរួមប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី៧ នៅប្រទេសភូមា ទទួលមេដាយសរុបចំនួន៣២គ្រឿង ក្នុងនោះ មេដាយមាស០៤ មេដាយប្រាក់១១ និងមេដាយសំរឹទ្ធិ១៧ និងបានទៅចូលរួមប្រកួតផ្នែកព័ត៌មានវិទ្យាថ្នាក់អន្តរជាតិ នៅទីក្រុងប៊ូសាន សាធារណរដ្ឋកូរ៉េ ដោយទទួលបានមេដាយមាស ប្រាក់ និងមេដាយសំរឹទ្ធិសរុបចំនួន១៥មេដាយ និងចូលរួមប្រកួតកីឡាស៊េរ៉ស្យ៉ាល់អូឡាំពិក ទទួលបានមេដាយសរុបចំនួន៤១គ្រឿង
- បានបណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្តួចផ្តើមបង្កើតមុខរបរនៅតាមសហគមន៍ដល់ជនពិការបាន ១.០៨១នាក់ លើជំនាញ កាត់ដេរសម្លៀកបំពាក់និងកាបូប អេឡិចត្រូនិច ជួសជុលម៉ាស៊ីន អ៊ុតសក់ធ្វើមុខនិងសម្អាងការ ចម្លាក់ កសិកម្ម ជួសជុលទូរស័ព្ទ និងជំនាញគ្រប់គ្រងអាជីវកម្មនិងអនាម័យ។ ទន្ទឹមនេះ បានដោះស្រាយការងារ និងមុខរបរជូនជនពិការបាន៣៨៥នាក់។ ដោយឡែក កុមារ គ ថ្លង់ ខ្សោយសតិបញ្ញា និងពិការភ្នែក១.០២៨នាក់ បានសិក្សាភាសាសញ្ញា និងអក្សរស្ទាប តាមរយៈកម្មវិធីសិក្សារបស់អង្គការដៃគូ

- អនុវត្តតាមអនុក្រឹត្យ ស្តីពីការជ្រើសរើសជនពិការចូលបម្រើការងារ ក្រសួង ស.អ.យ. បានជំរុញក្រសួង ស្ថាប័នរដ្ឋ ក្នុងការជ្រើសរើសជនពិការចូលបម្រើការងារតាមអត្រាកំណត់២% បច្ចុប្បន្នជនពិការ២.៧៧៣នាក់ស្មើនឹង១.៧៨% កំពុងបម្រើការងារតាមក្រសួង ស្ថាប័នរដ្ឋចំនួន៤៣ និងជនពិការ២.៩៦២នាក់ កំពុងបម្រើការងារនៅក្នុងរោងចក្រ សហគ្រាស ផ្នែកឯកជនចំនួន៦៣
- បានផ្តល់របបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ ៨.៦៥៨នាក់ ទៅតាមបីកម្រិត កម្រិត១ឧបត្ថម្ភ១២ខែ កម្រិត២ឧបត្ថម្ភ៦ខែ និងកម្រិត៣ឧបត្ថម្ភ៣ខែ ដោយមួយខែៗឧបត្ថម្ភ២០.០០០៛
- បានចេញប្រកាស ស្តីពីការដាក់ឱ្យប្រើប្រាស់នូវឯកសារណែនាំគោល ស្តីពីនីតិវិធីអធិការកិច្ចលើវិស័យពិការភាពនៃព្រះរាជាណាចក្រកម្ពុជា និងបានផ្សព្វផ្សាយបានចំនួន១៦ខេត្ត
- មូលនិធិជនពិការបានសហការជាមួយអង្គការដៃគូ ផ្តល់សេវាស្តារលទ្ធភាពពលកម្មប្រកបដោយគុណភាពដោយឥតគិតថ្លៃជូនជនពិការ ៣៩០.០២៤នាក់ ក្នុងនោះ សេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ២៥៤.៩២៦នាក់ និងស្តារលទ្ធភាពពលកម្មកាយសម្បទាបាន ១៣៥.០៩៨នាក់។ ទន្ទឹមនេះ ជនពិការដែលមកទទួលសេវាពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម បានទទួលការឧបត្ថម្ភជាប្រាក់អាហារ និងថ្លៃធ្វើដំណើរទៅមកផងដែរ។ ក្រៅពីការផ្តល់សេវានៅតាមមណ្ឌលស្តារលទ្ធភាពពលកម្ម មូលនិធិជនពិការក៏បានផ្តល់សេវាសហគមន៍ជូនជនពិការ ដូចជា ការជួសជុលឧបករណ៍សិប្បនិម្មិតនិងរណប ការសម្របសម្រួលជូនជនពិការទៅទទួលសេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបង្កើតក្រុមជួយខ្លួនឯងនៃជនពិការចំនួន១.៩៦៦ក្រុម។ បានចុះផ្តល់ប្រាក់ឧបត្ថម្ភរបបគោលនយោបាយសម្រាប់ពិនិត្យនិងថែទាំសុខភាព ជូនដល់ជនពិការក្រីក្រនៅតាមសហគមន៍បាន ៩៤៦នាក់ ក្នុងនោះ ស្រុកមេមត់ខេត្តត្បូងឃ្មុំ ៧១៤នាក់ និងខេត្តប៉ៃលិន ២៣២នាក់ ដោយម្នាក់ៗទទួលបានថវិកា៣០.០០០៛។

តារាងទី៤.លទ្ធផលសម្រេចបានការងារអាទិភាពទី៣

| ល.រ | សូចនាករ | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | 2014 | 2015 | 2016 | 2017 | 2018 | |
| 1 | ជនពិការដែលទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ(នាក់) | 158 | 478 | 205 | 123 | 117 | 1,081 |
| 2 | ជនពិការក្រីក្រនៅតាមសហគមន៍ទទួលបានរបបឧបត្ថម្ភគោលនយោបាយ (នាក់) | 0 | 0 | 3,133 | 6,658 | 8,658 | |
| 3 | ជនពិការទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទា(នាក់) | 25,485 | 27,175 | 30,249 | 26,325 | 25,864 | 135,098 |
| 4 | ជនពិការទទួលបានសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ(នាក់) | 35,291 | 53,673 | 27,254 | 82,596 | 56,112 | 254,926 |

**បញ្ហាប្រឈម៖**

- ជនពិការ ជាពិសេស ជនពិការក្រីក្រតែងជួបប្រទះការរើសអើងពីសង្គម ព្រមទាំងជួបការលំបាក ទាំងផ្នែកកាយសម្បទា និងហិរញ្ញវត្ថុ ដែលរារាំងពួកគាត់ពីការទទួលយកសេវាសុខាភិបាល និងការអប់រំ ព្រមទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ។ កត្តានេះ នាំឱ្យជនពិការមិនមានលទ្ធភាពក្នុងការរួមចំណែកក្នុងការបង្កើនផលិតភាពក្នុងសេដ្ឋកិច្ច ឬទទួលបានអត្ថប្រយោជន៍ពីកត្តាសេដ្ឋកិច្ចទាំងនេះឡើយ[4]
- យន្តការនៃការកំណត់អត្តសញ្ញាណរបស់ជនពិការនៅមានភាពខ្វះខាតច្រើននៅឡើយ ដែលនាំឱ្យជនពិការមួយចំនួន មិនបានទទួលអត្ថប្រយោជន៍ពីគោលនយោបាយនានារបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា
- មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មភាគច្រើនទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដូចនេះនៅពេលដែលដៃគូអភិវឌ្ឍន៍បន្ថយ ឬបញ្ឈប់ការគាំទ្រ ធ្វើឱ្យមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មជួបបញ្ហាហិរញ្ញវត្ថុ។ គុណភាពនៃការស្តារលទ្ធភាពពលកម្មនៅមានកម្រិត ដែលទាមទារឱ្យមានការពង្រឹងបន្ថែមទាំងលើមន្ត្រីជំនាញក្នុងការពន្លឿនការព្យាបាលជូនជនពិការ ជាមួយនឹងឧបករណ៍បច្ចេកទេសជំនួយសម្រាប់ប្រក្រតីភាពនៃជីវិតជនពិការ[5]
- ការជ្រើសរើសជនពិការចូលបម្រើការងារ មិនទាន់អនុវត្តបានតាមអត្រាកំណត់សម្រាប់វិស័យឯកជន។ រដ្ឋបាលសិទ្ធិជនពិការដែលជាយន្តការដ៏សំខាន់ក្នុងការរៀបចំបទដ្ឋានគតិយុត្ត នីតិវិធី និងគោលការណ៍ណែនាំសម្រាប់អនុវត្តកិច្ចការនេះ កំពុងជួបការលំបាកខ្វះខាតមធ្យោបាយ និងធនធានសម្រាប់បម្រើឱ្យការអនុវត្តកម្មវិធីរបស់ខ្លួន
- របបឧបត្ថម្ភជនពិការក្រីក្រនៅសហគមន៍ ទើបអនុវត្តបានតែ៥ខេត្ត ដោយសារ ការកំណត់អត្តសញ្ញាណជនពិការក្រីក្រមិនទាន់គ្របដណ្តប់ទូទាំងប្រទេស ដោយកញ្ចប់ថវិកាជាតិ និងសមត្ថភាពមន្ត្រីនៅថ្នាក់ក្រោមជាតិ រួមទាំងបច្ចេកវិទ្យានៅមានកម្រិត
- ការបណ្តុះបណ្តាលជនពិការនៅមិនទាន់បានទូលំទូលាយ ព្រមទាំងការយល់ដឹង និងលទ្ធភាពទទួលព័ត៌មានអំពីសេវាស្តារលទ្ធភាពពលកម្មកាយសម្បទារបស់ជនពិការនៅមានកម្រិត ទោះបីជាមានការផ្សព្វផ្សាយយ៉ាងណាក៏ដោយ។

## ការងារអាទិភាពទី៤៖ លើកកម្ពស់សុខុមាលភាពមនុស្សចាស់

- បានរៀបចំ និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ និងបានរៀបចំផែនការសកម្មភាព ២០១៨-២០២០ សម្រាប់អនុវត្តគោលនយោបាយនេះផងដែរ
- បានសាងសង់មជ្ឈមណ្ឌលជាតិគាំពារមនុស្សចាស់រាជធានីភ្នំពេញ និងដាក់ឱ្យដំណើរការឆាប់ៗនេះ។ ទន្ទឹមនេះ ក្រសួងបានចេញប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិគាំពារ

[4] ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ទំព័រទី១៩
[5] ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ទំព័រទី៤០

មនុស្សចាស់ រាជធានីភ្នំពេញ និងកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីកិច្ចគាំពារសង្គមសម្រាប់មនុស្សវ័យចាស់ក្រីក្រគ្មានទីពឹង

- បានរៀបចំទិវាមនុស្សចាស់កម្ពុជា និងមនុស្សចាស់អន្តរជាតិ ០១តុលា ជារៀងរាល់ឆ្នាំ ដើម្បីលើកស្ទួយដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មនុស្សចាស់
- បានបំផុសលើកទឹកចិត្ត និងគាំទ្រ ដល់អង្គការសង្គមស៊ីវិល វិស័យឯកជន និងសប្បុរសជន ក្នុងការបង្កើតមជ្ឈមណ្ឌលថែទាំមនុស្សចាស់ សាងសង់ផ្ទះសម្រាប់មនុស្សចាស់ក្រីក្រគ្មានទីពឹង និងការផ្តល់ថវិកា សម្ភារបរិក្ខារដល់មនុស្សចាស់ក្រីក្រគ្មានទីពឹង
- ដើម្បីលើកកម្ពស់សេចក្តីថ្លៃថ្នូរ ជំរុញលើកទឹកចិត្តឱ្យមនុស្សចាស់ចេះសាមគ្គីគ្នា ជួយគ្នាទៅវិញទៅមក ក្រសួងបានបង្កើតសមាគមមនុស្សចាស់ ១.៦៥០ នៅគ្រប់២៥ រាជធានី ខេត្ត ទូទាំងប្រទេស ក្រៅពីនេះ ក្រសួងបាននិងកំពុងរៀបចំបង្កើតមូលនិធិមនុស្សចាស់ ដើម្បីបន្តនិរន្តរភាពការគាំពារដល់មនុស្សចាស់។

តារាងទី៥.លទ្ធផលសម្រេចបានការងារអាទិភាពទី៤

| ល.រ | សូចនាករ | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | 2014 | 2015 | 2016 | 2017 | 2018 | |
| 1 | សមាគមមនុស្សចាស់ត្រូវបានបង្កើត(សមាគម) | 0 | 0 | 394 | 1,246 | 10 | 1,650 |

**បញ្ហាប្រឈម៖**

- និរន្តរភាពសមាគមមនុស្សចាស់ហាក់មិនទាន់មានភាពច្បាស់លាស់និងប្រាកដប្រជា ដោយសារកង្វះថវិកា ដើម្បីជួយទ្រទ្រង់ដល់សមាគម ការផ្តល់បច្ចេកទេសបន្ថែមទៅលើការគ្រប់គ្រងសមាគមមនុស្សចាស់ក៏នៅមានកម្រិត ព្រមទាំងមិនបានចុះពិនិត្យតាមដាននិងវាយតម្លៃពីដំណើរការសមាគម បន្ទាប់ពីបង្កើតរួច។ ក្រៅពីនេះ យើងក៏មិនទាន់មានកម្មវិធីគាំទ្រនិងថែទាំដែលមានលក្ខណៈអចិន្ត្រៃយ៍ដល់មនុស្សចាស់ដែលជាសមាជិកសមាគមមនុស្សចាស់ឃុំ សង្កាត់។
- ទោះបីជាយ៉ាងណាក៏ដោយ យើងនៅតែជួបបញ្ហាប្រឈមមួយចំនួនដែលត្រូវគិតគូ និងយកចិត្តទុកដាក់ ដូចជា ការកើនឡើងនូវចំនួនមនុស្សវ័យចាស់ដែលមានអាយុ៦០ឆ្នាំឡើង។ នៅក្នុងឆ្នាំ២០១៣ មនុស្សវ័យចាស់មាន៨% ប្រមាណ១.២០០.០០០នាក់នៃប្រជាជនសរុប១៥លាននាក់ នៅឆ្នាំ២០១៥ មាន៧,២% ប្រមាណ១.១០៧.០០០នាក់ នៃប្រជាជនសរុប១៥.៧០០.០០០នាក់ ហើយត្រូវបានព្យាករណ៍ថា នឹងកើនឡើងរហូតដល់១១% ប្រមាណ១.៩៩០.០០០នាក់ នៃប្រជាជនសរុប១៨លាននាក់ នៅឆ្នាំ២០៣០ ដូចបានបង្ហាញក្នុងរូបទី១ ប៉ុន្តែនៅក្នុងឆ្នាំ២០១៦ តាមប្រព័ន្ធទិន្នន័យឃុំ សង្កាត់បានរកឃើញថា មានមនុស្សវ័យចាស់ក្រីក្រសរុបប្រមាណ២៣២.៣១១នាក់[6] នៃចំនួនមនុស្សវ័យចាស់សរុប ក្នុងនោះ មនុស្សវ័យចាស់ក្រីក្រ១ សរុប៩៨.១៦៥នាក់ និងមនុស្សវ័យចាស់ក្រីក្រ២ សរុប១៣៤.១៤៦នាក់។

[6] របាយការណ៍ និងផែនទីចេញពីមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រ នៃប្រព័ន្ធព័ត៌មានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ២០១៥

រូបទី១.ភាគរយប៉ាន់ស្មាននិងព្យាករណ៍ នៃប្រជាជនវ័យចាស់ធៀបនឹងប្រជាជនសរុប




**ប្រភព៖ ការព្យាករណ៍ចំនួនប្រជាជនកម្ពុជា** របាយការណ៍ជំរឿនទូទៅនូវប្រជារាស្ត្រឆ្នាំ២០០៨ លេខ១២

- ពិតមែនតែមនុស្សវ័យចាស់កម្ពុជាមានអាយុកាន់តែវែង ហើយរស់នៅក្នុងជីវិតដែលមានសុខភាពល្អជាងមុន ទោះជាយ៉ាងនេះក្តី មនុស្សវ័យចាស់កម្ពុជាប្រឈមមុខកាន់តែច្រើនទៅនឹងកត្តាផ្នែកសង្គមសេដ្ឋកិច្ច ផលិតភាពចុះទាប ស្ថានភាពសុខភាព គួបផ្សំនឹងការធ្វើចំណាកស្រុករបស់មនុស្សពេញវ័យដើម្បីស្វែងរកការងារធ្វើ បន្សល់ទុកកូនៗឱ្យរស់នៅជាមួយមនុស្សចាស់។ នៅពេលដែលមនុស្សចាស់មានអាយុកាន់តែច្រើន បញ្ហាដែលពួកគាត់កំពុងប្រឈមមានទំហំកាន់តែធំ។ មនុស្សកាន់តែចាស់ភាពងាយរងគ្រោះរបស់ពួកគាត់ក៏កាន់តែកើនឡើងផងដែរ។ ពួកគាត់អាចជួបនឹងបញ្ហាប្រឈមកាន់តែច្រើនឡើង រួមមាន ស្ថានភាពសុខភាពទន់ខ្សោយ ការចុះខ្សោយនៃប្រព័ន្ធការពាររាងកាយពីជំងឺឆ្លងផ្សេងៗ និងមានហានិភ័យកាន់តែខ្ពស់ចំពោះជំងឺមិនឆ្លង ដូចជា ជំងឺទឹកនោមផ្អែម និងសម្ពាធឈាមខ្ពស់ជាដើម។ ទន្ទឹមនឹងនេះ មនុស្សចាស់ក៏ច្រើនតែមានជំងឺធ្ងន់ធ្ងរដល់អាយុជីវិត ដូចជា ជំងឺមហារីក ពិការភាព និងការលែងដំណើរការនៃសរីរាង្គ ដែលទាមទារឱ្យមានការថែទាំរយៈពេលវែង
- អាំងស៊ីដង់ជំងឺ ក៏ដូចជា ពិការភាពកើនឡើងទៅតាមអាយុដែលទាមទារនូវការយកចិត្តដាក់ដល់អ្នករងផលប៉ះពាល់ឱ្យបានច្រើនជាងមុន រួមទាំងការផ្តល់ការថែទាំរយៈពេលវែង។ ការចំណាយលើផ្នែកសុខភាពមានការកើនឡើង និងអសន្តិសុខផ្នែកហិរញ្ញវត្ថុក៏មានការកើនឡើងទៅតាមអាយុ។ បញ្ហានេះមួយផ្នែកបណ្តាលមកពីការធ្លាក់ចុះនៃសមត្ថភាពចូលរួមក្នុងការងាររបស់ពួកគាត់។ លើសពីនេះទៀត តម្លៃពិតនៃប្រាក់សោធនក៏នឹងថយចុះទៅតាមពេលវេលាផងដែរ។ តាមធម្មតា ការកែតម្រូវប្រាក់សោធនមិនបានឆ្លើយតបទាំងស្រុងទៅនឹងកំណើននៃចំណាយសម្រាប់ជីវភាពប្រចាំថ្ងៃទេ។ ជាលទ្ធផល ហានិភ័យដែលមនុស្សចាស់នឹងប្រឈម គឺការធ្លាក់ចូលទៅក្នុងភាពក្រីក្រ នៅពេលដែលពួកគាត់មានអាយុកាន់តែច្រើន
- ប្រពៃណីនៃការជួយផ្តល់ប្រាក់កាសដល់ឪពុកម្តាយ និងសាច់ញាតិវ័យចាស់របស់កូនៗ និងសាច់ញាតិវ័យក្មេងបានចាក់ឫសគល់រឹងមាំនៅក្នុងសង្គមកម្ពុជា ប៉ុន្តែការប្រតិបត្តិប្រពៃណីបែបនេះអាចនឹងធ្លាក់ចុះ

នៅថ្ងៃខាងមុខនៅពេលណាដែលចំនួនអ្នកផ្តល់ការគាំទ្រមនុស្សចាស់ (មនុស្សវ័យក្មេងជាង) មានកាន់តែតិចទៅៗ។ ក្នុងន័យនេះការជួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុដែលនឹងត្រូវផ្តល់ដោយប្រជាជនវ័យក្មេងដែលកាន់តែមានចំនួនតិចទៅៗ នឹងមានការធ្លាក់ចុះជាបណ្តើរៗ។ ដើម្បីរក្សាបាននូវគុណភាពជីវិតរបស់មនុស្សចាស់ ការធានាបាននូវស្ថិរភាពនៃប្រាក់ចំណូលរបស់ពួកគាត់គឺជាប្រការចាំបាច់។ មនុស្សចាស់ដែលជួបប្រទះអសន្តិសុខហិរញ្ញវត្ថុ និងមិនមានសមត្ថភាពអាចធ្វើការបាន ចាំបាច់ត្រូវស្ថិតក្រោមគម្រោងគាំពារសង្គមនិងសុខុមាលភាព។ នាពេលបច្ចុប្បន្ននេះ វិសាលភាពនៃគម្រោងគាំពារសង្គមនិងសុខុមាលភាព នៅមានកម្រិតនៅឡើយ ហើយចាំបាច់ត្រូវពង្រីកបន្ថែមទៀត ដើម្បីការពារមនុស្សចាស់ដែលងាយរងគ្រោះឱ្យគេចផុតពីភាពក្រីក្រ។

## ការងារអាទិភាពទី៥៖ លើកកម្ពស់វិស័យអតីតមន្ត្រីរាជការស៊ីវិល

- ដើម្បីទ្រទ្រង់ដំណើរការបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល រាជរដ្ឋាភិបាលបានបង់ភាគទាន ២៤% នៃប្រាក់បៀវត្សរ៍សរុប ដោយក្នុងនោះ បានបង់ភាគទាន ៦% ជំនួសមន្ត្រីរាជការស៊ីវិលដែលមានកាតព្វកិច្ចត្រូវបង់។ ទន្ទឹមនឹងការទ្រទ្រង់ទាំងស្រុងដោយថវិកាជាតិលើរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ធ្វើការកែសម្រួលដំឡើងរបបសន្តិសុខសង្គមនេះជាបន្តបន្ទាប់ ដើម្បីឱ្យស្របតាមការរីកចម្រើននៃសេដ្ឋកិច្ច និងលទ្ធភាពនៃថវិកាជាតិ
- ប.ជ.ស. បានបង្កើតការិយាល័យថ្នាក់រាជធានី ខេត្ត ដែលជាសេនាធិការក្នុងការអនុវត្តការងារ និងដោះស្រាយបញ្ហានានាផ្ទាល់ជាមួយសិទ្ធិវន្ត។ រាជរដ្ឋាភិបាលបានចេញសារាចរលេខ០៥ សរ. ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលនីតិវិធី នៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ ដើម្បីធានាប្រសិទ្ធភាពនៃការដាក់ឱ្យចូលនិវត្តន៍ និងទទួលប្រាក់សោធនទាន់ពេលវេលា
- នៅដើមឆ្នាំ២០១៨ ប.ជ.ស. បានសហការជាមួយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ដើម្បីផ្តល់តាវកាលិកថៃទាំសុខភាពជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយត្រូវបានដាក់ឱ្យទទួលសេវាថៃទាំសុខភាពនៅតាមបណ្តាមូលដ្ឋានសុខាភិបាលដែលមានចុះកិច្ចសន្យាជាមួយ ប.ស.ស. ចាប់ពីខែមករា ឆ្នាំ២០១៨ តទៅ
- ក្នុងរយៈពេល៥ឆ្នាំ ២០១៤-២០១៨ រាជរដ្ឋាភិបាលបានដំឡើងប្រាក់សោធនជាមធ្យមជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈជារៀងរាល់ឆ្នាំ ដែលមានអត្រាកំណើនប្រមាណ៤២%។ ដោយឡែកចំពោះប្រាក់សោធនអប្បបរមាគឺមានការកើនឡើង១៤០% ដោយក្នុងឆ្នាំ២០១៤ ប្រាក់សោធនអប្បបរមារបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ មានចំនួន២០០.០០០៛ មកដល់ឆ្នាំ២០១៨ ប្រាក់សោធនអប្បបរមាត្រូវបានដំឡើងដល់៤៨០.០០០៛។ ដើម្បីធានាដល់ការបើកប្រាក់សោធនបានទាន់ពេលវេលា រាជរដ្ឋាភិបាលបានចេញសារាចរលេខ០៤ សរ. ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់ប្រាក់របបសន្តិសុខសង្គមជូនសិទ្ធិវន្ត និងជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន។ គិតជាមធ្យមក្នុងរយៈពេល៥ឆ្នាំនេះ មាននិវត្តជន និងជន

បាត់បង់សម្បទាវិជ្ជាជីវៈចំនួន៥១.៨៤៧នាក់[7] និងអ្នកនៅក្នុងបន្ទុកចំនួន៤១.៤៣១នាក់[8] កំពុងទទួលរបបសន្តិសុខសង្គម។

តារាងទី៦.លទ្ធផលសម្រេចបានការងារអាទិភាពទី៥

| ល.រ | សូចនាករ | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | |
|---|---|---|---|---|---|---|
| | | 2014 | 2015 | 2016 | 2017 | 2018 |
| 1 | និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលទទួលបានរបបសោធន(នាក់) | 47,375 | 49,709 | 52,012 | 53,785 | 56,353 |
| | - និវត្តជន(នាក់) | 44,469 | 46,856 | 49,392 | 51,345 | 54,028 |
| | - ជនបាត់បង់សម្បទាវិជ្ជាជីវៈ(នាក់) | 2,906 | 2,853 | 2,620 | 2,440 | 2,325 |
| 2 | អ្នកនៅក្នុងបន្ទុក(នាក់) | 42,046 | 37,728 | 40,423 | 42,926 | 44,033 |

**បញ្ហាប្រឈម៖**

- ប.ជ.ស. ត្រូវបានបង្កើតឡើងក្នុងគោលដៅដើម្បីគ្រប់គ្រង ធានាការបើកផ្តល់ និងបម្រើសេវារបបសន្តិសុខសង្គមជូនមន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក ឱ្យបានទាន់ពេលវេលា ដើម្បីកាត់បន្ថយការលំបាករបស់ពួកគាត់ តាមគោលការណ៍អភិបាលកិច្ចល្អ មានតម្លាភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។ ទោះជាយ៉ាងនេះក្តី ប.ជ.ស. នៅជួបបញ្ហាប្រឈមជាច្រើនដែលត្រូវបន្តដោះស្រាយក្នុងក្របខ័ណ្ឌរយៈពេលខ្លី មធ្យម និងវែង ប្រកបដោយភាពទន់ភ្លន់ និងការទទួលខុសត្រូវ។ បញ្ហាទាំងនោះរួមមាន ទី១.ប្រព័ន្ធសោធនកំពុងប្រឈមជាមួយនឹងបញ្ហាអសង្គតិភាពនៃប្រាក់សោធន រវាងនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលចូលនិវត្តន៍មុនឆ្នាំ២០១៥ និងក្រោយឆ្នាំ២០១៥ ដោយសារឥទ្ធិពលដែលកើតចេញពីការដំឡើងប្រាក់សោធនតាមកម្រិត និងការកែប្រែប្រព័ន្ធបៀវត្សរ៍មូលដ្ឋានថ្មី ទី២.តាវកាលិកចំនួន៣ គឺ គ្រោះថ្នាក់ការងារ លំហែមាតុភាព និងមរណភាពសម្រាប់មន្ត្រីរាជការស៊ីវិលពុំទាន់ត្រូវបានអនុវត្តនៅឡើយ ដែលកន្លងមកអត្ថប្រយោជន៍ទាំងបីនេះផ្តល់ដោយក្រសួង ស្ថាប័នសាមី ទី៣.នៅពុំទាន់មានមូលនិធិសម្រាប់ទ្រទ្រង់ដំណើរការ ប.ជ.ស. ក្រៅពីការឧបត្ថម្ភរបស់រដ្ឋ
- មកទល់ពេលនេះ រដ្ឋរ៉ាប់រងទាំងស្រុងលើការចំណាយបើកផ្តល់ប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ទៅតាមតម្រូវការនៃចំណាយជាក់ស្តែងប្រចាំឆ្នាំ។ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ ស្តីពីការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលតម្រូវឱ្យមន្ត្រីរាជការស៊ីវិល

[7] 51,847នាក់ = (47,375នាក់ + 49,709នាក់ + 52,012នាក់ + 53,785នាក់ + 56,353នាក់) / 5

[8] 41,431នាក់ = (42,046នាក់ + 37,728នាក់ + 40,423នាក់ + 42,926នាក់ + 44,033នាក់) / 5

បង់ភាគទាន ៦% និងរដ្ឋត្រូវចូលរួមបង់ភាគទាន១៨%។ ប៉ុន្តែ ការប្រមូលភាគទានតាមអត្រាដែលបានកំណត់រួចនេះមិនទាន់បានអនុវត្តនៅឡើយ។ ដូច្នេះ រដ្ឋនៅតែបន្តរ៉ាប់រងទាំងស្រុងលើការឧបត្ថម្ភអតីតមន្ត្រីរាជការស៊ីវិល និងអ្នកនៅក្នុងបន្ទុក។ គម្រោងដំឡើងបៀវត្សរ៍ប្រចាំឆ្នាំ អាចនឹងគិតគូរពិចារណារួមគ្នាជាមួយនឹងការដាក់ឱ្យអនុវត្តការប្រមូលភាគទាននេះ។[9]

## ការងារអាទិភាពទី៦៖ លើកកម្ពស់វិស័យអតីតយុទ្ធជន

- ក្រសួងបានយកចិត្តទុកដាក់ចំពោះស្ថានភាពរបស់អតីតយុទ្ធជន ដោយកែសម្រួលបន្ថែមប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជនជាបន្តបន្ទាប់ ចាប់ពីឆ្នាំ២០១៤ បានកែសម្រួលបង្កើនប្រាក់ឧបត្ថម្ភប្រចាំខែជូនឪពុក ម្តាយ អាណាព្យាបាលរបស់ជនពលីមរណៈពី៣.២០០៛ ទៅ៨.០០០៛ ក្នុង១ខែ ប្រាក់ឧបត្ថម្ភប្រពន្ធដល់១៥.០០០៛/ខែ និងកូនដល់១០.០០០៛/ខែ
- បានកែសម្រួលប្រាក់បៀវត្សរ៍មូលដ្ឋាន និងប្រាក់ម្ហូបអាហារជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ដែលបានផ្ទេរមកក្រសួង ស.អ.យ. មុន និងក្រោយឆ្នាំ២០០៧ ឱ្យមានតុល្យភាពគ្នា។ រហូតមកដល់ឆ្នាំ២០១៨ ប្រាក់សោធនអប្បបរមារបស់និវត្តជន ជនបាត់បង់សមត្ថភាពការងារ និងជនពិការ ត្រូវបានដំឡើងដល់៤៨០.០០០៛។ ក្នុងរយៈពេល៥ឆ្នាំនេះ អតីតយុទ្ធជននិងគ្រួសារប្រមាណ៨៧.៣៤១នាក់ និងអ្នកនៅក្នុងបន្ទុក១៤២.០៣២នាក់ កំពុងទទួលរបបសន្តិសុខសង្គម តាមប្រព័ន្ធធនាគារ។ ទន្ទឹមនេះ អតីតយុទ្ធជននិងគ្រួសារទទួលបានភាពងាយស្រួលតាមរយៈការដាក់ឱ្យដំណើរការ ការប្រើប្រាស់កាត ATM ការផ្ទេរសិទ្ធិបើកប្រាក់របបសន្តិសុខសង្គមជំនួសក្នុងករណីមានជំងឺឬចុះៈធ្ងន់ធ្ងរ នៅតាមរាជធានី ខេត្តទាំង២៥។ បានផ្តល់ប្រាក់គោលនយោបាយជូនអតីតយុទ្ធជនទទួលមរណភាព៣.៩៩៦នាក់។ បាននិងកំពុងសហការអនុវត្ត លើការផ្តល់នូវសេវាថែទាំសុខភាពសម្រាប់អតីតយុទ្ធជនដែលជានិវត្តជន ជនបាត់បង់សមត្ថភាពការងារ និងជនពិការ៥៤.៩៧៣នាក់ និងគ្រួសារពលី មរណៈ និងអ្នកក្នុងបន្ទុក៥៦.២១៨នាក់
- បានអនុវត្តគោលការណ៍ ស្តីពីការកំណត់អត្តសញ្ញាណកងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ និងគ្រួសារយុទ្ធជនពលី មរណៈ ដោយបានទទួលសំណុំលិខិតអ្នកដាក់ពាក្យស្នើសុំសម្បទានដីសង្គមកិច្ច១៣.២៦៥គ្រួសារ និងគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិបានផ្តល់សម្បទានដីសង្គមកិច្ចបាន៣.២៣៦គ្រួសារ។ បានបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជនឃុំ សង្កាត់១.០២៣ មានសមាជិកសរុបចំនួន២៤.៤០៤នាក់ នៃខេត្តចំនួន១៨ ដែលបានជួយកែលម្អជីវភាពរស់នៅរបស់អតីតយុទ្ធជន និងគ្រួសារឱ្យកាន់តែប្រសើរឡើងជាបន្តបន្ទាប់
- បានសហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជារៀបចំប្រារព្ធទិវាអតីតយុទ្ធជនកម្ពុជា២១មិថុនា ជារៀងរាល់ឆ្នាំ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ សមាគមអតីតយុទ្ធជនកម្ពុជាបានទទួលសំណុំបែបបទស្នើសុំប្រាក់បេឡាមរណសង្គ្រោះ និងបានចេញសេចក្តីសម្រេចប្រគល់ប្រាក់បេឡាមរណសង្គ្រោះជូនដល់គ្រួសារសពប្រមាណ៨.៩៧៩សព

---

[9] ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ទំព័រទី២៥

- រាជរដ្ឋាភិបាលកម្ពុជាបានឧបត្ថម្ភថវិកាចំនួន៤ពាន់លានរៀល/ឆ្នាំ ជូនដល់សមាគមអតីតយុទ្ធជនកម្ពុជា ដើម្បីប្រគល់ជូនដល់សមាជិកសមាគមអតីតយុទ្ធជនកម្ពុជាដែលបានទទួលមរណភាព ចាប់តាំងពីឆ្នាំ២០១៦
- បានសហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជាកសាងផ្ទះជូនអតីតយុទ្ធជន និងគ្រួសារបានចំនួន ៨៨៤ខ្នង និងសាលារៀន១ខ្នងស្មើ៦បន្ទប់
- បានរៀបចំ និងដាក់ឱ្យអនុវត្តសៀវភៅណែនាំ ស្តីពីនីតិវិធីប្រមូលទិន្នន័យពីស្ថានភាពជីវភាព និងតម្រូវការរបស់អតីតយុទ្ធជន និងគ្រួសារ ព្រមជាមួយគ្នានេះ បានបង្កើតប្រព័ន្ធទិន្នន័យរក្សាព័ត៌មានស្តីពីស្ថានភាពជីវភាព និងតម្រូវការរបស់អតីតយុទ្ធជននិងគ្រួសារ។

តារាងទី៧.លទ្ធផលសម្រេចបានការងារអាទិភាពទី៦

| ល.រ | សូចនាករ | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | 2014 | 2015 | 2016 | 2017 | 2018 | |
| 1 | អតីតយុទ្ធជននិងគ្រួសារដែលកំពុងទទួលរបប (នាក់) | 87,484 | 87,248 | 86,931 | 86,517 | 88,526 | |
| | - និវត្តជន (នាក់) | 23,888 | 25,078 | 25,643 | 26,479 | 27,101 | |
| | - ជនបាត់បង់សមត្ថភាពការងារ (នាក់) | 1,674 | 1,639 | 1,618 | 1,583 | 1,564 | |
| | - ជនពិការ (នាក់) | 26,962 | 26,286 | 25,977 | 26,501 | 27,205 | |
| | - ជនពលី (នាក់) | 29,943 | 28,537 | 27,587 | 25,645 | 25,732 | |
| | - ជនមរណៈ (នាក់) | 5,017 | 5,708 | 6,106 | 6,309 | 6,924 | |
| 2 | សមាជិក ស.អ.ក បានទទួលថវិកាបេឡាមរណសង្គ្រោះ(សព) | 1,200 | 3,055 | 1,129 | 899 | 2,696[10] | 8,979 |

**បញ្ហាប្រឈម៖**

- វិស័យអតីតយុទ្ធជននៅមានបញ្ហាប្រឈមដ៏ធំគឺ គម្លាតប្រាក់របបសន្តិសុខសង្គមប្រចាំខែ រវាងអ្នកចូលនិវត្តមុនឆ្នាំ២០១៥ រវាងជនពិការមុនឆ្នាំ២០១៥ និងការកំណត់តាវកាលិកសោធនសំរាប់មន្ត្រីរាជការ នគរបាល និងយោធិន មិនមានសង្គតិភាពនឹងគ្នា ដោយសារការកំណត់តាវកាលិកសោធនទាំងនោះត្រូវបានកំណត់ដោយច្បាប់ និងបទបញ្ញត្តិដោយឡែកពីគ្នា

[10] តួលេខសមាជិក ស.អ.ក បានទទួលថវិកាបេឡាមរណសង្គ្រោះនៅឆ្នាំ២០១៨ មានចំនួន២.៦៩៦សព ដោយមានការបូកបន្ថែមពីតួលេខលម្អៀងចុងឆ្នាំ២០១៥និងឆ្នាំ២០១៧ ដែលធ្វើឱ្យមានចំនួនច្រើនជាងតួលេខជាក់ស្តែង

- ក្រៅពីរបបសន្តិសុខសង្គមដែលផ្តល់ដោយរាជរដ្ឋាភិបាល អតីតយុទ្ធជននិងគ្រួសារ តែងទទួលការឧបត្ថម្ភគាំទ្រពីសមាគមអតីតយុទ្ធជនកម្ពុជា និងសប្បុរសជននានា ប៉ុន្តែទោះជាយ៉ាងនេះក្តីក៏មិនទាន់បានឆ្លើយតបបាន១០០% ទៅនឹងតម្រូវការចាំបាច់សម្រាប់ជីវភាពរស់នៅរបស់អតីតយុទ្ធជននិងគ្រួសារនៅឡើយ។ បេឡាជាតិអតីតយុទ្ធជន មានព័ត៌មានសម្រាប់តែគោលដៅរបបសន្តិសុខសង្គមដែលផ្តល់នូវតាវកាលិកផ្សេងៗដល់អតីតយុទ្ធជននិងគ្រួសារតែប៉ុណ្ណោះ។ ក្រសួង ស.អ.យ. មិនទាន់មានព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពជីវភាព និងតម្រូវការរបស់អតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជនដែលជាធាតុចូលយ៉ាងសំខាន់ ក្នុងការឆ្លើយតបនឹងការរៀបចំគម្រោងអភិវឌ្ឍន៍នានាដើម្បីលើកកម្ពស់ស្ថានភាពជីវភាពរបស់អតីតយុទ្ធជននិងគ្រួសារ ឱ្យមានជីវភាពរស់នៅសមរម្យ និងថ្លៃថ្នូរ
- តម្រូវការសម្បទានដីសង្គមកិច្ចមានច្រើន តែលទ្ធភាពក្នុងការឆ្លើយតបនៅមានកម្រិត។

## ការងារអាទិភាពទី៧៖ បង្កើតរបបសន្តិសុខសង្គមសម្រាប់ប្រជាជនទូទៅ

ក្រសួងបាននិងកំពុងសិក្សាស្រាវជ្រាវឯកសារនានា ដើម្បីរៀបចំបង្កើតប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់មជ្ឈដ្ឋាននានានិងប្រជាជនទូទៅ។

## ការងារអាទិភាពទី៨៖ ពង្រឹងសមត្ថភាពស្ថាប័ននិងពង្រឹងភាពជាដៃគូ

- ក្រសួងបានពង្រឹង និងពង្រីកសកម្មភាពវិទ្យាស្ថានជាតិសង្គមកិច្ច សំដៅបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ស្ថាប័នរដ្ឋ វិស័យឯកជន និងអង្គការ សមាគម មិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសដែលពាក់ព័ន្ធនឹងការងារសង្គមកិច្ច។ ក្នុងរយៈពេល៥ឆ្នាំនេះ វិទ្យាស្ថាន បាននិងកំពុងបណ្តុះបណ្តាលនិស្សិតកម្រិតឧត្តមសិក្សា១.៨៤៣នាក់ ដែលសិក្សាលើជំនាញសង្គមកិច្ច ជំនាញសង្គមវិទ្យា ជំនាញកិច្ចគាំពារសង្គម ជំនាញវិស្វកម្មសិប្បនិម្មិតនិងរណប ជំនាញគ្រប់គ្រងសាធារណៈ ជំនាញរដ្ឋបាលសាធារណៈ ជំនាញគោលនយោបាយសង្គម ជំនាញគោលនយោបាយសាធារណៈ និងជំនាញអក្សរសាស្ត្រអង់គ្លេស។ និស្សិតដែលបានប្រឡងជាប់ជាស្ថាពរថ្នាក់បរិញ្ញាបត្រចំនួន១៤១នាក់ និងសិក្ខាកាមដែលបានបញ្ចប់ការសិក្សាកម្រិតវិញ្ញាបនបត្រចំនួន៤៤១នាក់
- បានចុះអធិការកិច្ច និងសវនកម្ម ដើម្បីពិនិត្យ កែលម្អការបំពេញមុខងារ តួនាទី របៀបរបបការងារ ការដោះស្រាយជម្លោះ ការអនុវត្តចំណូល ចំណាយថវិកាជាតិ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅតាមមន្ទីរ ស.អ.យ. រាជធានី ខេត្ត សំដៅលើកកម្ពស់គណនេយ្យភាព តម្លាភាព ប្រសិទ្ធភាពនៃការផ្តល់សេវាសង្គមកិច្ចជូនជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទ
- បានអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយអនុវត្តការគ្រប់គ្រង ការបើកផ្តល់បានត្រឹមត្រូវ និងទាន់ពេលវេលាដល់គ្រប់មុខសញ្ញាក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព និងបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ
- ក្រសួងបានលើកទឹកចិត្ត និងសហប្រតិបត្តិការជាមួយអង្គការ សមាគម មិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស និងដៃគូអភិវឌ្ឍន៍នានា ក្នុងស្មារតីសាមគ្គីធម៌ និងកៀរគរប្រភពធនធានទាំងសម្ភារ ថវិកា និងបច្ចេកទេស បម្រើឱ្យសំណូមពររបស់ជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទក្នុងសង្គម ជាអាទិ៍ ក្រសួងបានចុះកិច្ចព្រមព្រៀងគម្រោងការជាមួយអង្គការ ១២៤អង្គការ ដែលមានថវិកាគម្រោង

សរុបចំនួន១៤៤.៧៤១.៦៦៥,៦០ដុល្លារអាមេរិក បើគិតក្នុងមួយឆ្នាំចំនួន៣៦.១៨៥.៤១៦,៤ដុល្លារអាមេរិក។ ទន្ទឹមនេះ ក៏បានធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធក្នុងក្របខ័ណ្ឌតំបន់អាស៊ាន ពាក់ព័ន្ធនឹងវិស័យសុខុមាលភាពសង្គម និងការអភិវឌ្ឍ រួមមាន ផែនការសកម្មភាពថ្នាក់តំបន់អាស៊ាន ស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី និងផែនការសកម្មភាពតំបន់អាស៊ាន ស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារ គោលការណ៍ណែនាំ ស្តីពីយេនឌ័រក្នុងការដោះស្រាយបញ្ហាស្ត្រីរងគ្រោះក្នុងការជួញដូរមនុស្ស សេចក្តីប្រកាសកូឡាឡាំពួរ ស្តីពីមនុស្សចាស់ "ផ្តល់សិទ្ធិអំណាចដល់មនុស្សចាស់នៅក្នុងតំបន់អាស៊ាន" ការអភិវឌ្ឍផែនការសកម្មភាពក្នុងការអនុវត្តសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការពង្រឹងកិច្ចគាំពារសង្គម។

តារាងទី៨.លទ្ធផលសម្រេចបានការងារអាទិភាពទី៨

| ល.រ | សូចនាករ | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | 2014 | 2015 | 2016 | 2017 | 2018 | |
| 1 | និស្សិតដែលបានចុះឈ្មោះចូលរៀនឆ្នាំទី១ (នាក់) | 53 | 69 | 73 | 59 | 155 | 409 |
| 2 | និស្សិតដែលកំពុងសិក្សាកម្រិតបរិញ្ញាបត្រ (នាក់) | 232 | 301 | 374 | 433 | 503 | 1,843 |
| 3 | និស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ (នាក់) | 0 | 0 | 33 | 88 | 20 | 141 |
| 4 | សិក្ខាកាមដែលបានបញ្ចប់ការសិក្សាកម្រិតវិញ្ញាបនបត្រ (នាក់) | 53 | 49 | 143 | 105 | 91 | 441 |

**បញ្ហាប្រឈម៖**

- សម្រាប់មន្ត្រី បុគ្គលិកសង្គមកិច្ច នៅពុំទាន់មានឯកសណ្ឋានផ្លូវការ ដែលធ្វើឱ្យមានការភ័ន្តច្រឡំនៅពេលចុះបម្រើការងារ
- ចំនួនមន្ត្រីដែលកំពុងបម្រើការងារនៅមានកំណត់ នៅតាមការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុកមួយចំនួននៅពុំទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ហើយការបំពេញក្របខ័ណ្ឌថ្មីមិនមានតុល្យភាពនឹងចំនួនមន្ត្រីចូលនិវត្តន៍ ជាពិសេស នៅថ្នាក់មន្ទីរ ស.អ.យ. រាជធានី ខេត្ត
- នៅតាមក្រុង ស្រុក នៃខេត្តមួយចំនួន ពុំទាន់មានការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ថវិកាគាំទ្រដល់ការចុះអធិការកិច្ច សវនកម្មផ្ទៃក្នុង និងការចុះពិនិត្យ តាមដានការអនុវត្តការងារ មានទំហំមិនសមស្របទៅនឹងតម្រូវការជាក់ស្តែង នាំឱ្យការវាយតម្លៃ ឆ្លុះបញ្ចាំងពីប្រសិទ្ធភាព ប្រសិទ្ធផល និងតម្រង់ទិសការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរ ស.អ.យ រាជធានី ខេត្ត មិនបានគ្រប់ជ្រុងជ្រោយ
- គ្មានប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមមុខសញ្ញារបស់ក្រសួង ដែលនាំឱ្យការកសាងផែនការសកម្មភាពមានភាពចន្លោះប្រហោង មិនអាចឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងបានពេញលេញ
- ថវិកាដែលបានវិភាជន៍សម្រាប់ក្រសួង មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែថវិកាទាំងនោះភាគច្រើន ចំណាយទៅលើរបបសន្តិសុខសង្គម និងបៀវត្សរ៍របស់មន្ត្រី

- ការលំហូរថវិកាពីអង្គភាពថវិកាទៅអង្គភាពអនុវត្តមានការយឺតយ៉ាវ ធ្វើឱ្យសកម្មភាពមួយចំនួនមិនអាចសម្រេចបានតាមគោលដៅ ជាពិសេសការអន្តរាគមន៍ផ្តល់សេវាសង្គ្រោះបន្ទាន់
- កង្វះថវិកាវិភាជន៍ មធ្យោបាយផ្សព្វផ្សាយ នៅជាបញ្ហាសំខាន់ ដែលចាំបាច់ត្រូវធ្វើការកែលម្អ ដើម្បីពង្រឹងសមត្ថភាពវិទ្យាស្ថាន និងទាក់ទាញការគាំទ្រពីសិស្ស និស្សិត អាណាព្យាបាល និងការទទួលស្គាល់ពីមជ្ឈដ្ឋានទូទៅ។

រូបទី២.ថវិការដ្ឋដែលបានវិភាជន៍រយៈពេល៥ឆ្នាំ ២០១៤-២០១៨ ឯកតា៖លានរៀល



# ជំពូកទី៣
# ទិសដៅយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## ៣.១. ចក្ខុវិស័យ

លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ ងាយរងគ្រោះ និងរក្សាបានស្ថិរភាពប្រាក់ចំណូល។

## ៣.២. បេសកកម្ម

អនុវត្តប្រព័ន្ធជាតិគាំពារសង្គម និងវិធានការផ្សេងៗឱ្យបានទូទាំងប្រទេស និងសម្រេចឱ្យបានភាគច្រើននូវភាពគ្របដណ្តប់នៃប្រព័ន្ធនេះដល់ប្រជាជនក្រីក្រ និងងាយរងគ្រោះ។

## ៣.៣. គោលបំណងយុទ្ធសាស្ត្រ

### ៣.៣.១.គោលបំណងគោលនយោបាយ

ផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ចតុកោណទី១ "ការអភិវឌ្ឍធនធានមនុស្ស" មុំទី៣ និងទី៤ និងស្ថិតនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផ.យ.អ.ជ. ជំពូក៤ លេខ៣.៣ និង៣.៤។

**មុំទី៣៖ ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ** ដើម្បីគាំទ្រការអភិវឌ្ឍធនធានមនុស្ស កំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គម ប្រកបដោយបរិភាព៖

- ការជំរុញវិសាលភាពគ្របដណ្តប់សុខភាពសកល នៅកម្ពុជា ដោយបង្កើនវិសាលភាពគ្របដណ្តប់នៃមូលនិធិសមធម៌សុខាភិបាល បន្តអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន និងរបបថែទាំសុខភាពសម្រាប់កម្មករនិយោជិត ដែលស្ថិតនៅក្រោមច្បាប់ស្តីពីការងារ និងដោយរៀបចំរបបថែទាំសុខភាពសម្រាប់បុគ្គលស្វ័យនិយោជន៍
- ការដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភស្ត្រីមានផ្ទៃពោះ និងកុមារក្រោមអាយុ២ឆ្នាំ នៃគ្រួសារក្រីក្រ ការរៀបចំកិច្ចអន្តរាគមន៍ផ្សេងៗ សំដៅលើកកម្ពស់អាហារូបត្ថម្ភ និងរៀបចំឱ្យមានយន្តការពហុវិស័យ ដោយមានការចូលរួមពីសហគមន៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៃតំបន់ដែលទទួលរងនូវកង្វះអាហារូបត្ថម្ភកម្រិតខ្ពស់។

**មុំទី៤៖ ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម** ដើម្បីលើកស្ទួយស្ថានភាពសង្គម-សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ

- ការជំរុញអនុវត្ត "ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥" ពិសេសដោយដាក់ឱ្យអនុវត្តនូវរបបហានិភ័យការងារមន្ត្រីសាធារណៈ និងរបបសោធនសម្រាប់កម្មករនិយោជិតដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ការកែទម្រង់របបសោធនសម្រាប់មន្ត្រីរាជការ ការធ្វើសមាហរណកម្មប្រតិបត្តិករប្រព័ន្ធសន្តិសុខសង្គម និងក្របខ័ណ្ឌអភិបាលកិច្ចគាំពារសង្គម ទន្ទឹមនឹងការជំរុញការអនុវត្តគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ និងគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០

- ការរៀបចំក្របខ័ណ្ឌគតិយុត្ត និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដើម្បីដាក់ឱ្យដំណើរការកម្មវិធីជាតិជំនួយសង្គមថ្មីៗ និងពង្រីកកម្មវិធីដែលមានស្រាប់ សំដៅបង្កើនការគាំពារបន្ថែមដល់ជនក្រីក្រ និងជនងាយរងគ្រោះ និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមថ្មី ព្រមទាំងពង្រីកវិសាលភាពលើរបបដែលមានស្រាប់ សំដៅបង្កើនការគាំពារដល់ប្រជាជនគ្រប់រូប។

## ៣.៣.២. គោលបំណងកម្មវិធី

| កម្មវិធីទី១ | ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម |
|---|---|

**គោលបំណង៖**

លើកកម្ពស់ការកែលម្អគុណភាព និងប្រសិទ្ធភាពសេវាសុខុមាលភាពសង្គមឱ្យកាន់តែប្រសើរឡើងជូនជនរងគ្រោះ និងងាយរងគ្រោះ ប្រកបដោយស្មើភាព តម្លាភាព និងគ្មានការរើសអើង។

| កម្មវិធីទី២ | ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ |
|---|---|

**គោលបំណង៖**

បង្កើនប្រសិទ្ធភាពនៃសេវាបើកផ្តល់របបសន្តិសុខសង្គមជូនអតីតមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ និងកែសម្រួលរបបគោលនយោបាយស្របតាមលទ្ធភាពនៃសេដ្ឋកិច្ចជាតិ។ ពង្រឹងពង្រីកការស្តារលទ្ធភាពពលកម្មកាយសម្បទា និងលើកកំពស់ជីវភាពជនពិការ។

| កម្មវិធីទី៣ | ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិបាលកិច្ចល្អ និងភាពជាដៃគូ |
|---|---|

**គោលបំណង៖**

បង្កើនប្រសិទ្ធភាពជំនាញ ពង្រឹងស្មារតីទទួលខុសត្រូវមនសិការវិជ្ជាជីវៈ របស់មន្ត្រីសង្គមកិច្ចគ្រប់កម្រិតអនុវត្តកម្មវិធីកំណែទម្រង់លើគ្រប់ផ្នែកឱ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសផ្ទេរមុខងារឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងពង្រឹងភាពជាដៃគូកៀរគរប្រភពធនធានទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីបង្កើនការផ្តល់សេវាសុខុមាលភាពសង្គមជូនជនរងគ្រោះ និងងាយរងគ្រោះ។

## ៣.៤. កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព

ដើម្បីថែរក្សាសមិទ្ធផលដែលក្រសួងសម្រេចបានកន្លងមក និងចូលរួមអនុវត្តឱ្យបានពេញលេញនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០៣០ ក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលឆ្នាំ ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០១៦-២០២៥ និងគោលនយោបាយជាតិស្ដីពីមនុស្សវ័យចាស់ឆ្នាំ ២០១៧-២០៣០ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានដាក់ចេញនូវកម្មវិធី ០៣ អនុកម្មវិធី១២ និងចង្កោមសកម្មភាពជាអាទិភាព រួមទាំងសកម្មភាពជាយុទ្ធសាស្ត្រមួយចំនួន។

រូបទី៣. គំនូសបំព្រួញផែនការយុទ្ធសាស្ត្រ



| កម្មវិធីទី១ | ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម |
|---|---|
| អនុកម្មវិធីទី១.១ | ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ |

- **គោលបំណង៖**

ពង្រឹងពង្រីកប្រសិទ្ធភាពនៃសេវាសុខុមាលភាពសង្គមជូនជនក្រីក្រ ជនអនាថា ជនវិកលចរិត ជនរងគ្រោះដោយគ្រោះមហន្តរាយធម្មជាតិ ជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ ជំងឺកាចសាហាវផ្សេងៗ និងជនចំណាកស្រុក។ ផ្តល់ និងសម្របសម្រួលសេវាស្តារ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

- **លទ្ធផលរំពឹងទុក៖**

ជនរងគ្រោះ និងងាយរងគ្រោះភាគច្រើនទទួលបានសេវាសង្គមពីភ្នាក់ងារផ្តល់សេវាទាំងរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានានៅឆ្នាំ២០២៣។

**ច.សទី១.១.១៖ លើកកម្ពស់សុខុមាលភាពជនរងគ្រោះនិងជនងាយរងគ្រោះ និងកិច្ចការគ្រួសារ**

- រៀបចំដាក់ឱ្យដំណើរការកម្មវិធីជាតិជំនួយសង្គមថ្មី និងការពង្រីកវិសាលភាពលើកម្មវិធីដែលមានស្រាប់ដើម្បីបង្កើនការគាំពារបន្ថែមដល់ជនក្រីក្រនិងងាយរងគ្រោះ តាមរយៈការសិក្សារៀបចំដាក់ឱ្យដំណើរការកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ និងកុមារ ដើម្បីឆ្លើយតបនឹងបញ្ហាកង្វះអាហារូបត្ថម្ភ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនក្រីក្រនិងងាយរងគ្រោះ
- ដោះស្រាយបញ្ហាជនអនាថាតាមរយៈការផ្តល់សេវាអប់រំផ្លូវចិត្ត ពិគ្រោះយោបល់ ការថែទាំសុខភាព ស្តារនីតិសម្បទា បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បង្កឱកាសស្តារជីវភាពនិងធ្វើសមាហរណកម្មទៅក្នុងសង្គម ដោយឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស ទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់តាមរយៈការផ្សព្វផ្សាយអប់រំ បញ្ជ្រាបការយល់ដឹង ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពសហគមន៍
- ពង្រឹងប្រសិទ្ធភាពនិងការគ្រប់គ្រងមជ្ឈមណ្ឌលសំចតសង្គមកិច្ច
- បញ្ចប់ការកសាង និងដាក់ឱ្យដំណើរការមជ្ឈមណ្ឌលព្យាបាលនិងថែទាំជនវិបល្លាសស្មារតី
- ផ្តល់សេវាថែទាំគាំទ្រ និងសង្គ្រោះជនរងគ្រោះ និងជនរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ
- អនុវត្តកម្មវិធីអភិវឌ្ឍគ្រួសារល្អ ការចិញ្ចឹមកូនបែបវិជ្ជមាន ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងរៀបចំទិវាអន្តរជាតិ ស្តីពីគ្រួសារ ១៥ឧសភា
- សិក្សានិងរៀបចំគោលនយោបាយជាតិ ស្តីពីគ្រួសារ
- បញ្ជ្រាបការងារយេនឌ័រទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងលើកកម្ពស់តួនាទីស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល
- សិក្សាដាក់ឱ្យដំណើរការការចុះបញ្ជីបុគ្គលិកសង្គមកិច្ច

- បន្តយកចិត្តទុកដាក់ដល់ប្រជាជនដែលគ្មានដីនឹងទទួលបានដីសម្រាប់សង់លំនៅឋាន និងបង្កបង្កើនផល តាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ច
- សិក្សានិងរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះគ្រប់ប្រភេទ និងទម្រង់ក្នុងការប្រមូលទិន្នន័យឱ្យបានច្បាស់។

**ច.សទី១.១.២៖ ផ្តល់កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ**

- ផ្តល់សេវាការពារផ្លូវច្បាប់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភផ្លូវភេទ
- ប្រឹក្សាយោបល់ បញ្ជូនទៅស្តារនីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភផ្លូវភេទ ធ្វើសមាហរណកម្ម និងតាមដានជនរងគ្រោះ
- បង្កើត និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យជនរងគ្រោះដោយអំពើជួញដូរមនុស្ស (Database Management System for Victims of Human Trafficking) ដើម្បីបង្កើតប្រសិទ្ធភាពក្នុងការជួយគាំពារ និងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- ទទួល និងធ្វើមាតុភូមិនិវត្តជនរងគ្រោះដោយអំពើជួញដូរមនុស្សដោយគ្មានការមាក់ងាយ និងរើសអើង
- ដាក់ឱ្យដំណើរការមជ្ឈមណ្ឌលសំចតប៉ោយប៉ែតសម្រាប់ទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- កសាងមជ្ឈមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅប៉ោយប៉ែត
- រៀបចំ និងដាក់ឱ្យប្រើប្រាស់នូវបទដ្ឋាន ស្តីពីនីតិវិធីប្រតិបត្តិ សម្រាប់ការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សរវាងកម្ពុជា-ថៃ
- ត្រួតពិនិត្យ និងកែសម្រួលឡើងវិញនូវបទដ្ឋាន ស្តីពីនីតិវិធីប្រតិបត្តិ សម្រាប់ទទួល និងបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ឆ្នាំ២០១០
- សហការជាមួយសាលាដំបូង ទាំង២៥ រាជធានី ខេត្ត ក្នុងករណីអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ អំពើរំលោភបំពានលើកុមារ និងយុត្តិធម៌អនីតិជន។

តារាងទី៩.ចំណុចដៅនៃសូចនាករអនុកម្មវិធីទី១.១

| ល.រ | សូចនាករ | ឯកតា | 2019 | 2020 | 2021 | 2022 | 2023 | សរុប |
|---|---|---|---|---|---|---|---|---|
| 1 | គ្រួសាររងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះមហន្តរាយ នៅតាមសហគមន៍ បានទទួលជំនួយសង្គ្រោះបន្ទាន់ | គ្រួសារ | 66,096 | 67,418 | 68,866 | 70,243 | 71,648 | 344,271 |
| 2 | ជនអនាថាដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | 968 | 823 | 700 | 595 | 506 | 3,592 |
| 3 | ជនអនាថាដែលទទួលបានសេវាគាំពារ | នាក់ | 2,567 | 2,800 | 3,033 | 3,266 | 3,499 | 15,165 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 4 | ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារផ្ទុកមេរោគអេដស៍ជំងឺអេដស៍ដែលទទួលសេវាថែទាំគាំទ្រតាមសហគមន៍ | នាក់ | 2,167 | 2,276 | 2,389 | 2,509 | 2,634 | 11,975 |
| 5 | ជនរំលោភសេពគ្រឿងញៀន ទទួលបានសេវាព្យាបាល និងថែទាំ ក្នុងមជ្ឈមណ្ឌល | នាក់ | 110 | 121 | 133 | 146 | 161 | 671 |
| 6 | ស្ត្រីមានផ្ទៃពោះនៅក្នុងគ្រួសារក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ | នាក់ | 36,000 | 72,000 | 72,000 | 72,000 | 72,000 | 324,000 |
| 7 | កុមារអាយុ ០-២ឆ្នាំ នៅក្នុងគ្រួសារក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ | នាក់ | 18,000 | 108,000 | 180,000 | 144,000 | 144,000 | 594,000 |
| 8 | ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភ ទទួលបានការស្តារនីតិសម្បទា | នាក់ | 300 | 250 | 250 | 250 | 250 | 1,300 |
| 9 | ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដែលត្រូវបានគាំពារ និងជួយសង្គ្រោះ | នាក់ | 300 | 220 | 220 | 220 | 220 | 1,180 |
| 10 | ជនរងគ្រោះដោយអំពើជួញដូរមនុស្សបានធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសខ្លួនវិញ | នាក់ | 10 | 10 | 10 | 10 | 10 | 50 |
| 11 | ជនរងគ្រោះដោយអំពើជួញដូរមនុស្សបានធ្វើមាតុភូមិនិវត្តន៍ពីក្រៅប្រទេស | នាក់ | 350 | 220 | 220 | 220 | 220 | 1,230 |
| 12 | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានធ្វើសមាហរណកម្មទៅតាមសហគមន៍វិញ | នាក់ | 300 | 220 | 220 | 220 | 220 | 1,180 |
| 13 | ជនរងគ្រោះដោយអំពើជួញដូរមនុស្សទទួលបានសេវាក្រោយធ្វើសមាហរណកម្ម | នាក់ | 300 | 200 | 200 | 200 | 200 | 1,100 |
| 14 | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានបិទករណី | នាក់ | 150 | 150 | 150 | 150 | 150 | 750 |

## អនុកម្មវិធីទី១.២ ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទា

○ **គោលបំណង៖**

ពង្រឹងពង្រីកប្រសិទ្ធភាពនៃសេវាថែទាំកុមារកំព្រា និងកុមារងាយរងគ្រោះនៅក្នុងមណ្ឌល និងតាមសហគមន៍ ផ្តល់កិច្ចការពារសិទ្ធិតាមផ្លូវច្បាប់ចំពោះអនីតិជនប្រព្រឹត្តបទល្មើសនៅតាមសហគមន៍ និង

ក្នុងពន្ធនាគារ និងផ្តល់ការព្យាបាលនិងស្តារនីតិសម្បទាជូនជនរងគ្រោះដែលប្រើប្រាស់បំពានគ្រឿងញៀន ដោយគោរពសិទ្ធិទាំងបួនរបស់កុមារ និងសិទ្ធិរបស់ជនរងគ្រោះ។

- **លទ្ធផលរំពឹងទុក៖**

កុមាររងគ្រោះ និងងាយរងគ្រោះភាគច្រើនទទួលបានសេវាថែទាំជំនួស ស្តារនីតិសម្បទា និងកិច្ចការពារសិទ្ធិតាមផ្លូវច្បាប់ដោយគោរពសិទ្ធិទាំងបួនរបស់កុមារនៅឆ្នាំ២០២៣។ ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនទទួលបានសេវាបន្សាប ព្យាបាល និងស្តារនីតិសម្បទា នៅតាមមជ្ឈមណ្ឌលមុនធ្វើសមាហរណកម្មទៅសហគមន៍វិញ។

**ច.សទី១.២.១៖ ពង្រឹងគុណភាពសេវាថែទាំកុមារក្នុងមណ្ឌល និងពង្រីកសេវាថែទាំកុមារតាមសហគមន៍**

- បង្កើត និងដាក់ឱ្យដំណើរការប្រព័ន្ធទិន្នន័យថ្នាក់ជាតិដើម្បីគ្រប់គ្រងទិន្នន័យកុមាររងគ្រោះនិងងាយរងគ្រោះដែលប្រឈមទៅនឹងការបំបែកពីគ្រួសារ និងកុមារដែលកំពុងទទួលបានសេវាថែទាំ
- លើកកម្ពស់សមត្ថភាពនៃការគ្រប់គ្រងមណ្ឌលថែទាំកុមារ ដោយផ្តោតលើគុណភាពសេវា ការគ្រប់គ្រងករណី ការបង្រួបបង្រួមគ្រួសារ និងសមាហរណកម្ម
- ធ្វើអធិការកិច្ចកន្លែង ឬមណ្ឌលថែទាំកុមារ និងការថែទាំកុមារតាមសហគមន៍ឱ្យស្របតាមបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ
- ពង្រឹងពង្រីកកម្មវិធីការបង្រួបបង្រួមគ្រួសារ ការបង្វែរ និងសមាហរណកម្មកុមារពីមណ្ឌលទៅជាការថែទាំនៅតាមគ្រួសារ និងសហមគន៍
- ពង្រឹងពង្រីកគុណភាពសេវាថែទាំកុមារនៅតាមគ្រួសារនិងសហគមន៍ដោយផ្តោតលើកុមារដែលបានបង្រួបបង្រួមគ្រួសារ និងកុមារកំពុងស្នាក់នៅកន្លែងថែទាំ រួមទាំងការថែទាំដោយឪពុកម្តាយធម៌ ការថែទាំដោយសាច់ញាតិ ការថែទាំពេលថ្ងៃនិងពេលយប់ និងអប់រំអំពីការចិញ្ចឹមកូនបែបវិជ្ជមាន
- សម្របសម្រួល និងជំរុញការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ តាមរយៈការបង្កើតយន្តការ និងប្រព័ន្ធកិច្ចការពារកុមារ
- រៀបចំកិច្ចព្រមព្រៀងរវាងប្រទេសកម្ពុជា និងភាគីថៃ ដើម្បីទទួល ឬផ្ទេរកុមារ ក្នុងការធ្វើផែនការអចិន្ត្រៃយ៍ចំពោះកុមារ
- ពង្រឹងពង្រីកផែនការអចិន្ត្រៃយ៍ ដោយផ្តោតលើការគាំទ្រគ្រួសារ ការថែទាំដោយឪពុកម្តាយធម៌ និងសុំកូនក្នុងប្រទេស។

**ច.សទី១.២.២៖ ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងរបាយការណ៍ ស្តីពីស្ថានភាពកុមារ**

- រៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារឆ្នាំ ២០១៩-២០២៣ សំដៅលើកកម្ពស់សិទ្ធិ ឧត្តមប្រយោជន៍របស់កុមារនិងយកចិត្តទុកដាក់ស្ថានភាពកុមារក្នុងគ្រួសារក្រីក្រ
- អនុវត្តអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិកុមារ តាមរយៈការរៀបចំរបាយការណ៍ជាតិ ស្តីពីការអនុវត្តសិទ្ធិកុមារ និងរបាយការណ៍ ស្តីពីការអនុវត្តពិធីសារបន្ថែមផ្សេងៗទៀត

- ពិនិត្យតាមដានការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ២០១៧-២០២១
- បន្តជំរុញ និងលើកកម្ពស់ការអនុវត្តសិទ្ធិកុមារតាមរយៈការពង្រឹងសមត្ថភាពមន្ត្រីរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាល និងផ្សព្វផ្សាយសិទ្ធិកុមារឱ្យបានទូលំទូលាយ
- រៀបចំបង្កើតគោលនយោបាយស្តីពីប្រព័ន្ធកិច្ចការពារកុមារ និងច្បាប់ស្តីពីកិច្ចការពារកុមារនៅកម្ពុជា
- រៀបចំ និងផ្សព្វផ្សាយ លិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធសិទ្ធិ និងការការពារកុមារ
- បណ្តុះបណ្តាលជំនាញពាក់ព័ន្ធនឹងការងារក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- រៀបចំទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា។

**ច.សទី១.២.៣៖ អនុវត្តការងារសុំកូនអន្តរប្រទេស ដោយធានាឧត្តមប្រយោជន៍និងការពារសិទ្ធិជាមូលដ្ឋានរបស់កុមារ**

- បង្កើនកិច្ចសហប្រតិបត្តិការជាមួយប្រទេសទទួល លើកិច្ចការពារកុមារទាក់ទងនឹងសុំកូនអន្តរប្រទេស
- ផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលមានវិជ្ជាជីវៈ គុណវុឌ្ឍិ និងក្រមសីលធម៌ត្រឹមត្រូវ ក្នុងការធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស
- លើកទឹកចិត្តជំរុញអនុវត្តការងារសុំកូនអន្តរប្រទេសដោយធានាឧត្តមប្រយោជន៍ និងការពារសិទ្ធិជាមូលដ្ឋានរបស់កុមារ ស្របតាមច្បាប់ ស្តីពីសុំកូនអន្តរប្រទេស
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាល ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ស្តីពីសុំកូនអន្តរប្រទេស។

**ច.សទី១.២.៤៖ ស្តារនីតិសម្បទាអនីតិជនដែលទំនាស់នឹងច្បាប់**

- បង្កើតមណ្ឌលយុវនីតិសម្បទា រៀបចំរចនាសម្ព័ន្ធ និងរៀបចំលិខិតបទដ្ឋានដើម្បីដំណើរការ
- រៀបចំកម្មវិធីបណ្តុះបណ្តាល បំណិនជីវិត និងជំនាញវិជ្ជាជីវៈដល់អនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា
- ផ្សព្វផ្សាយ អប់រំកុមារ យុវជន ទប់ស្កាត់បាតុភាពអសកម្មនានាក្នុងសង្គម រួមចំណែកលើកស្ទួយសីលធម៌ សុជីវធម៌ និងការពារសិទ្ធិរបស់កុមារ និងជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន និងអនីតិជនទំនាស់នឹងច្បាប់
- ផ្តល់សេវាសង្គមកិច្ចដល់កុមារតាមម្តាយក្នុងពន្ធនាគារ
- ផ្សព្វផ្សាយនិងដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រនិងផែនការប្រតិបត្តិដើម្បីអនុវត្តច្បាប់ ស្តីពីយុត្តិធម៌អនីតិជន
- បញ្ចប់ការរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលការណ៍សម្រាប់ការអនុវត្តផែនការបង្វែរ និងរចនាសម្ព័ន្ធភ្នាក់ងារសង្គមកិច្ចពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជន។

**ច.សទី១.២.៥៖ ស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន**

- ទទួល ព្យាបាល បន្សាប ស្តារនីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន នៅក្នុងមណ្ឌល
- លើកទឹកចិត្តការព្យាបាល និងស្តារនីតិសម្បទាជនរងគ្រោះដែលប្រើប្រាស់បំពានសារធាតុញៀននៅតាមសហគមន៍ និងលើកកម្ពស់ការចូលរួមទទួលខុសត្រូវ របស់ឪពុកម្តាយសាច់ញាតិ។

តារាងទី១០.ចំណុចដៅនៃសូចនាករអនុកម្មវិធីទី១.២

| ល.រ | សូចនាករ | ឯកតា | 2019 | 2020 | 2021 | 2022 | 2023 | សរុប |
|---|---|---|---|---|---|---|---|---|
| 15 | កុមារកំព្រា និង កុមារងាយរងគ្រោះដែលរស់នៅក្នុងមណ្ឌលថែទាំកុមារ | នាក់ | 7,481 | 7,336 | 7,189 | 7,045 | 6,904 | |
| 16 | កុមារកំព្រា និង កុមារងាយរងគ្រោះដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | 1,163 | 1,186 | 1,210 | 1,234 | 1,296 | 6,089 |
| 17 | កុមាររងគ្រោះដែលទទួលបានការថែទាំដោយក្រុមគ្រួសារ និងសហគមន៍ | នាក់ | 10,771 | 10,794 | 10,818 | 10,842 | 10,904 | |
| 18 | កុមារដែលត្រូវបានសុំកូនអន្តរប្រទេស | នាក់ | 10 | 15 | 15 | 15 | 15 | 70 |
| 19 | ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលទទួលបានការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស | ទីភ្នាក់ងារ | 2 | 2 | 2 | 2 | 2 | 10 |
| 20 | អនីតិជនប្រព្រឹត្តល្មើសច្បាប់ដែលជាប់ក្នុងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែ និងមណ្ឌលយុវនីតិសម្បទាទទួលបានសេវាស្តារនីតិសម្បទា | នាក់ | 500 | 500 | 500 | 500 | 500 | 2,500 |
| 21 | កូនតាមម្តាយដែលមានអាយុចាប់ពី៣ (បី) ឆ្នាំឡើងទៅនៅក្នុងពន្ធនាគារបានទទួលសេវាសង្គមកិច្ច | នាក់ | 20 | 20 | 20 | 20 | 20 | 100 |
| 22 | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនបានស្តារនីតិសម្បទា | នាក់ | 4,000 | 3,800 | 3,500 | 3,500 | 3,500 | 18,300 |
| 23 | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | 500 | 500 | 500 | 500 | 500 | 2,500 |

## អនុកម្មវិធីទី១.៣ ការអភិវឌ្ឍសុខុមាលភាពជនពិការ

- **គោលបំណង៖**

លើកកម្ពស់សិទ្ធិជនពិការ និងលុបបំបាត់ការរើសអើងចំពោះជនពិការ។ អភិវឌ្ឍភាសាសញ្ញា អក្សរស្ទាប ពង្រឹងពង្រីកប្រសិទ្ធភាពសេវាស្តារលទ្ធភាពពលកម្ម បណ្តុះបណ្តាលវិជ្ជាជីវៈ អភិវឌ្ឍមុខរបរខ្នាតតូចជូនជនពិការ លើកទឹកចិត្តចលនាកីឡា និងសិល្បៈរបស់ជនពិការ ដើម្បីលើកកម្ពស់ជីវភាព និងសេចក្តីថ្លៃថ្នូ ទទួលបានឱកាសចូលរួមក្នុងកិច្ចការសង្គម។

- **លទ្ធផលរំពឹងទុក៖**

ជនពិការភាគច្រើនទទួលបានសេវាអភិវឌ្ឍជំនាញវិជ្ជាជីវៈ ស្តារលទ្ធភាពពលកម្មគ្រប់ប្រភេទ និងជនពិការក្រីក្រនៅតាមសហគមន៍ចំនួន ២២.២២៨នាក់ នឹងទទួលបានរបបឧបត្ថម្ភគោលនយោបាយនៅឆ្នាំ២០២៣។

**ច.សទី១.៣.១៖ បង្កើនប្រសិទ្ធភាពផ្តល់សេវាសុខុមាលភាពជនពិការ និងលើកកម្ពស់សិទ្ធិជនពិការ**

- រៀបចំប្រព័ន្ធទិន្នន័យគ្រប់គ្រងជនពិការឱ្យបានជាក់លាក់
- អនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនពិការក្រីក្រនៅតាមសហគមន៍
- បណ្តុះបណ្តាលវិជ្ជាជីវៈ និងបង្កើតមុខរបរដល់ជនពិការ
- សម្របសម្រួល ត្រួតពិនិត្យ និងជំរុញឱ្យក្រសួង ស្ថាប័នរដ្ឋ និងសហគ្រាសឯកជនអនុវត្តកាតព្វកិច្ចទទួលជនពិការចូលបម្រើការងារ
- សម្របសម្រួល និងជំរុញឱ្យក្រសួង ស្ថាប័នរដ្ឋ និងសហគ្រាសឯកជនអនុវត្តកាតព្វកិច្ចរៀបចំលក្ខណៈងាយស្រួល (Accessibility) សម្រាប់ជនពិការបំលាស់ទី
- លើកទឹកចិត្តចលនាកីឡា សិល្បៈរបស់ជនពិការ ការងារផ្សព្វផ្សាយព័ត៌មានជាភាសាសញ្ញា
- សហការជាមួយអង្គការដៃគូក្នុងការអភិវឌ្ឍ និងបណ្តុះបណ្តាលអក្សរស្ទាប និងភាសាសញ្ញា។

**ច.សទី១.៣.២៖ ពង្រឹងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ ច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ យុទ្ធសាស្ត្រ ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត**

- រៀបចំ និងដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព ២០១៩-២០២៣
- ផ្តល់សេវាផ្លូវច្បាប់សម្រាប់ជនពិការដែលមានតម្រូវការចាំបាច់ ដោយសហការជាមួយស្ថាប័នតុលាការ មន្ត្រីយុត្តិធម៌ និងបុគ្គលិកពន្ធនាគារ
- រៀបចំរបាយការណ៍ ស្តីពីការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិជនពិការ យុទ្ធសាស្ត្រអ៊ីនឈាន់ និងពិធីសារបន្ថែមផ្សេងៗ
- ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិជនពិការ
- រៀបចំទិវាជនពិការជាតិ អន្តរជាតិ និងទិវាផ្សេងៗពាក់ព័ន្ធជនពិការ
- អនុវត្តស្តង់ដាអប្បបរមានៃការបង្កលក្ខណៈងាយស្រួលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មធ្យោបាយធ្វើដំណើរ និងទំនាក់ទំនងសម្រាប់ជនពិការ
- បញ្ជ្រាបការយល់ដឹងអំពីសមត្ថភាពបើកបរ និងផ្តល់ប័ណ្ណបើកបរសម្រាប់ជនពិការ
- សហការជាមួយ គ.ជ.ប. ដើម្បីបង្កលក្ខណៈឱ្យជនពិការកាន់តែងាយស្រួលចូលរួមក្នុងការបោះឆ្នោត
- ផលិត បោះពុម្ព និងផ្សព្វផ្សាយលិខិត បទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងពិការភាព។

តារាងទី១១.ចំណុចដៅនៃសូចនាករអនុកម្មវិធីទី១.៣

| ល.រ | សូចនាករ | ឯកតា | 2019 | 2020 | 2021 | 2022 | 2023 | សរុប |
|---|---|---|---|---|---|---|---|---|
| 24 | ជនពិការក្រីក្រនៅតាមសហគមន៍ទទួលបានរបបឧបត្ថម្ភគោលនយោបាយ[11] | នាក់ | 10,228 | 13,228 | 16,228 | 19,228 | 22,228 | |

[11] លទ្ធផលបូកបន្តសម្រាប់ជនពិការក្រីក្រនៅតាមសហគមន៍ទទួលបានរបបឧបត្ថម្ភគោលនយោបាយ

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 25 | ជនពិការទទួលបានការបណ្តុះ-បណ្តាលវិជ្ជាជីវៈ | នាក់ | 590 | 590 | 590 | 590 | 590 | 2,950 |
| 26 | ជនពិការត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារនៅតាមស្ថាប័នរដ្ឋ (២%) | នាក់ | 30 | 30 | 30 | 30 | 30 | 150 |
| 27 | ជនពិការត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារនៅតាមស្ថាប័នឯកជន (១%) | នាក់ | 3,500 | 3,500 | 3,500 | 3,500 | 3,500 | 17,500 |

## អនុកម្មវិធីទី១.៤ ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់

- **គោលបំណង៖**

ពង្រឹងពង្រីកប្រសិទ្ធភាពសេវាថែទាំមនុស្សចាស់នៅតាមគ្រួសារ និងសមាគមមនុស្សចាស់តាមឃុំ សង្កាត់ លើកទឹកចិត្តដល់សហគមន៍ អារាមសាសនាជាពិសេសព្រះពុទ្ធសាសនា និងសាសនាដទៃទៀត ក្នុងការជួយដល់សាសនិកដែលជាជនចាស់ជរាបានជ្រកកោន។

- **លទ្ធផលរំពឹងទុក៖**

មនុស្សវ័យចាស់ទីទ័លក្រ ជួបការលំបាកភាគច្រើននៅតាមសហគមន៍ទទួលបានសេវាគាំពារពីភ្នាក់ងារផ្តល់សេវារបស់រដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនៅឆ្នាំ២០២៣។

### ច.សទី១.៤.១៖ ពង្រឹងសកម្មភាពសមាគមមនុស្សចាស់ តាមឃុំ សង្កាត់

- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់សមាគមមនុស្សចាស់
- ពង្រឹងសមត្ថភាពគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ និងអនុគណៈកម្មាធិការដើម្បីមនុស្សចាស់ថ្នាក់រាជធានី ខេត្ត
- លើកទឹកចិត្តសប្បុរសជនបង្កើតកម្មវិធីមនុស្សធម៌ជួយដល់ជនចាស់ជរាក្រីក្រ
- ផ្តល់កិត្តិយស និងលើកទឹកចិត្តដល់មនុស្សចាស់គំរូ (ផ្តល់ពានរង្វាន់ ឬ វិញ្ញាបនបត្រទទួលស្គាល់ស្នាដៃ)
- រៀបចំកម្មវិធីប្រកួតប្រជែងស្នាដៃរបស់មនុស្សចាស់ ព្រមទាំងបង្កើតទីតាំងសម្រាប់លក់សមិទ្ធផលរបស់មនុស្សចាស់
- បញ្ចប់ការរៀបចំលក្ខន្តិកៈសមាគមមនុស្សចាស់ ដើម្បីគ្រប់គ្រងនិងដំណើរការសមាគមមនុស្សចាស់ឱ្យបានប្រសើរ។

### ច.សទី១.៤.២៖ សិក្សា និងបង្កើតកម្មវិធីគាំពារមនុស្សចាស់ជរា

- រៀបចំប្រព័ន្ធទិន្នន័យគ្រប់គ្រងមនុស្សចាស់ឱ្យបានជាក់លាក់
- កំណត់លក្ខណៈវិនិច្ឆ័យអ្នកទទួលផល និងកម្រិតអត្ថប្រយោជន៍
- សិក្សាដាក់ឱ្យអនុវត្តកម្មវិធីគាំពារមនុស្សចាស់ជរាក្នុងខេត្តអាទិភាព និងពង្រីកវិសាលភាពគ្របដណ្តប់ទូទាំងប្រទេស

- បង្កើត និងដាក់ឱ្យដំណើរការមូលនិធិទ្រទ្រង់មនុស្សចាស់
- បង្កើត និងដាក់ឱ្យដំណើរការមជ្ឈមណ្ឌលជាតិគាំពារមនុស្សចាស់ ដើម្បីផ្តល់សេវាថែទាំមនុស្សចាស់ជរា
- រៀបចំបណ្តុះបណ្តាលវិជ្ជាជីវៈលើជំនាញចិត្តសាស្ត្រ និងបច្ចេកទេសថែទាំមនុស្សចាស់សម្រាប់អ្នកថែទាំ អ្នកធ្វើកិច្ចការសង្គម និងអ្នកស្ម័គ្រចិត្ត
- សិក្សារៀបចំគោលនយោបាយ ស្តីពីការថែទាំរយៈពេលវែង
- អនុវត្តគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ តាមរយៈការរៀបចំ និងតាមដានការអនុវត្តផែនការសកម្មភាពជាតិ ២០១៧-២០២០។

តារាងទី១២.ចំណុចដៅនៃសូចនាករអនុកម្មវិធីទី១.៤

| ល.រ | សូចនាករ | ឯកតា | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|---|---|
| 28 | អត្រាមនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានសេវាថែទាំនៅតាមសហគមន៍ | % | 2% | 3% | 4% | 5% | 6% |
| 29 | មនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានសេវាថែទាំក្នុងមជ្ឈមណ្ឌលគាំពារមនុស្សចាស់ | នាក់ | 30 | 50 | 80 | 100 | 130 |
| 30 | មនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានគោលរបបគាំពារសង្គម | នាក់ | 6,250 | 7,500 | 8,750 | 10,000 | 11,250 |

## អនុកម្មវិធីទី១.៥ ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន

- **គោលបំណង៖**

ពង្រឹងពង្រីកប្រសិទ្ធភាពនៃការផ្តល់ប្រាក់បេឡាមរណសង្គ្រោះ ការបណ្តុះបណ្តាលវិជ្ជាជីវៈជូនអតីតយុទ្ធជន និងកូនអតីតយុទ្ធជន លើកកម្ពស់ជីវភាពរស់នៅរបស់អតីតយុទ្ធជន និងគ្រួសារឱ្យកាន់តែល្អប្រសើរ។

- **លទ្ធផលរំពឹងទុក៖**

អតីតយុទ្ធជន និងគ្រួសារភាគច្រើនទទួលបានការលើកកម្ពស់ជីវភាពរស់នៅកាន់តែល្អប្រសើរឡើងនៅឆ្នាំ២០២៣។

### ច.សទី១.៥.១៖ អភិវឌ្ឍសហគមន៍អតីតយុទ្ធជន

- បន្តបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជនឃុំ សង្កាត់ សំដៅទ្រទ្រង់ជីវភាពអតីតយុទ្ធជន និងគ្រួសារ
- កំណត់អត្តសញ្ញាណអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ សម្រាប់ស្នើសុំសម្បទានដីសង្គមកិច្ច
- អនុវត្តគម្រោងអភិវឌ្ឍន៍អតីតយុទ្ធជន ឃុំ សង្កាត់
- បណ្តុះបណ្តាលគ្រូបង្គោល ស្តីពីនីតិវិធីប្រមូលទិន្នន័យពីស្ថានភាពជីវភាព និងតម្រូវការរបស់អតីតយុទ្ធជន និងគ្រួសារ នៅតាមសហគមន៍ឃុំ សង្កាត់។

**ច.សទី១.៥.២៖ សម្របសម្រួលការងារសមាគមអតីតយុទ្ធជននៅថ្នាក់ឃុំ សង្កាត់**

- សហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជា ដើម្បីពង្រឹងការអនុវត្តបេឡាមរណសង្គ្រោះ ការសាងសង់ផ្ទះ និងការអភិវឌ្ឍសហគមន៍អតីតយុទ្ធជន
- រៀបចំទិវាអតីតយុទ្ធជនកម្ពុជា ២១មិថុនា នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជារៀងរាល់ឆ្នាំ។

| អនុកម្មវិធីទី១.៦ | ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គមរាជធានី ខេត្ត |
|---|---|

- **គោលបំណង៖**

លើកកម្ពស់ការកែលម្អគុណភាព និងប្រសិទ្ធភាពសេវាសុខុមាលភាពសង្គមឱ្យកាន់តែប្រសើរឡើងជូនជនរងគ្រោះ និងងាយរងគ្រោះប្រកបដោយស្មើភាព តម្លាភាព និងគ្មានការរើសអើងនៅថ្នាក់រាជធានី ខេត្ត។

- **លទ្ធផលរំពឹងទុក៖**

ជនរងគ្រោះ និងងាយរងគ្រោះភាគច្រើននៅតាមសហគមន៍ទទួលបានសេវាសុខុមាលភាពសង្គមប្រកបដោយគុណភាពគ្មានការរើសអើងនៅឆ្នាំ២០២៣។

**ច.សទី១.៦.១៖ បង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម រាជធានី ខេត្ត**

- បង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ
- ពង្រឹងពង្រីកប្រសិទ្ធភាពសេវាសុខុមាលភាពកុមារ និងយុវនីតិសម្បទា
- ពង្រឹងពង្រីកសេវាសុខុមាលភាពជនពិការ
- ពង្រឹងពង្រីកសេវាសុខុមាលភាពមនុស្សចាស់
- ពង្រឹងពង្រីកសេវាសុខុមាលភាពអតីតយុទ្ធជន

| កម្មវិធីទី២ | ការបង្កើនប្រសិទ្ធិភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ |
|---|---|
| អនុកម្មវិធីទី២.១ | ការអភិវឌ្ឍសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលប្រកបដោយប្រសិទ្ធភាព |

- **គោលបំណង៖**

ពង្រឹងពង្រីកសេវាសុខុមាលភាពសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល ដោយអនុវត្តលើតាវកាលិក ៦មុខ រួមមាន៖ ការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ មរណភាព និងអ្នកនៅក្នុងបន្ទុក។

- **លទ្ធផលរំពឹងទុក៖**

និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុកចំនួន ១២២.៥៣៥នាក់ នឹងទទួលបានរបបសន្តិសុខសង្គមនៅឆ្នាំ២០២៣។

### ច.សទី២.១.១៖ ផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលជូនសិទ្ធិវន្តនៃ ប.ជ.ស.

- ពង្រឹង និងបង្កើនប្រសិទ្ធភាពផ្នែកសោធន តាមរយៈការបើកផ្តល់របបសន្តិសុខសង្គមជូននិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក និងបង្កើតយន្តការសិក្សាស្រាវជ្រាវបន្ថែមដើម្បីកាត់បន្ថយគម្លាតនៃរបបសោធនរបស់មន្ត្រីសាធារណៈ
- ដាក់ឱ្យអនុវត្តគោលការណ៍គ្រោះថ្នាក់ការងារ មាតុភាព និងមរណភាព សម្រាប់មន្ត្រីរាជការស៊ីវិល
- គ្រប់គ្រងហិរញ្ញប្បទានសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងកែសម្រួលរបបសន្តិសុខសង្គមជូននិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក
- សម្របសម្រួលអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិគាំពារសង្គម និងជំរុញការដាក់ឱ្យអនុវត្តការប្រមូលភាគទានសម្រាប់ទ្រទ្រង់ ប.ជ.ស.
- អភិវឌ្ឍស្ថាប័ន និងគ្រប់គ្រងធនធានមនុស្ស
- សហការជាមួយក្រសួង ស្ថាប័ន ធនាគារ និងគ្រឹះស្ថានសាធារណៈ ដៃគូអភិវឌ្ឍន៍នានា ដើម្បីបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គម
- សិក្សា រៀបចំ និងដាក់ឱ្យដំណើរការសេវាថែទាំសុខភាពសម្រាប់មន្ត្រីរាជការស៊ីវិល
- ពន្លឿនការបើកផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រួសារសពនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ។

តារាងទី១៣.ចំណុចដៅនៃសូចនាករអនុកម្មវិធីទី២.១

| ល.រ | សូចនាករ | ឯកតា | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|---|---|
| 31 | និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុកដែលទទួលរបបសន្តិសុខសង្គម | នាក់ | 105,095 | 109,445 | 113,815 | 118,175 | 122,535 |
| | - និវត្តជនដែលទទួលរបបសោធន | នាក់ | 55,799 | 58,299 | 60,799 | 63,299 | 65,799 |
| | - ជនបាត់បង់សម្បទាវិជ្ជាជីវៈដែលទទួលរបបសោធន | នាក់ | 2,139 | 2,039 | 1,939 | 1,839 | 1,739 |
| | - អ្នកនៅក្នុងបន្ទុក | នាក់ | 47,157 | 49,117 | 51,077 | 53,037 | 54,997 |

## អនុកម្មវិធីទី២.២ ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ

- **គោលបំណង៖**

ពង្រឹងពង្រីកសេវាសុខុមាលភាពសង្គមសម្រាប់អតីតយុទ្ធជន ដោយអនុវត្តលើគោលការណ៍ចំនួន៩មាន៖ ការចូលនិវត្តន៍ ការបាត់បង់សមត្ថភាពការងារ មាតុភាព អាពាហ៍ពិពាហ៍គ្រាដំបូង ពលី មរណៈ ពិការភាព ជំងឺ និងគ្រួសាររបស់ជនទាំងនោះ។

- **លទ្ធផលរំពឹងទុក៖**

អតីតយុទ្ធជនជានិវត្តជន ជនបាត់បង់សមត្ថភាពការងារ ជនពិការ ជនពលី ជនមរណៈ ចំនួន ៥៨.២៤៥នាក់ និងទទួលបានរបបសន្តិសុខសង្គមនៅឆ្នាំ២០២៣។

**ច.សទី២.២.១៖ បង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារ**

- សិក្សាស្រាវជ្រាវបន្ថែមការដាក់ឱ្យអនុវត្តការប្រមូលភាគទានសម្រាប់ទ្រទ្រង់ ប.ជ.អ.
- បើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងអ្នកនៅក្នុងបន្ទុក
- បើកផ្តល់ប្រាក់គោលនយោបាយមរណភាពជូនដល់គ្រួសារអតីតយុទ្ធជន។

**ច.សទី២.២.២៖ លើកស្ទួយជីវភាពអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន**

- កែសម្រួលរបបសន្តិសុខសង្គម តាមរយៈការកាត់បន្ថយគម្លាតនៃរបបសោធនរបស់នគរបាលជាតិ និងយោធិននៃកងយោធពលខេមរភូមិន្ទ
- បង្កើនប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងអ្នកនៅក្នុងបន្ទុក
- សហការជាមួយធនាគារ គ្រឹះស្ថានសាធារណៈ សហគ្រាសឯកជន ដើម្បីពង្រឹងប្រសិទ្ធភាពនៃការបើកផ្តល់របបសន្តិសុខសង្គម
- សហការជាមួយធនាគារដៃគូ ដើម្បីសិក្សាពីលទ្ធភាពផ្តល់ប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាបជូនដល់អតីតយុទ្ធជន។

តារាងទី១៤.ចំណុចដៅនៃសូចនាករអនុកម្មវិធីទី២.២

| ល.រ | សូចនាករ | ឯកតា | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|---|---|
| 32 | អតីតយុទ្ធជនដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | 91,749 | 96,249 | 97,249 | 97,749 | 98,249 |
| | - និវត្តជនដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | 31,662 | 35,992 | 37,047 | 37,732 | 38,582 |
| | - ជនបាត់បង់សមត្ថភាពការងារដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | 1,450 | 1,335 | 1,225 | 1,110 | 995 |
| | - ជនពិការដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | 26,531 | 26,686 | 26,691 | 26,646 | 26,551 |
| | - ជនពលីដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | 25,421 | 25,441 | 25,441 | 25,416 | 25,376 |
| | - ជនមរណៈដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | 6,685 | 6,795 | 6,845 | 6,845 | 6,745 |

## អនុកម្មវិធីទី២.៣ ការបន្តនិរន្តរភាពសេវាស្តារលទ្ធភាពពលកម្មជូនជនពិការ

- **គោលបំណង៖**

ពង្រឹងសេវាស្តារលទ្ធភាពពលកម្មនៅក្នុងមណ្ឌលស្តារ ដើម្បីផ្តល់ឱកាស និងលទ្ធភាពជូនជនពិការបានចូលរួមគ្រប់សកម្មភាពរបស់សង្គម។

- **លទ្ធផលរំពឹងទុក៖**

ជនពិការចំនួន ១៤០.០០០នាក់ ទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទានៅតាមមជ្ឈមណ្ឌល ជនពិការចំនួន ៤៥.០០០នាក់ ទទួលបានសេវាស្តារលទ្ធភាពពលកម្មនៅតាមសហគមន៍ ជនពិការចំនួន ២៧៥.០០០នាក់ ទទួលបានសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រនៅឆ្នាំ២០២៣។

**ច.សទី២.៣.១៖ ផ្តល់សេវាស្តារលទ្ធភាពពលកម្មគ្រប់ប្រភេទជូនជនពិការ**

- ផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា
- ផ្តល់សេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ
- ផ្តល់សេវាតាមសហគមន៍សម្រាប់ជនពិការ
- ផលិតឧបករណ៍សិប្បនិម្មិត និងណេប។

**ច.សទី២.៣.២៖ កៀរគរប្រភពធនធានថវិកាសម្រាប់និរន្តរភាពសេវាស្តារលទ្ធភាពពលកម្មជូនជនពិការ**

- ប្រមូលភាគទានប្រាក់ពិន័យអន្តរការណ៍ ចំពោះស្ថាប័ននានា និងនីតិបុគ្គលដែលមិនបានបំពេញកាតព្វកិច្ច ដូចមានចែងក្នុងច្បាប់ ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- ពង្រីកការដាក់ហិបមូលនិធិជនពិការនៅតាមរាជធានី ខេត្ត
- ផ្តល់សេវាព្យាបាលដោយចលនាដោយបង់ប្រាក់
- សហប្រតិបត្តិការជាមួយអង្គការដៃគូនានា ដើម្បីបង្កើនប្រសិទ្ធភាពការផ្តល់សេវាគាំទ្រដល់ជនពិការ
- រៀបចំផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ របស់មូលនិធិជនពិការ។

**ច.សទី២.៣.៣៖ ផ្តល់របបគោលនយោបាយឧបត្ថម្ភដល់ជនពិការ**

- ផ្តល់របបគោលនយោបាយថ្លៃធ្វើដំណើរ និងអាហារដល់ជនពិការដែលមកទទួលសេវាព្យាបាលនៅតាមមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម
- ជំរុញបង្កើនប្រាក់របបឧបត្ថម្ភដល់ជនពិការក្នុងការមកទទួលសេវាពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម
- បើកផ្តល់របបគោលនយោបាយថែទាំសុខភាពជូនជនពិការក្រីក្រនៅសហគមន៍។

**ច.សទី២.៣.៤៖ ផ្សព្វផ្សាយច្បាប់ ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ**

- ផ្សព្វផ្សាយ បញ្ជ្រាបការយល់ដឹងដល់សាធារណជនអំពីច្បាប់ ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- បង្កើនការអប់រំ លើកទឹកចិត្តជនពិការឱ្យរក្សាភាពថ្លៃថ្នូររបស់ខ្លួន និងមានជំនឿជឿជាក់លើខ្លួនឯងពិការតែរាងកាយ តែចិត្តមិនពិការ។

តារាងទី១៥.ចំណុចដៅនៃសូចនាករកម្មវិធីទី២.៣

| ល.រ | សូចនាករ | ឯកតា | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|---|---|
| 33 | ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទានៅតាមមជ្ឈមណ្ឌល | នាក់ | 28,000 | 28,000 | 28,000 | 28,000 | 28,000 |
| 34 | ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មនៅសហគមន៍ | នាក់ | 9,000 | 9,000 | 9,000 | 9,000 | 9,000 |
| 35 | ជនពិការទទួលបានសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ | នាក់ | 55,000 | 55,000 | 55,000 | 55,000 | 55,000 |
| 36 | ជនពិការក្រីក្រទទួលបានរបបគោលនយោបាយឧបត្ថម្ភសេវាពិនិត្យថែទាំសុខភាព | នាក់ | 29,253 | 39,701 | 50,148 | 60,596 | 71,043 |

| | |
|---|---|
| **កម្មវិធីទី៣** | **ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិបាលកិច្ចភាពជាដៃគូ** |
| **អនុកម្មវិធីទី៣.១** | **ការពង្រឹងសមត្ថភាពស្ថាប័ននិងភាពជាដៃគូ** |

- **គោលបំណង៖**

បង្កើនសមត្ថភាពជំនាញ ពង្រឹងស្មារតីទទួលខុសត្រូវមនសិការវិជ្ជាជីវៈរបស់មន្ត្រីសង្គមកិច្ចគ្រប់កម្រិត ពង្រឹងកិច្ចសហប្រតិបត្តិការនៅក្នុងក្របខ័ណ្ឌអាស៊ាននិងសាកលលោក និងពង្រឹងពង្រីកភាពជាដៃគូជាមួយអង្គការនានាដើម្បីកៀរគរប្រភពធនធានទាំងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ។

- **លទ្ធផលរំពឹងទុក៖**

មន្ត្រីក្រសួង ស.អ.យ. ថ្នាក់ជាតិនិងក្រោមជាតិទទួលបានការពង្រឹងសមត្ថភាព អភិវឌ្ឍជំនាញវិជ្ជាជីវៈ ព្រមទាំងការចូលរួមពីអង្គការ សមាគម ក្នុងស្រុក និងបរទេស ដៃគូអភិវឌ្ឍន៍ ទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដើម្បីគាំទ្រដល់ការផ្តល់សេវាសុខុមាលភាពសង្គមប្រកបដោយគុណភាពនៅឆ្នាំ២០២៣។

**ច.សទី៣.១.១៖ ពង្រឹងសមត្ថភាពមន្ត្រីរាជការ និងបង្កើនប្រសិទ្ធភាពការងាររដ្ឋបាល**

- រៀបចំផែនការក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលឱ្យមានតុល្យភាពទៅនឹងបរិមាណមន្ត្រីចូលនិវត្តន៍ ស្របតាមស្ថានភាពជាក់ស្តែងរបស់មន្ទីរ ស.អ.យ. រាជធានី ខេត្ត
- បណ្តុះបណ្តាលពង្រឹងសមត្ថភាព ជំនាញដល់មន្ត្រីគ្រប់លំដាប់ថ្នាក់
- លើកទឹកចិត្តមន្ត្រីគ្រប់លំដាប់ថ្នាក់ តាមរយៈការតែងតាំង ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ ប្រាក់បំណាច់មុខងារ ប្រាក់ឧបត្ថម្ភបន្ថែម និងរូបភាពសរសើរផ្សេងៗ
- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ តាមរយៈការអនុវត្តច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល បទបញ្ជាផ្ទៃក្នុង និងរបៀបរបបធ្វើការឱ្យបានហ្មឺងម៉ាត់ ធានាឱ្យបាននូវប្រសិទ្ធភាពការងារ
- អនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំឱ្យមានឯកសណ្ឋានផ្លូវការសម្រាប់មន្ត្រីនិងបុគ្គលិកសង្គមកិច្ច។

**ច.សទី៣.១.២៖ ពង្រឹងការងារផែនការ និងផ្សព្វផ្សាយ**

- រៀបចំផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ និងផែនការសកម្មភាពប្រចាំឆ្នាំ
- ផ្សព្វផ្សាយលទ្ធផលការងារដែលក្រសួងសម្រេចបាន
- ពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាព និងលទ្ធផលការងាររបស់អង្គភាពចំណុះ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត
- គាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥
- អនុវត្តកម្មវិធីជាតិអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**ច.សទី៣.១.៣៖ បន្តពង្រឹងភាពជាដៃគូជាមួយអង្គការ សមាគម មិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ**

- សហប្រតិបត្តិការជាមួយអង្គការ សមាគម ដែលជាដៃគូក្នុងស្រុក និងបរទេស
- សហប្រតិបត្តិការទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសនានា ទាំងក្នុងសហគមន៍អាស៊ាន និងសហគមន៍អន្តរជាតិ។

**ច.សទី៣.១.៤៖ អនុវត្តកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤**

- អនុវត្តថវិកាកម្មវិធីពេញលេញ
- បើកផ្តល់របបឧបត្ថម្ភបានត្រឹមត្រូវ ទាន់ពេលវេលា និងមានប្រសិទ្ធភាព។

**ច.សទី៣.១.៥៖ ពង្រឹងការងារអធិការកិច្ច**

- ដោះស្រាយបណ្តឹង និងវិវាទការងារជូនមន្ត្រីរាជការរបស់ក្រសួង
- ធ្វើអធិការកិច្ចអង្គភាព មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត លើការអនុវត្តបទបញ្ជាផ្ទៃក្នុង របៀបរបបការងារ និងការគ្រប់គ្រងវត្តមានរបស់មន្ត្រី។

**ច.សទី៣.១.៦៖ ពង្រឹងការងារសវនកម្មផ្ទៃក្នុង**

- ចុះធ្វើសវនកម្មនៅតាមអង្គភាព និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត លើការគ្រប់គ្រងចំណូល ចំណាយ ថវិកាជាតិ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការតាមដានការអនុវត្តអនុសាសន៍របស់សវនករ។

| អនុកម្មវិធីទី៣.២ | ការអភិវឌ្ឍធនធានមនុស្ស |
|---|---|

- **គោលបំណង៖**

បណ្តុះបណ្តាលជំនាញបច្ចេកទេសសង្គមកិច្ច និងវិស្វកម្មសិប្បនិម្មិតនិងរណប សំដៅបណ្តុះបណ្តាលដល់មន្ត្រីនិងបុគ្គលិកសង្គមកិច្ច បម្រើឱ្យវិស័យសង្គមកិច្ច។

- **លទ្ធផលរំពឹងទុក៖**

និស្សិតចំនួន៦០៧នាក់ នឹងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និងសិក្ខាកាមចំនួន១.០០០នាក់ នឹងបញ្ចប់ការសិក្សាកម្រិតវិញ្ញាបនបត្រ។

**ច.សទី៣.២.១៖ បណ្តុះបណ្តាលវិជ្ជាជីវៈកម្រិតឧត្តមសិក្សា និងកម្រិតវិញ្ញាបនបត្រ**

- បណ្តុះបណ្តាលវិជ្ជាជីវៈកម្រិតឧត្តមសិក្សា ថ្នាក់បរិញ្ញាបត្រ សង្គមកិច្ច សង្គមវិទ្យា កិច្ចគាំពារសង្គម គ្រប់គ្រងសាធារណៈ រដ្ឋបាលសាធារណៈ គោលនយោបាយសង្គម គោលនយោបាយសាធារណៈ អក្សរសាស្ត្រអង់គ្លេស និងបរិញ្ញាបត្រវិស្វកម្មឧបករណ៍សិប្បនិម្មិត និងរណប
- បណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី កម្រិតវិញ្ញាបនបត្រ លើមុខជំនាញផ្សេងៗ
- លើកទឹកចិត្ត និងផ្តល់អាទិភាព ដល់និស្សិតដែលបានបញ្ចប់ការសិក្សាលើជំនាញ សង្គមកិច្ច ចិត្តសាស្ត្រ សង្គមវិទ្យា ក្នុងការជ្រើសរើសចូលបម្រើការងារក្នុងក្របខ័ណ្ឌរបស់ក្រសួង។

**ច.សទី៣.២.២៖ ពង្រឹង និងពង្រីកសមត្ថភាពវិទ្យាស្ថានជាតិសង្គមកិច្ច**

- ជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាពមកបណ្តុះបណ្តាលដល់និស្សិត
- រៀបចំផែនការបណ្តុះបណ្តាល និងអភិវឌ្ឍកម្មវិធីសិក្សា
- សាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់បរិក្ខារសិក្សា។

តារាងទី១៦.ចំណុចដៅនៃសូចនាករអនុកម្មវិធី៣.២

| ល.រ | សូចនាករ | ឯកតា | 2019 | 2020 | 2021 | 2022 | 2023 | សរុប |
|---|---|---|---|---|---|---|---|---|
| 37 | និស្សិតដែលបានចុះឈ្មោះចូលរៀនឆ្នាំទី១ | នាក់ | 150 | 150 | 200 | 200 | 200 | 900 |
| 38 | និស្សិតដែលកំពុងសិក្សាកម្រិតបរិញ្ញាបត្រ | នាក់ | 500 | 500 | 550 | 550 | 550 | 2,650 |
| 39 | និស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ | នាក់ | 89 | 98 | 120 | 150 | 150 | 607 |
| 40 | សិក្ខាកាមដែលបានបញ្ចប់ការសិក្សាកម្រិតវិញ្ញាបនបត្រ | នាក់ | 150 | 150 | 200 | 250 | 250 | 1,000 |

## អនុកម្មវិធីទី៣.៣ ការពង្រឹងសមត្ថភាពមន្ទីរ និងអភិវឌ្ឍភាពជាដៃគូ រាជធានី-ខេត្ត

- **គោលបំណង៖**

បង្កើនប្រសិទ្ធភាពជំនាញ ពង្រឹងស្មារតីទទួលខុសត្រូវមនសិការវិជ្ជាជីវៈ របស់មន្ត្រី និងពង្រឹងភាពជាដៃគូកៀរគរប្រភពធនធានទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីបង្កើនការផ្តល់សេវាសុខុមាលភាពសង្គមជូនជនរងគ្រោះ និងងាយរងគ្រោះរាជធានី ខេត្ត។

- **លទ្ធផលរំពឹងទុក៖**

មន្ត្រីមន្ទីរ ស.អ.យ. ទាំង២៥ រាជធានី ខេត្ត ទទួលបានការបង្កើនប្រសិទ្ធិភាពជំនាញវិជ្ជាជីវៈដើម្បីអនុវត្តការងាររដ្ឋបាល ផែនការ និងពង្រឹងភាពជាដៃគូសម្រាប់កៀរគរប្រភពធនធានទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ បង្កើនការផ្តល់សេវាសុខុមាលភាពសង្គមជូនជនរងគ្រោះ និងងាយរងគ្រោះភាគច្រើនក្នុងសហគមន៍នៅឆ្នាំ២០២៣។

### ប.សទី៣.៣.១៖ ពង្រឹងសមត្ថភាពមន្ទីរ និងអភិវឌ្ឍភាពជាដៃគូ រាជធានី ខេត្ត

- ពង្រឹងសមត្ថភាពមន្ត្រីរាជការ និងបង្កើនប្រសិទ្ធភាពការងាររដ្ឋបាល
- ពង្រឹងការងារផែនការ និងអនុវត្តផែនការ
- បន្តពង្រឹងភាពជាដៃគូជាមួយអង្គការ សមាគម មិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ

# ជំពូកទី៤
# ការរៀបចំស្ថាប័នសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ

## ៤.១.ថ្នាក់ជាតិ

អនុក្រឹត្យលេខ ៥៤ អនក្របក. ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង ស.អ.យ. បានកំណត់មុខងារនិងការទទួលខុសត្រូវច្បាស់លាស់របស់ អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន នាយកដ្ឋានជំនាញ និងអង្គភាពចំណុះទាំងអស់ក្រោមឱវាទក្រសួង។ ក្នុងន័យនេះ ក្រសួងគឺជាស្ថាប័នដែលទទួលខុសត្រូវក្នុងការសម្របសម្រួលនិងអនុវត្តវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងតាមដានត្រួតពិនិត្យលើការអនុវត្តផែនការយុទ្ធសាស្ត្រ។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.) ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១២០១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើការងារទាក់ទងនឹងការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព និងការចូលរួមចំណែករបស់កុមារ។ តួនាទី និងភារកិច្ចចម្បងរបស់ ក.ជ.ក. គឺ ពិគ្រោះយោបល់ សម្របសម្រួលសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហាកុមារ ពិនិត្យ តាមដាន វាយតម្លៃ លើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ កម្មវិធីជាតិសម្រាប់កុមារនៅកម្ពុជា និងលើកសំណើជូនរាជរដ្ឋាភិបាល ពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកុមារ ផ្សព្វផ្សាយច្បាប់ អនុសញ្ញាស្តីពីសិទ្ធិកុមារ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា របស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងបញ្ហានានារបស់កុមារ និងបំផុសចលនាគាំទ្រការអនុវត្តសិទ្ធិកុមារឱ្យមានប្រសិទ្ធភាព រៀបចំគោលនយោបាយ ផែនការ កម្មវិធី និងសកម្មភាពផ្សេងៗដើម្បីឧត្តមប្រយោជន៍កុមារ និងរៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិ ដែលពាក់ព័ន្ធនឹងសិទ្ធិរបស់កុមារ។

ក្រុមប្រឹក្សាសកម្មភាពជនពិការ គឺជាជាយន្តការសម្របសម្រួលថ្នាក់ជាតិ និងពិគ្រោះយោបល់លើបញ្ហាពិការភាព ដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខ នស/រកត/០១០/០៧០៩ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។ ក.ជ.ស. មានតួនាទី និងភារកិច្ច ដូចតទៅ៖ ផ្តល់ការពិគ្រោះយោបល់ជំនាញលើបញ្ហាពិការភាពនិងការស្តារលទ្ធភាពពលកម្ម ជួយក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធក្នុងការរៀបចំគោលនយោបាយ ផែនការជាតិ និងយុទ្ធសាស្ត្រ ដែលមានការពាក់ព័ន្ធទៅនឹងពិការភាព និងការស្តារលទ្ធភាពពលកម្ម ជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាពនិងការស្តារលទ្ធភាពពលកម្ម លើកសំណើកែសម្រួល បំពេញបន្ថែម ធ្វើវិសោធនកម្ម គោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព តាមដាន វាយតម្លៃការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព ទំនាក់ទំនងជាមួយសហគមន៍ជាតិ អន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ កៀរគរប្រភពធនធានទាំងក្នុង និងក្រៅប្រទេស រៀបចំទិវាជនពិការជាតិ ទិវាជនពិការអន្តរជាតិ និងទិវាជនពិការផ្សេងៗទៀត រៀបចំផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពទាក់ទងនឹងពិការភាព ដឹកនាំ

ចាត់ចែង អនុវត្ត ធ្វើរបាយការណ៍បូកសរុបលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងរៀបចំរបាយការណ៍ស្តីពីស្ថានភាពជនពិការជូនរាជរដ្ឋាភិបាល។

បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ១៤ អនក្រ.បក ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងដោយអនុលោមតាមព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៣៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល។ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល គឺជាស្ថាប័នមួយដែលមានតួនាទីរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍ និងកែទម្រង់គោលនយោបាយរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ជាពិសេសគឺសិក្សាលើលទ្ធភាពក្នុងការផ្តល់នូវតាវកាលិកបន្ថែមទៀត ដើម្បីឱ្យស្របទៅតាមបរិបទនៃវឌ្ឍនភាពសេដ្ឋកិច្ច និងសង្គម។ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល មានភារកិច្ចគ្រប់គ្រង និងធានាការបើកផ្តល់របបសន្តិសុខសង្គមដែលមានតាវកាលិកចំនួន០៦ គឺ ការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ មរណភាព និងអ្នកនៅក្នុងបន្ទុក ។

បេឡាជាតិអតីតយុទ្ធជន ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៧៩អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ ស្របតាមខ្លឹមសារនៃព្រះរាជក្រឹត្យលេខ នស/រកត/០៧១០/៥៩៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ស្តីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន។ បេឡាជាតិអតីតយុទ្ធជន (ប.ជ.អ.) គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាល សម្រាប់ដាក់ឱ្យដំណើរការគ្រប់គ្រង និងធានាការបើកផ្តល់របបសន្តិសុខសង្គម ជូនអតីតយុទ្ធជននៃកងយោធពលខេមរភូមិន្ទ អតីតយុទ្ធជននៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ អតីតយុទ្ធជននៃក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល បុគ្គលិកជាប់កិច្ចសន្យា កងជីវពល កងសេនាជន និងប្រជាពលរដ្ឋដែលបានចូលរួមប្រយុទ្ធឬបម្រើការងារប្រយុទ្ធ ដើម្បីប្រទេសជាតិ និងគ្រួសារអតីតយុទ្ធជន។ បេឡាជាតិអតីតយុទ្ធជន បម្រើសេវាបើកផ្តល់នូវតាវកាលិករបបសន្តិសុខសង្គមជូនអតីតយុទ្ធជន រួមមាន ការចូលនិវត្តន៍ ការបាត់បង់សមត្ថភាពការងារ មាតុភាព អាពាហ៍ពិពាហ៍គ្រាដំបូង ពលី មរណៈ ពិការភាព ជំងឺ និងគ្រួសាររបស់ជនទាំងនោះ។

មូលនិធិជនពិការត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១១៨អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ដោយអនុលោមតាមច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។ មូលនិធិជនពិការជាគ្រឹះស្ថានសាធារណៈរដ្ឋបាល មានបេសកកម្ម ធានានូវសិទ្ធិ និងលទ្ធភាពរបស់ជនពិការ ក្នុងការទទួលសេវាស្តារលទ្ធភាពពលកម្ម និងការចូលរួមយ៉ាងពេញលេញក្នុងសង្គម និងមានភារកិច្ចចម្បងៗ ដូចតទៅ ផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ គ្រប់គ្រងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មជូនជនពិការ លើកកម្ពស់និងបង្កើនសុខុមាលភាពជនពិការ ធ្វើសមាហរណកម្មជនពិការទៅសហគមន៍ គ្រប់គ្រងថវិកាដែលទទួលបានពីការឧបត្ថម្ភរបស់រាជរដ្ឋាភិបាលនិងពីប្រភពផ្សេងៗ ប្រមូលភាគទាន ប្រាក់ពិន័យអន្តរការណ៍ និងប្រាក់ពិន័យផ្សេងៗទៀតពីប្រធានស្ថាប័ននិងនីតិបុគ្គលដែលមិនបានបំពេញតាមកាតព្វកិច្ចដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ផ្តល់មូលនិធិសម្រាប់ការអនុវត្តកម្មវិធីផ្សេងៗដែល

ជួយដល់ជនពិការ និងគាំទ្រដល់ស្ថាប័ន គ្រឹះស្ថាននានា ដែលផ្តល់សេវាកម្មដល់ជនពិការ រៀបចំគោលនយោបាយជាតិផ្គត់ផ្គង់និងឧបត្ថម្ភដល់ជនពិការ រៀបចំហិបប្រាក់វិភាគទានសប្បុរសធម៌សម្រាប់ជនពិការ ចាត់ចែងនិងគ្រប់គ្រងការវិនិយោគមូលនិធិនៃ ម.ជ.ព. និងស្រាវជ្រាវនិងបណ្តុះបណ្តាលធនធានមនុស្សក្នុងការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ។

វិទ្យាស្ថានជាតិសង្គមកិច្ច ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ២៣៣អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១។ វ.ជ.ស. មានបេសកកម្ម បណ្តុះបណ្តាល និងស្រាវជ្រាវលើផ្នែកសង្គមកិច្ច ដោយភ្ជាប់ទៅនឹងតម្រូវការរបស់ប្រទេសជាតិ និងសង្គម។

## ៤.២.ថ្នាក់រាជធានី ខេត្ត

ការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរ ស.អ.យ. រាជធានីខេត្តត្រូវបានចែងក្នុងប្រកាសលេខ ០៦៦ ស.អ.យ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧។ មន្ទីរ ស.អ.យ. ជាខ្សែបណ្តោយរបស់ក្រសួងមានភារកិច្ចសម្របសម្រួល និងទទួលអនុវត្ត វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅថ្នាក់ក្រោមជាតិ ដែលមានការិយាល័យ ស.អ.យ. ក្រុង ស្រុក ខណ្ឌ ធ្វើជាសេនាធិការក្នុងការធ្វើការជាមួយអាជ្ញាធរនៅថ្នាក់ក្រោមជាតិ។ បច្ចុប្បន្ន ក្រសួងបានធ្វើប្រតិភូកម្មមុខងារមួយចំនួនឱ្យទៅមន្ទីរអនុវត្តក្នុងនាមក្រសួង និងនៅពេលខាងមុខ ក្រសួងនឹងផ្ទេរមុខងារមួយចំនួនទៀតដែលទាក់ទងដោយផ្ទាល់ក្នុងការផ្តល់សេវាឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាបណ្តើរៗ[12] ដូច្នេះមន្ត្រីជំនាញរបស់មន្ទីរ ស.អ.យ. រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាអ្នកអនុវត្តដោយផ្ទាល់ក្រោមការសម្របសម្រួលពីរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៤.៣. ភាគីពាក់ព័ន្ធ

ភាគីពាក់ព័ន្ធដទៃទៀតដែលរួមចំណែកក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រួមមាន ក្រសួង ស្ថាប័ន កាកបាទក្រហមកម្ពុជា ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស វិស័យឯកជន អាជ្ញាធរថ្នាក់ក្រោមជាតិ[13] និងអ្នកដែលទទួលបានសេវាសុខុមាលភាពសង្គមទាំងអស់នឹងផ្តល់ការគាំទ្រ និងសហការជាមួយក្រសួង ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះឱ្យទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផល ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

---

[12] ដោយមានការសម្របសម្រួលពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

[13] ក្រុមប្រឹក្សារាជធានីខេត្ត ក្រុងស្រុក ខណ្ឌ គណៈអភិបាលរាជធានីខេត្ត ក្រុងស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់

# ជំពូកទី៥
# យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទានសម្រាប់ផែនការយុទ្ធសាស្ត្រ

## ៥.១. ថវិកាជាតិ

ក្រសួងបានទទួលថវិកាពីរាជរដ្ឋាភិបាលក្នុងរយៈពេលប្រាំឆ្នាំកន្លងមក (២០១៤-២០១៨) មានថវិកាសរុបចំនួន ៣.៥៦១.៣១៧,៤០លានរៀល សម្រាប់ចំណាយលើការទិញ សេវាខាងក្រៅ សេវាខាងក្រៅផ្សេងៗ បន្ទុកបុគ្គលិក ឧបត្ថម្ភធន ជំនួយសង្គមនិងពន្ធអាករ។ យោងតាមការវិភាគទិន្នន័យ និងពិភាក្សាជាមួយផ្នែកជំនាញបានបង្ហាញយ៉ាងច្បាស់ថា ការគ្រប់គ្រងថវិការបស់ក្រសួងពិតជាបានបម្រើនូវសំណូមពរ និងតម្រូវការចាំបាច់ដើម្បីដោះស្រាយការលំបាកជាច្រើន ដែលធ្វើឱ្យចំនួនជនរងគ្រោះនិងងាយរងគ្រោះត្រូវបានកាត់បន្ថយជាបន្តបន្ទាប់និងមុខសញ្ញាបានទទួលនូវសេវាជាទីទុកចិត្ត។ កិច្ចការទាំងនេះក៏បានអនុវត្តតាមជំពូកនៃថវិកានិងឆ្លុះបញ្ចាំងពីការអនុវត្តកម្មវិធីថវិការបស់ខ្លួនផងដែរ។

សម្រាប់រយៈពេល៥ឆ្នាំខាងមុខ តាមការព្យាករណ៍ រាជរដ្ឋាភិបាលនឹងបង្កើនថវិកាជាតិជិតពីរដង ពី ៣.៥៦១.៣១៤,៤០លានរៀល ទៅ ៦.៤៩៣.៤០៧លានរៀល សម្រាប់អនុវត្តនូវបណ្តាគោលនយោបាយ កម្មវិធីអាទិភាពថ្មីៗ ដែលគាំទ្រដល់សុខុមាលភាពជនរងគ្រោះ និងងាយរងគ្រោះជាងគេនៅក្នុងសង្គម។

## ៥.២. ធនធានដៃគូអភិវឌ្ឍន៍

ក្រសួងនឹងយកចិត្តទុកដាក់លើភាពជាដៃគូក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ ទ្វេភាគី ពហុភាគី ក្នុងក្របខ័ណ្ឌអាស៊ាន តំបន់ និងសកលលោក ដោយអនុវត្តគោលនយោបាយលើកទឹកចិត្ត បង្កលក្ខណៈងាយស្រួលដល់អង្គការពាក់ព័ន្ធនានាដែលធ្វើសកម្មភាពរបស់ខ្លួនលើវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ គិតពីឆ្នាំ២០១៤-២០១៨ ក្រសួងបានចុះកិច្ចព្រមព្រៀងជាមួយអង្គការដៃគូចំនួន ១២៤ ដែលថវិកាគម្រោងសរុបចំនួន១៤៤.៧៤១.៦៦៥,៦០ដុល្លារអាម៉េរិក បើគិតជាមធ្យមក្នុងមួយឆ្នាំស្មើ ៣៦.១៨៥.៤១៦,៤០ ដុល្លារអាម៉េរិក ដែលបានរួមចំណែកសម្រាលបន្ទុកថវិកាជាតិ និងប្រមូលបាននូវធនធានមនុស្សបច្ចេកទេស និងបទពិសោធន៍ល្អៗជាច្រើនសម្រាប់ផ្តល់សេវាវិស័យ ស.អ.យ.។

## ៥.៣ តម្រូវការថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ

ក្រសួងត្រូវការថវិកាសរុបរយៈពេលប្រាំឆ្នាំពី២០១៩-២០២៣ ប្រមាណ ៦.៤៩៣.៤៧០លានរៀល និងថវិកាដៃគូប្រមាណ ១៨០លានដុល្លារអាម៉េរិក ដើម្បីអនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពទាំងឡាយដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាឱ្យទទួលបានជោគជ័យ។

តារាងទី១៧. តម្រូវការថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ២០១៩-២០២៣

| តម្រូវការវិនិយោគ | ថវិកាជាតិ | | ថវិកាដៃគូ (គិតជាដុល្លារ) |
|---|---|---|---|
| | គិតជារៀល (លានរៀល) | គិតជាដុល្លារ | |
| **សរុបរួម** | **6,493,470.00** | **1,623,367,500.00** | **180,000,000$** |
| ១.កម្មវិធីទី១ | 849,189.00 | 212,297,250.00 | 180,000,000$ |
| ២.កម្មវិធីទី២ | 5,228,379.20 | 1,307,094,800.00 | |
| ៣.កម្មវិធីទី៣ | 415,901.80 | 103,975,450.00 | |

# ជំពូកទី៦
# ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីឱ្យការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាឆ្នាំ ២០១៩-២០២៣ សម្រេចបានតាមកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពនិងចំណុចដៅនៃសូចនាករដែលបានកំណត់។ ក្រសួងនឹងបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃមួយជាក់លាក់សម្រាប់វាស់វែងវឌ្ឍនភាព។ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពដែលបានអនុវត្តគឺជាការងារដ៏សំខាន់នៃដំណើរការការងារផែនការ ក្រសួងនឹងរៀបចំផែនការសកម្មភាពប្រចាំឆ្នាំដោយមានការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយជាមួយអ្នកពាក់ព័ន្ធផ្អែកលើផែនការយុទ្ធសាស្ត្រនេះ ។

## ៦.១.ត្រួតពិនិត្យតាមដាន

ក្រសួង ស.អ.យ. នឹងត្រូវធ្វើការតាមដានត្រួតពិនិត្យវឌ្ឍនភាពសម្រេចបានក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រប្រចាំឆ្នាំនីមួយៗធៀបនឹងកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងធនធានដែលបានកំណត់ប្រចាំឆ្នាំ។ ការតាមដានត្រួតពិនិត្យត្រូវផ្អែកលើឧបករណ៍ដូចជា ផែនការសកម្មភាពប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំ។ នាយកដ្ឋានផែនការ ស្ថិតិ និងសរុបត្រូវធ្វើរបាយការណ៍ពីលទ្ធផលនៃការតាមដានត្រួតពិនិត្យប្រចាំឆ្នាំជូនថ្នាក់ដឹកនាំក្រសួងដើម្បីពិនិត្យ កែលម្អ និងផ្ដល់អនុសាសន៍។

## ៦.២.ការវាយតម្លៃ

ក្រសួងនឹងធ្វើការវាយតម្លៃលទ្ធផល ដោយផ្អែកលើសូចនាករដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រ។ ការវាយតម្លៃនឹងធ្វើចំនួន ០២ដង គឺការវាយតម្លៃពាក់កណ្ដាលអាណត្តិនៅឆមាសទី២ឆ្នាំ២០២១ និងការវាយតម្លៃបញ្ចប់អាណត្តិនៅឆមាសទី២ឆ្នាំ២០២៣។ ការវាយតម្លៃនេះនឹងផ្អែកលើឧបករណ៍ដូចជាផែនការយុទ្ធសាស្ត្រ២០១៩-២០២៣ ផែនការសកម្មភាពប្រចាំឆ្នាំ និងរបាយការណ៍លទ្ធផល(សូចនាករលទ្ធផល) ប្រចាំឆ្នាំនីមួយៗ របាយការណ៍វាយតម្លៃវឌ្ឍនភាពពាក់កណ្ដាលអាណត្តិ២០១៩-២០២១ និងរបាយការណ៍វាយតម្លៃវឌ្ឍនភាពបញ្ចប់អាណត្តិ ២០១៩-២០២៣។

# ជំពូកទី៧
# សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាឆ្នាំ២០១៩-២០២៣ ត្រូវបានរៀបចំកសាងឡើងនៅឆ្នាំ២០១៨ ក្រោមការដឹកនាំពីឯកឧត្តមរដ្ឋមន្ត្រី និងការចូលរួមរបស់ក្រុមការងារ នាយកដ្ឋានជំនាញ អង្គភាពចំណុះ ដោយមានការសម្របសម្រួលពិគ្រោះយោបល់ និងពិភាក្សាគ្រប់ជ្រុងជ្រោយជាមួយភាគីដៃគូពាក់ព័ន្ធនានាក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ផែនការយុទ្ធសាស្ត្រនេះ គឺជាផែនទីចង្អុលផ្លូវសម្រាប់អនុវត្តកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីរួមចំណែកអនុវត្ត គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥ និងគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ឆ្នាំ ២០១៧-២០៣០។

ផែនការយុទ្ធសាស្ត្រនេះ គឺជាក្របខ័ណ្ឌយុទ្ធសាស្ត្រថ្មីមួយសម្រាប់វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលអាចគ្របដណ្តប់រាល់ការអនុវត្តកម្មវិធីទាំងបី។ ផែនការយុទ្ធសាស្ត្រនេះតម្រូវឱ្យមានការចូលរួម ការប្តេជ្ញាចិត្តពីរាជរដ្ឋាភិបាល និងការគាំទ្រពីដៃគូពាក់ព័ន្ធ ព្រមទាំងសប្បុរសជននានា។ ផែនការយុទ្ធសាស្ត្រនេះនឹងធ្វើឱ្យមានភាពសុខុដុមនីយកម្មរវាងកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពរបស់ក្រសួង។ ផែនការយុទ្ធសាស្ត្រនេះនឹងឆ្លើយតបទៅនឹងសំណូមពររបស់ភាគីពាក់ព័ន្ធ និងជួយដោះស្រាយនូវបញ្ហាប្រឈមទាំងឡាយ ដើម្បីធ្វើឱ្យសម្រេចបាននូវចំណុចដៅនៃសូចនាករដែលបានកំណត់ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

# ឧបសម្ព័ន្ធ

## ១.ម៉ាទ្រីចស្តីពីតម្រូវការចំណាយលើកម្មវិធី និងអនុកម្មវិធី

ឯកតា៖ លានរៀល

| បរិយាយ(កម្មវិធី និងអនុកម្មវិធី) | ចំណាយប៉ាន់ស្មាន | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|
| | ចំណាយចរន្ត | ចំណាយវិនិយោគ | |
| **១. កម្មវិធីទី១** | **794,926.00** | **54,263.00** | អគ្គនាយកដ្ឋានបច្ចេកទេស |
| ១.១. អនុកម្មវិធីទី១ | 69,012.70 | 21,405.00 | ១.នាយកដ្ឋានសុខុមាលភាពសង្គម<br>២.នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ |
| ១.២. អនុកម្មវិធីទី២ | 88,211.00 | 24,858.00 | ១.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ<br>២.នាយកដ្ឋានសុខុមាលភាពកុមារ<br>៣.នាយកដ្ឋានយុវនីតិសម្បទា<br>៤.មជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន<br>៥.រដ្ឋបាលសុំកូនអន្តរប្រទេស |
| ១.៣. អនុកម្មវិធីទី៣ | 69,167.80 | 00 | ១.ក្រុមប្រឹក្សាសកម្មភាពជនពិការ<br>២.នាយកដ្ឋានសុខុមាលភាពជនពិការ |
| ១.៤. អនុកម្មវិធីទី៤ | 48,123.00 | 8,000.00 | នាយកដ្ឋានសុខុមាលភាពមនុស្សចាស់ |
| ១.៥. អនុកម្មវិធីទី៥ | 27,079.90 | 00 | នាយកដ្ឋានអតីតយុទ្ធជន |
| ១.៦. អនុកម្មវិធីទី៦ | 493,331.60 | 00 | មន្ទីរ ស.អ.យ. ២៥ រាជធានី ខេត្ត |

| បរិយាយ(កម្មវិធី និងអនុកម្មវិធី) | ចំណាយប៉ាន់ស្មាន | | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|
| | ចំណាយចរន្ត | ចំណាយវិនិយោគ | |
| **២. កម្មវិធីទី២** | **5,228,379.20** | **00** | |
| ២.១. អនុកម្មវិធីទី១ | 2,438,013.20 | 00 | បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល |
| ២.២. អនុកម្មវិធីទី២ | 2,742,986.00 | 00 | បេឡាជាតិអតីតយុទ្ធជន |
| ២.៣. អនុកម្មវិធីទី៣ | 47,380.00 | 00 | មូលនិធិជនពិការ |
| **៣. កម្មវិធីទី៣** | **400,901.80** | **15,000.00** | **អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ** |
| ៣.១. អនុកម្មវិធីទី១ | 173,032.50 | 00 | ១.នាយកដ្ឋានរដ្ឋបាល បុគ្គលិក<br>២.នាយកដ្ឋានផែនការ ស្ថិតិ និងសរុប<br>៣.នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់<br>៤.នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ<br>៥.អគ្គាធិការដ្ឋាន<br>៦.នាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៣.២. អនុកម្មវិធីទី២ | 8,621.10 | 00 | វិទ្យាស្ថានជាតិសង្គមកិច្ច |
| ៣.៣. អនុកម្មវិធីទី៣ | 219,248.20 | 15,000.00 | មន្ទីរ ស.អ.យ. ២៥ រាជធានី ខេត្ត |
| **សរុបរួម** | **6,424,207** | **69,263** | |
| **%** | **98.93** | **1.03** | |

## ២.ម៉ាទ្រីចស្តីពីតម្រូវការឥណទានតាមប្រភេទចំណាយតាមកម្មវិធី និងអនុកម្មវិធី

ឯកតា៖ លានរៀល

| តម្រូវការឥណទាន តាមកម្មវិធី និងអនុកម្មវិធី | គ្រោងតម្រូវការឥណទាន ឆ្នាំ២០១៩ | គ្រោងតម្រូវការឥណទាន ឆ្នាំ២០២០ | គ្រោងតម្រូវការឥណទាន ឆ្នាំ២០២១ | គ្រោងតម្រូវការឥណទាន ឆ្នាំ២០២២ | គ្រោងតម្រូវការឥណទាន ឆ្នាំ២០២៣ | សរុប |
|---|---|---|---|---|---|---|
| **សរុបរួម** | **1,197,979.00** | **1,239,545.40** | **1,296,190.20** | **1,351,735.20** | **1,408,020.20** | **6,493,470.00** |
| **១. កម្មវិធីទី១** | **167,875.20** | **160,825.20** | **167,161.00** | **173,495.90** | **179,831.70** | **849,189.00** |
| ១.១. អនុកម្មវិធីទី១ | 17,469.50 | 16,678.40 | 17,717.50 | 18,756.60 | 19,795.70 | **90,417.70** |
| ១.២. អនុកម្មវិធីទី២ | 27,620.60 | 18,990.30 | 20,571.50 | 22,152.70 | 23,733.90 | **113,069.00** |
| ១.៣. អនុកម្មវិធីទី៣ | 10,792.60 | 10,750.80 | 13,312.80 | 15,874.80 | 18,436.80 | **69,167.80** |
| ១.៤. អនុកម្មវិធីទី៤ | 7,950.00 | 10,745.00 | 11,610.50 | 12,476.00 | 13,341.50 | **56,123.00** |
| ១.៥. អនុកម្មវិធីទី៥ | 5,574.10 | 5,331.90 | 5,361.90 | 5,391.00 | 5,421.00 | **27,079.90** |
| ១.៦. អនុកម្មវិធីទី៦ | 98,468.40 | 98,328.80 | 98,586.80 | 98,844.80 | 99,102.80 | **493,331.60** |
| **២. កម្មវិធីទី២** | **960,211.80** | **1,000,740.00** | **1,045,400.00** | **1,088,896.10** | **1,133,131.30** | **5,228,379.20** |
| ២.១. អនុកម្មវិធីទី១ | 402,138.60 | 442,666.80 | 487,326.80 | 530,822.90 | 575,058.10 | **2,438,013.20** |
| ២.២. អនុកម្មវិធីទី២ | 548,597.20 | 548,597.20 | 548,597.20 | 548,597.20 | 548,597.20 | **2,742,986.00** |
| ២.៣. អនុកម្មវិធីទី៣ | 9,476.00 | 9,476.00 | 9,476.00 | 9,476.00 | 9,476.00 | **47,380.00** |
| **៣. កម្មវិធីទី៣** | **69,892.00** | **77,980.20** | **83,629.20** | **89,343.20** | **95,057.20** | **415,901.80** |
| ៣.១. អនុកម្មវិធីទី១ | 26,732.00 | 31,211.05 | 34,787.10 | 38,363.15 | 41,939.20 | **173,032.50** |
| ៣.២. អនុកម្មវិធីទី២ | 1,411.90 | 1,618.10 | 1,708.40 | 1,863.70 | 2,019.00 | **8,621.10** |
| ៣.៣. អនុកម្មវិធីទី៣ | 41,748.10 | 45,151.05 | 47,133.70 | 49,116.35 | 51,099.00 | **234,248.20** |

## ៣.ម៉ាទ្រីចស្តីពីការតាមដានត្រួតពិនិត្យការអនុវត្ត

| សូចនាករ | ឯកតា | ទិ.មូលដ្ឋាន | ចំណុចដៅតាមឆ្នាំ | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | | |
| គ្រួសាររងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះមហន្តរាយ នៅតាមសហគមន៍ បានទទួលជំនួយសង្គ្រោះបន្ទាន់ | គ្រួសារ | 64,800 | 25,514 | 26,024 | 27,544 | 28,094 | 28,655 | រដ្ឋបាល | ន.សុខុមាលភាពសង្គម |
| ជនអនាថាដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | 1,139 | 968 | 823 | 700 | 595 | 506 | រដ្ឋបាល | |
| ជនអនាថាដែលទទួលបានសេវាគាំពារ | នាក់ | 2,334 | 968 | 823 | 700 | 595 | 506 | រដ្ឋបាល | |
| ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារផ្ទុកមេរោគអេដស៍ជំងឺអេដស៍ ដែលទទួលសេវាថែទាំគាំទ្រតាមសហគមន៍ | នាក់ | 2,064 | 2,167 | 2,276 | 2,389 | 2,509 | 2,634 | រដ្ឋបាល | |
| ជនវិបល្លាសស្មារតីទទួលបានសេវាព្យាបាល និងថែទាំ ក្នុងមជ្ឈមណ្ឌល | នាក់ | n/a | 110 | 121 | 133 | 146 | 161 | រដ្ឋបាល | |
| ស្ត្រីមានផ្ទៃពោះនៅក្នុងគ្រួសារក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ | នាក់ | n/a | 36,000 | 72,000 | 72,000 | 72,000 | 72,000 | រដ្ឋបាល | |
| កុមារអាយុ ០-២ឆ្នាំ នៅក្នុងគ្រួសារក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ | នាក់ | n/a | 18,000 | 108,000 | 180,000 | 144,000 | 144,000 | រដ្ឋបាល | |
| ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភ ទទួលបានការស្តារនីតិសម្បទា | នាក់ | 494 | 300 | 250 | 250 | 250 | 250 | រដ្ឋបាល | ន.ប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ |
| ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដែលត្រូវបានគាំពារ និងជួយសង្គ្រោះ | នាក់ | n/a | 300 | 220 | 220 | 220 | 220 | រដ្ឋបាល | |
| ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសខ្លួនវិញ | នាក់ | n/a | 10 | 10 | 10 | 10 | 10 | រដ្ឋបាល | |
| ជនរងគ្រោះដោយអំពើជួញដូរបានធ្វើមាតុភូមិនិវត្តន៍ពីក្រៅប្រទេស | នាក់ | n/a | 350 | 220 | 220 | 220 | 220 | រដ្ឋបាល | |
| ជនរងគ្រោះដោយអំពើជួញដូរបានធ្វើសមាហរណកម្មទៅតាមសហគមន៍វិញ | នាក់ | 250 | 300 | 220 | 220 | 220 | 220 | រដ្ឋបាល | |
| ជនរងគ្រោះដោយអំពើជួញដូរត្រូវបានផ្តល់សេវាក្រោយធ្វើសមាហរណកម្ម | នាក់ | n/a | 300 | 200 | 200 | 200 | 200 | រដ្ឋបាល | |
| ជនរងគ្រោះដោយអំពើជួញដូរត្រូវបានបិទករណី | នាក់ | n/a | 150 | 150 | 150 | 150 | 150 | រដ្ឋបាល | |
| កុមារកំព្រា និង កុមារងាយរងគ្រោះដែលរស់នៅក្នុងមណ្ឌលថែទាំកុមារ | នាក់ | 7,639 | 7,481 | 7,336 | 7,189 | 7,045 | 6,904 | រដ្ឋបាល | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| កុមារកំព្រា និង កុមារងាយរងគ្រោះដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | 1,140 | 1,163 | 1,186 | 1,210 | 1,234 | 1,296 | រដ្ឋបាល | ន.សុខុមាលភាពកុមារ |
| កុមាររងគ្រោះដែលទទួលបានថែទាំដោយក្រុមគ្រួសារ និងសហគមន៍ | នាក់ | 10,748 | 10,771 | 10,794 | 10,818 | 10,842 | 10,904 | រដ្ឋបាល | |
| កុមារដែលត្រូវបានសុំកូនអន្តរប្រទេស | នាក់ | n/a | 10 | 15 | 15 | 15 | 15 | រដ្ឋបាល | រដ្ឋបាលសុំកូនអន្តរប្រទេស |
| ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលទទួលបានការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស | ទីភ្នាក់ងារ | n/a | 2 | 2 | 2 | 2 | 2 | រដ្ឋបាល | |
| អនីតិជនប្រព្រឹត្តល្មើសច្បាប់ដែលជាប់ក្នុងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែ និងមណ្ឌលយុវនីតិសម្បទាទទួលបានសេវាស្តារនីតិសម្បទា | នាក់ | n/a | 500 | 500 | 500 | 500 | 500 | រដ្ឋបាល | ន.យុវនីតិសម្បទា |
| កូនតាមម្តាយដែលមានអាយុចាប់ពី៣(បី)ឆ្នាំឡើងទៅ នៅក្នុងពន្ធនាគារត្រូវបានទទួលសេវាសង្គមកិច្ច | នាក់ | n/a | 20 | 20 | 20 | 20 | 20 | រដ្ឋបាល | |
| ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនបានស្តារនីតិសម្បទា | នាក់ | 4,000 | 3,800 | 3,500 | 3,500 | 3,500 | 18,300 | រដ្ឋបាល | |
| ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | n/a | 500 | 500 | 500 | 500 | 500 | រដ្ឋបាល | |
| ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទានៅតាមមជ្ឈមណ្ឌល | នាក់ | 28,000 | 28,000 | 28,000 | 28,000 | 28,000 | 28,000 | PMS4[14] | ម.ជ.ព. |
| ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ | នាក់ | n/a | 55,000 | 55,000 | 55,000 | 55,000 | 55,000 | PMS4[15] | |
| ជនពិការដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មនៅសហគមន៍ | នាក់ | 9,000 | 9,000 | 9,000 | 9,000 | 9,000 | 9,000 | រដ្ឋបាល | |
| ជនពិការក្រីក្រទទួលបានរបបគោលនយោបាយឧបត្ថម្ភ និងសេវាពិនិត្យថែទាំសុខភាព | នាក់ | 946 | 29,253 | 39,701 | 50,148 | 60,596 | 71,043 | រដ្ឋបាល | |
| ជនពិការទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ | នាក់ | n/a | 590 | 590 | 590 | 590 | 590 | រដ្ឋបាល | ន.សុខុមាលភាពជនពិការ |
| ជនពិការត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារនៅតាមស្ថាប័នរដ្ឋ (២%) | នាក់ | 2,773 | 3,000 | 3,000 | 3,000 | 3,000 | 3,000 | រដ្ឋបាល | |
| ជនពិការត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារនៅតាមស្ថាប័ន ឯកជន (១%) | នាក់ | 2,962 | 3,500 | 3,500 | 3,500 | 3,500 | 3,500 | រដ្ឋបាល | |

[14] PMS4: Patients Management System 4
[15] PMS4: Patients Management System 4

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ជនពិការក្រីក្រនៅតាមសហគមន៍ទទួលបានរបបឧបត្ថម្ភគោលនយោបាយ | នាក់ | 7,228 | 10,228 | 13,228 | 16,228 | 19,228 | 22,228 | រដ្ឋបាល | |
| អត្រាមនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានសេវាថែទាំនៅតាមសហគមន៍ | % | n/a | 2% | 3% | 4% | 5% | 6% | រដ្ឋបាល | |
| មនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានសេវាថែទាំក្នុងមជ្ឈមណ្ឌលគាំពារមនុស្សចាស់ | នាក់ | n/a | 30 | 50 | 80 | 100 | 130 | រដ្ឋបាល | ន.សុខុមាលភាពមនុស្សចាស់ |
| មនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានគោលរបបគាំពារសង្គម | នាក់ | n/a | 6,250 | 7,500 | 8,750 | 10,000 | 11,250 | រដ្ឋបាល | |
| និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុកដែលទទួលរបបសន្តិសុខសង្គម | នាក់ | 100,497 | 105,095 | 109,445 | 113,815 | 118,175 | 122,535 | RID[16] | |
| និវត្តជនដែលទទួលរបបសោធន | នាក់ | 52,921 | 55,799 | 58,299 | 60,799 | 63,299 | 65,799 | RID | ប.ជ.ស. |
| ជនបាត់បង់សម្បទាវិជ្ជាជីវៈដែលទទួលរបបសោធន | នាក់ | 2,239 | 2,139 | 2,039 | 1,939 | 1,839 | 1,739 | RID | |
| អ្នកនៅក្នុងបន្ទុក | នាក់ | 45,337 | 47,157 | 49,117 | 51,077 | 53,037 | 54,997 | RID | |
| អតីតយុទ្ធជនដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | 86,889 | 91,749 | 96,249 | 97,249 | 97,749 | 98,249 | VDS[17] | |
| និវត្តជនដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | 26,798 | 31,662 | 35,992 | 37,047 | 37,732 | 38,582 | VDS | |
| ជនបាត់បង់សមត្ថភាពការងារដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | 1,572 | 1,450 | 1,335 | 1,225 | 1,110 | 995 | VDS | |
| ជនពិការដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | 26,601 | 26,531 | 26,686 | 26,691 | 26,646 | 26,551 | VDS | ប.ជ.អ. |
| ជនពលីដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | 25,401 | 25,421 | 25,441 | 25,441 | 25,416 | 25,376 | VDS | |
| ជនមរណៈដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | 6,515 | 6,685 | 6,795 | 6,845 | 6,845 | 6,745 | VDS | |
| និស្សិតដែលបានចុះឈ្មោះចូលរៀនឆ្នាំទី១ | នាក់ | 155 | 150 | 150 | 200 | 200 | 200 | រដ្ឋបាល | |
| និស្សិតដែលកំពុងសិក្សាកម្រិតបរិញ្ញាបត្រ | នាក់ | 500 | 500 | 500 | 550 | 550 | 550 | រដ្ឋបាល | វិទ្យាស្ថានជាតិសង្គមកិច្ច |
| និស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ | នាក់ | 20 | 89 | 98 | 120 | 150 | 150 | រដ្ឋបាល | |
| សិក្ខាកាមដែលបានបញ្ចប់ការសិក្សាកម្រិតវិញ្ញាបនបត្រ | នាក់ | 91 | 150 | 150 | 200 | 250 | 250 | រដ្ឋបាល | |

[16] RID: Retiree and Invalid Database
[17] VDS: Veterans Database System